**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការបំពុលទាំង៥

## (ការបំពុលទឹក ខ្យល់ ដី សំឡេង និងសំណល់រឹង-រាវ)

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **យិន វិសាល** | **បណ្ឌិត អ៊ុន សកក្កដា** |


| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន | ២០១៨ |
| ជំនាន់ទី២២ | ឆ្នាំសរសេរសារណា | ២០២២ |

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការបំពុលនាំង៥

## (ការបំពុលទឹក ខ្យល់ ដី សំឡេង និងសំណល់រឹង-រាវ)

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **យិន ទិសាល**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **យិន ទិសាល** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២១-២០២២។

**សូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ ៖**

- **លោកអ្នកមានគុណ** ដែលបានផ្តល់កំណើតដល់រូបខ្ញុំ ជាពិសេសលោកទាំងពីរតែងតែអប់រំទូន្មានប្រៀនប្រដៅ ដាស់តឿន កូនឱ្យក្លាយជាបុគ្គលដ៏ល្អ ព្រមទាំងជួយជម្រុញ និងលើកទឹកចិត្តដល់កូនឱ្យមានចិត្តតស៊ូពុះពារក្នុងការសិក្សា និងទំនុបបម្រុងកូនទាំងសម្ភារៈ និងថវិការរហូតដល់កូនទទួលបានជោគជ័យក្នុងថ្ងៃនេះ។
- **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង** ព្រមទាំងសាស្ត្រាចារ្យ និងបុគ្គលទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ អប់រំ ផ្តល់ចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនដល់រូបខ្ញុំបាទ រហូតទទួលបានជោគជ័យ និងឈានដល់ការបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ។
- **លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំ និងចង្អុលបង្ហាញពីវិធីសាស្ត្រល្អជាច្រើនដែលទាក់ទងទៅនឹងប្រធានបទសារណា ព្រមទាំងបានចំណាយពេលដ៏មានតម្លៃតាំងពីដើមរហូតដល់បញ្ចប់ក្នុងការសិក្សាស្រាវជ្រាវនេះ។

ជាថ្មីម្តងទៀត ខ្ញុំបាទសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ព្រមទាំងសូមប្រសិទ្ធពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចំពោះ**លោកឪពុក អ្នកម្តាយ និងសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណានេះតាក់តែងឡើង ដើម្បីជាជំនួយដល់ការសិក្សាសម្រាប់ ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ គឺជាលទ្ធផល ដែលកើតចេញមកពីការខិតខំប្រឹងប្រែង បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងអស់រយៈពេល ៤ឆ្នាំកន្លងមក នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីអំពី "ការបំពុលទាំង៥" ដើម្បីបន្សល់ទុកជាឯកសារស្រាវជ្រាវសម្រាប់ជូនសិស្ស និស្សិត និងបណ្ដាអ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដែលមានបំណងធ្វើការចងក្រងជាសារណានេះទុក។ ក្នុងការសរសេរជាសារណានេះ ដើម្បីបញ្ចាក់ការបញ្ចប់ក្នុងការសិក្សារបស់ខ្ញុំបាទ ខ្ញុំបានទទួលការដឹកនាំដោយ **សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា** និងទទួលបាននូវការណែនាំ ការផ្តល់គំនិតយោបល់ល្អៗ ជាពិសេសការជ្រោមជ្រែង និងការផ្តល់ជាមតិយោបល់ល្អៗ ពីសំណាក់លោកគ្រូ ព្រមទាំងសិស្សច្បងទាំងឡាយ។

ការសម្រេចចិត្តជ្រើសរើស ប្រធានបទខាងលើនេះមកសិក្សាស្រាវជ្រាវ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារតែខ្ញុំបាទយល់ឃើញថា វាពិតជាមានសារៈសំខាន់ណាស់សម្រាប់បរិស្ថាន ក្នុងនោះមានបង្ហាញនូវចំណេះដឹង និងវិធីសាស្ត្រនៃការគ្រប់គ្រងបរិស្ថាន ដើម្បីផ្សព្វផ្សាយឱ្យបានទំលំទូលាយដល់ប្រជាពលរដ្ឋខ្មែរ និងជួយបណ្ដុះគំនិត អ្នកដែលបានអានអត្ថបទមួយនេះឱ្យមានចិត្តស្រលាញ់ និងជួយការពារបរិស្ថានឱ្យបានល្អ និងចាំបាច់ត្រូវមានការចូលរួមពីសំណាក់ប្រជាជនគ្រប់រូប ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផ្ទាល់ និងសង្គមជាតិទាំងអស់ ដែលធ្វើឱ្យទីក្រុងបរិស្ថានស្អាតល្អ និងអាចជាគំរូដល់កូនចៅជំនាន់ក្រោយ។

ការសិក្សាស្រាវជ្រាវអត្ថបទមួយនេះ ត្រូវបានចាប់ផ្តើមឡើងដោយ ការសិក្សាតាមរយៈឯកសារច្បាប់មួយចំនួនដែលពាក់ព័ន្ធនឹងបរិស្ថាន ការប្រមូលព័ត៌មានតាមរយៈសៀវភៅណែនាំនានាដែលពាល់ព័ន្ធ និងបរិស្ថាន តាមរយៈប្រព័ន្ធអ៊ីនធើណេត និងតាមរយៈឯកសារផ្សេងៗទៀតជាច្រើន រួចយកមកដាក់បញ្ចូលគ្នាក្នុងគោលបំណងឆ្លុះបញ្ចាំងឱ្យឃើញនូវប្រភពដែលនាំឱ្យកើតមានការបំពុល និងផលវិបាកផ្សេងៗទៀតដែលកើតមានឡើងចំពោះបរិស្ថាន។

ជាចុងក្រោយ បើទោះបីជាខ្ញុំបាទមានការខិតខំសិក្សាស្រាវជ្រាវ និងត្រួតពិនិត្យយ៉ាងម៉ត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណាមួយនេះនៅតែមានចន្លោះខ្វះខាត ដូច្នេះខ្ញុំបាទសុំអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គងដោយអចេតនាទាំងឡាយណាដែលមានកើតឡើងក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ របស់ខ្ញុំនឹងត្រៀមខ្លួនជានិច្ចដោយរងចាំទទួលនូវមតិរិះគន់កែលម្អក្នុងន័យស្ថាបនាយ៉ាងខ្ពង់ខ្ពស់ពីសំណាក់សិស្ស និស្សិត អ្នកស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់ ដើម្បីជួយផ្តល់ជាមតិ និងគំនិតល្អៗបន្ថែមទៀត ក្នុងការកែលម្អសារណានេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរថែមទៀតផងដែរ។ ក្រោយពីបានសិក្សាស្រាវជ្រាវបញ្ចប់ ខ្ញុំបាទសង្ឃឹមថាសារណាមួយនេះ និងក្លាយជាឯកសារមួយដែលចូលរួមចំណែកក្នុងការជំរុញឱ្យបរិស្ថានកាន់តែមានភាពល្អប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបរិស្ថាន**

**១.១. ទិដ្ឋភាពទូទៅនៃបរិស្ថាន** ............ ៤

១.១.១. និយមន័យ ............ ៦

១.១.២. ប្រភេទនៃបរិស្ថាន ............ ៧

**១.២. ទំនាក់ទំនងបរិស្ថាន និងសង្គម** ............ ៧

១.២.១. បរិស្ថានសង្គម-វប្បធម៌ ............ ៧

១.២.២. បរិស្ថានធម្មជាតិ ............ ៨

១.២.៣. បរិស្ថានមនុស្ស ............ ៨

**១.៣. សមត្ថកិច្ចគ្រប់គ្រងបរិស្ថាន** ............ ៨

១.៣.១. ការគ្រប់គ្រងធនធានធម្មជាតិ ............ ១០

១.៣.២. កិច្ចការពារបរិស្ថាន ............ ១១

**ជំពូកទី២**

**ការបំពុលបរិស្ថានទាំង៥ ផលប៉ះពាល់ និងដំណោះស្រាយ**

**២.១. មូលហេតុនៃការបំពុលទាំង៥** ............ ១២

២.១.១. មូលហេតុនៃការបំពុលទឹក ............ ១២

២.១.២. មូលហេតុនៃការបំពុលខ្យល់ ............ ១៤

២.១.៣. មូលហេតុនៃការបំពុលសំឡេង ............ ១៦

២.១.៤. មូលហេតុនៃការបំពុលដី ............ ១៦

២.១.៥. មូលហេតុនៃការបំពុលសំណល់រឹង រាវ ............ ១៧

**២.២. ផលប៉ះពាល់នៃការបំពុលទាំង៥** ............ ១៩

២.២.១. ផលប៉ះពាល់ដោយការបំពុលទឹក ........ ១៩
២.២.២. ផលប៉ះពាល់ដោយការបំពុលខ្យល់ ........ ២០
២.២.៣. ផលប៉ះពាល់ដោយការបំពុលដោយសំឡេង ........ ២២
២.២.៤. ផលប៉ះពាល់ដោយការបំពុលដី ........ ២៣
២.២.៥. ផលប៉ះពាល់ដោយការបំពុលសំណល់រឹង រាវ ........ ២៦
**២.៣. វិធានការដោះស្រាយនៃការបំពុល** ........ ២៨
២.៣.១. វិធានការដោះស្រាយនៃការបំពុលទឹក ........ ២៨
២.៣.២. វិធានការដោះស្រាយនៃការបំពុលខ្យល់ ........ ២៩
២.៣.៣. វិធានការដោះស្រាយនៃការបំពុលដី ........ ៣១
២.៣.៤. វិធានការដោះស្រាយនៃការបំពុលសំឡេង ........ ៣២
២.៣.៥. វិធានការដោះស្រាយនៃការបំពុលសំណល់រឹង រាវ ........ ៣៣
**សេចក្តីសន្និដ្ឋាន** ........ ៤០
**អនុសាសន៍** ........ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

បរិស្ថាន គឺមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយ និងជីវិតរស់នៅក្នុងសង្គម។ ភាវៈរស់ទាំងអស់រួមមាន មនុស្ស សត្វ រុក្ខជាតិទាំងឡាយមានសុខភាពល្អ ឬមិនល្អ មានអាយុវែង ឬខ្លី គឺអាស្រ័យទៅនឹងកម្រិតបរិស្ថាន ដែលកំពុងរស់នៅជាមួយ។ បើសិនជា បរិស្ថានស្អាតក៏ធ្វើឱ្យជីវិតរស់នៅរបស់យើង និងសុខភាពរបស់យើងល្អ ទៅតាមមជ្ឈដ្ឋាននោះដែរ។ មនុស្សទាំងឡាយតែងតែគិតថាខ្លួនឯងជាចំណែកមួយផ្នែកនៃបរិស្ថាន ដែលពាក់ព័ន្ធ និងសុខុមាលភាពចាំបាច់ សម្រាប់ជីវិតពួកគេ និងការអភិវឌ្ឍន៍បន្តទៀត។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ការយល់ដឹងមួយនេះត្រូវបានអន់ថយបន្តិចម្តងៗ ដោយសារតែការរីកចម្រើនជឿនលឿនផ្នែកខាង ឧស្សាហកម្ម នគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី មនុស្សអ្នកបង្កើតនូវបញ្ហាទាំងឡាយនេះ តាមរយៈសកម្មភាព និងសេចក្តីសម្រេចចិត្ត។ ដោយសារតែសកម្មភាពរីកចម្រើនជឿនលឿនទាំងអស់នេះហើយ ទើបធ្វើឱ្យមានការផ្លាស់ប្តូរបរិស្ថានយ៉ាងឆាប់រហ័ស ក្នុងទ្រង់ទ្រាយធំ តាមរយៈសកម្មភាពទាំងអស់របស់មនុស្ស ដូច្នេះហើយ យើងត្រូវយល់ដឹងពីបញ្ហាបរិស្ថាន និងការគ្រប់គ្រងបញ្ហាទាំងអស់នេះឱ្យបានសមស្រប ដែលអាចការពារបរិស្ថានសម្រាប់យើងផ្ទាល់ និងសម្រាប់មនុស្សជំនាន់ក្រោយៗផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យទទួលបាននូវលក្ខណៈស៊ីជម្រៅ ក៏ដូចជាភាពកាន់តែច្បាស់លាស់បន្ថែមទៀតនោះលើប្រធានបទស្រាវជ្រាវខាងលើ ខ្ញុំបាទបានលើកឡើងនូវចំណោទបញ្ហាដើម្បីធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមាន៖ តើការបំពុលបរិស្ថានបណ្តាលមកពីកត្តាអ្វីខ្លះ? ហើយតើមានដំណោះស្រាយយ៉ាងណាដើម្បីដោះស្រាយការបំពុលបរិស្ថាន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកនូវប្រធានបទទាក់ទងនឹងប្រធានបទមួយដែលស្តីពី ការបំពុលបរិស្ថាន និងដំណោះស្រាយ គឺក្នុងគោលបំណងគឺចង់បង្ហាញឱ្យសាធារណៈជនទូទៅបានដឹង និងស្វែងយល់អំពីសារៈសំខាន់នៃ បរិស្ថាន និងការបំពុលបរិស្ថាន ព្រោះគ្រប់ភាវៈរស់គឺត្រូវការចាំបាច់ជាមួយទំនាក់ទំនងជាមួយបរិស្ថានសម្រាប់ការរស់នៅសព្វថ្ងៃ បានសេចក្តីថាមានបរិស្ថានទើបមានជីវិត ប៉ុន្តែបរិស្ថាននោះគួរតែជាបរិស្ថានធម្មជាតិដើម្បីជីវិតមានការរស់នៅនឹងលូតលាស់ល្អជាមួយគ្រប់ភាវៈ និងជីវៈចម្រុះ។

បន្ថែមពីនេះទៅទៀត គោលបំណងនៃការបង្កើតស្នាដៃនៃការសិក្សាស្រាវជ្រាវលើប្រធានបទសិក្សាស្រាវជ្រាវមួយនេះ គឺមាននូវគោលបំណងនៅក្នុងការបង្ហាញអំពីសារៈសំខាន់នៃបរិស្ថានសម្រាប់ជីវិតមនុស្ស សត្វ រុក្ខជាតិ ក៏ដូចជាជីវៈចម្រុះគ្រប់ប្រភេទ ជាពិសេសជាងនេះទៅទៀតនោះគឺចង់ឱ្យសាធារណៈជនជាពិសេស

គឺអ្នកសិក្សាទូទៅឱ្យដឹងអំពីការបំពុលបរិស្ថាន ពីព្រោះយើងដឹងហើយថាការបំពុលបរិស្ថាន គឺជា សកម្មភាព ដែលអាចបំផ្លាញនូវជីវិតនៅលើផែនដី ព្រមទាំងចង់បង្ហាញអំពីការចូលរួមពីសំណាក់ស្ថាប័នដែល ពាក់ព័ន្ធ ដែលបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការជួយថែរក្សាបរិស្ថាន ក៏ដូចជាមានដំណោះស្រាយចំពោះការ បំពុលបរិស្ថានផងដែរ។

## ៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺផ្ដើលើកឡើងតែអំពីការបំពុលទាំង៥ នៃបរិស្ថានតែប៉ុណ្ណោះ ហើយ ចំពោះសារណានេះ ខ្ញុំបាទសូមលើកយកតែប្រភពនៃការបំពុលបរិស្ថានទាំង៥ ផលប៉ះពាល់នៃការបំពុលទាំង៥ និងដំណោះស្រាយនៃការបំពុលទៅលើបញ្ហាទាំងអស់នេះ។ ជាការពិតណាស់រាល់ស្នាដៃសិក្សាស្រាវជ្រាវទាំង អស់ គឺសុទ្ធសឹងតែមាននូវគោលបំណងសំខាន់ៗនៅក្នុងកិច្ចការស្រាវជ្រាវនោះ។ យ៉ាងណាមិញនៅក្នុងការ សិក្សាស្រាវជ្រាវដែលទាក់ទងនឹងការបំពុលបរិស្ថាន ព្រោះយើងដឹងហើយថានាពេលបច្ចុប្បន្ននេះប្រទេសយើង កំពុងទទួលបានការគំរាមកំហែងផងដែរចំពោះបញ្ហានៃការបំពុលបរិស្ថានជាខ្លាំង។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះផង ដែរ រាជរដ្ឋាភិបាលបាននឹងកំពុងជួយដោះស្រាយយ៉ាងសកម្មជាមួយនឹងគោលការណ៍ សម្រាប់អនុវត្តព្រមទាំង ការចូលរួមពីសំណាក់ស្ថាប័នដែលពាក់ព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗជាច្រើនទៀតដែលជាដំណោះស្រាយ សម្រាប់បរិស្ថាន។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំបាទ និងអ្នកសិក្សាដទៃទៀតក្នុងការបំពេញ ចំណេះដឹងបន្ថែម ក្រៅពីការសិក្សាក្នុងម៉ោងសិក្សានៅសាលា និងសៀវភៅ។ ម៉្យាងទៀតវិញ ប្រធានបទនេះបាន ចូលរួមយ៉ាងសំខាន់ក្នុងការយល់ដឹងពីការបំពុល និងការគ្រប់គ្រងបរិស្ថានឱ្យកាន់តែមានប្រសិទ្ធភាព និងជា ពិសេស គឺអ្នកជំនាន់ក្រោយនឹងអាចទទួលបានឯកសារ និងបានស្វែងយល់កាន់តែច្រើន ដើម្បីបំពេញសេចក្ដីត្រូវការ ឬក៏អាចជាការជួយបាននូវអ្វីដែលខ្វះខាតនានា នៅពេលបច្ចុប្បន្ននេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីស្រាវជ្រាវសរសេរចងក្រងសារណាមួយនេះ ចំពោះឯកសារ ខ្ញុំបាទបានធ្វើការស្រាវជ្រាវលើការ គ្រប់គ្រងឯកសារពាក់ព័ន្ធ ដូចជា ច្បាប់ អនុក្រឹត្យ សារាចរណែនាំ សៀវភៅណែនាំនានាទាក់ទងទៅនឹងបរិស្ថាន និងតាមរយៈប្រព័ន្ធអ៊ីនធើណេត ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ ខ្ញុំបាទបានធ្វើការបែងចែកជា ពីរជំពូករួមមាន៖

## ជំពូកទី១ ៖ សញ្ញាណទូទៅនៃបរិស្ថាន

នៅក្នុងជំពូកនេះខ្ញុំបាទនឹងបែងចែកជាបីចំនុចបន្ថែមទៀតគឺ ចំនុចទី១ និយាយអំពីសញ្ញាណទូទៅនៃបរិស្ថាន ដោយចំនុចទី២ បង្ហាញអំពីទំនាក់ទំនងបរិស្ថាន និងសង្គម និងចំនុចទី៣ បកស្រាយអំពីសារៈសំខាន់នៃបរិស្ថាន។

## ជំពូកទី២ ៖ ការបំពុលបរិស្ថានទាំង៥ ផលប៉ះពាល់ និងវិធានការដោះស្រាយ

នៅក្នុងជំពូកនេះខ្ញុំបាទនឹងបែងចែកជាបីចំនុចបន្ថែមទៀត ដោយចំនុចទី១ និយាយអំពីមូលហេតុនៃការបំពុលទាំង៥ ដោយចំនុចទី២ បង្ហាញអំពីផលប៉ះពាល់នៃការបំពុលទាំង៥ និងចំនុចទី៣ បកស្រាយអំពីវិធានការដោះស្រាយនៃការបំពុល។

# ជំពូកទី១
# សញ្ញាណទូទៅនៃបរិស្ថាន

# ជំពូកទី១
# សញ្ញាណទូទៅនៃបរិស្ថាន

## ១.១. ទិដ្ឋភាពទូទៅនៃបរិស្ថាន

បរិស្ថានរបស់ប្រទេសកម្ពុជាផ្តល់នូវធនធានធម្មជាតិ រួមមាន ព្រៃឈើ ផ្លូវទឹក រុក្ខជាតិ និងសត្វព្រៃ។ ធនធានធម្មជាតិ ក៏រួមបញ្ចូលផងដែរនូវ រ៉ែ ថាមពល និងឧស្សាហកម្មនិស្សារណកម្ម។ បរិស្ថាន គ្របដណ្តប់ដោយទេសភាពផ្សេងៗគ្នា យ៉ាងហោចណាស់ចំនួន ០៧នៅទូទាំងប្រទេស។ ប្រហែលបីភាគបួននៃប្រជាជនកម្ពុជាពឹងផ្អែកលើ កសិកម្ម ទិន្នផលព្រៃឈើ និងនេសាទ ដើម្បីចិញ្ចឹមជីវិត។ ដូច្នេះការថែរក្សាបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ មានសារៈសំខាន់ណាស់។

បរិស្ថានរបស់ប្រទេសកម្ពុជា ក៏ត្រូវបានចាត់ទុកជាធនធានមួយសម្រាប់ពិភពលោក។ ជាផ្នែកមួយនៃតំបន់ឥណ្ឌូចិនភូមា ប្រទេសកម្ពុជា គឺជាទីកំណប់ធនធានជីវចម្រុះ និងជាប្រទេសដែលមានរុក្ខជាតិ សត្វកម្រ និងសត្វជិតផុតពូជចំនួន ២,៤៤៩ ប្រភេទ។ ទោះយ៉ាងណាក្តី ការអភិវឌ្ឍសេដ្ឋកិច្ចបានបង្កឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ ១៩៩០ ជាងមកម្ល៉េះ។

ទោះបីជាភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវបានគ្រប់ដណ្តប់ដោយដោយតំបន់ទំនាបកណ្តាល ប្រហែលបីភាគបួននៃប្រទេសកម្ពុជា មានទេសភាពខុសៗគ្នាជាច្រើនផ្សេងទៀត គឺ ព្រៃតំបន់ខ្ពង់រាប រួមមានតំបន់ភ្នំក្រវាញ ដងរែក និងភ្នំឆ្លូង ព្រៃលិចទឹក បឹងទន្លេសាប និងប្រព័ន្ធទន្លេមេគង្គ វាលទំនាប ខាងកើត ឬតំបន់ខ្ពង់រាបព្រៃឈើកណ្តាល តំបន់ឆ្នេរសមុទ្រដែលរួមមានដីល្បាប់ កោងកាង និងកោះ ឈូងសមុទ្រថៃ។

ប្រហែលពីរភាគបីនៃប្រទេសកម្ពុជា រួមមាន បឹងទន្លេសាប ដែលស្ថិតនៅក្នុងអាងទន្លេមេគង្គ គឺជាបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី រួមចំណែកយ៉ាងសំខាន់ដល់សុខមាលភាពនៃតំបន់មេគង្គទាំងមូល ជាពិសេសតំបន់ ដីសណ្តទន្លេមេគង្គ។ កាលដើមឆ្នាំ២០០១ អង្គការស្បៀងអាហារនឹងកសិកម្ម បានគូសបញ្ជាក់ពី ការផ្លាស់ប្តូរប្រព័ន្ធអេកូទន្លេសាបដែលបាននាំយកមកនូវកំណល្បាប់ម៉ដ្ឋ គឺមីកសិកម្ម ការបំពុល ផ្សេងៗ បម្រែបម្រួលធារាសាស្ត្រ ការស្រោចស្រព និងការដឹកជញ្ជូន ហើយជាការពិត ការផ្លាស់ប្តូរទាំងនេះ និងមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង ដល់ប្រព័ន្ធទន្លេមេគង្គទាំងមូល។

ក្រសួងបរិស្ថាន ជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តច្បាប់បរិស្ថាន និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ស្របទៅនឹងអាណត្តិក្នុងរដ្ឋធម្មនុញ្ញដែលរដ្ឋបានទទួលខុសត្រូវក្នុងការ "ការពារបរិស្ថាន និងតុល្យភាពនៃធនធានធម្មជាតិដ៏បរិបូរណ៍"។

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន បានចេញផ្សាយគោលនយោបាយការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC)

របស់ខ្លួន កាលពីខែ តុលា ឆ្នាំ ២០១៥ ដែលផ្តោតសំខាន់លើការកាត់បន្ថយការបំភាយឧស្ម័ន ផ្ទះកញ្ចក់ឱ្យបាន ២៧ ភាគរយ ពីកម្រិតស្ថានភាពដដែល ដែលបានព្យាករសម្រាប់ឆ្នាំ ២០៣០ លើសពី នេះ គោលនយោបាយនេះ បានកំណត់គោលដៅមួយក្នុងការបង្កើននូវគម្របព្រៃឈើ ៦០ ភាគរយ នៃផ្ទៃដី សរុបនៅឆ្នាំ ២០៣០។ មុនពេល ចេញផ្សាយ គោលនយោបាយនេះ ការចំណាយលើ ការប្រែប្រួល អាកាសធាតុ ត្រូវបានកំណត់ថានឹងកើនឡើង ១.៥ ភាគរយនៃ ផលិតផល ក្នុងស្រុកសរុប នៅឆ្នាំ ២០១៨។

មានឯកសារយុទ្ធសាស្ត្រជាច្រើនផ្តោតលើការការពារបរិស្ថាន និងធនធានធម្មជាតិ។ យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដាក់អាទិភាពខ្ពស់ទៅលើការការពារ បរិស្ថាន។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា មានចំណុចដៅមួយថា "បញ្ចូលគោលការណ៍អភិវឌ្ឍន៍ ប្រកបដោយចីរភាព ទៅក្នុងគោលនយោបាយនឹងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន"។ ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) សម្រាប់ឆ្នាំ ២០១៤-២០១៨ មានចែងពីសារៈសំខាន់នៃការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

នៅឆ្នាំ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ដែលអនុវត្តដោយក្រសួងបរិស្ថាន សម្គាល់តំបន់ការពារ ២៣ ដែលនៅពេលនោះគ្របដណ្តប់ជាង ១៨ ភាគរយ នៃផ្ទៃដីនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជក្រឹត្យនេះចែកតំបន់ការពារជាបួនប្រភេទ៖

- ឧទ្យានធម្មជាតិ
- ដែនជម្រកសត្វព្រៃ
- តំបន់ការពារទេសភាព
- តំបន់ប្រើប្រាស់ច្រើនយ៉ាង។

សន្ទស្សន៍អភិបាលកិច្ចធនធានរបស់កម្ពុជា "ធ្លាក់មកត្រឹមលេខ ៣០" នៃ ១០០ ពិន្ទុ ក្នុងឆ្នាំ ២០១៧ ជា ប្រទេសជាប់ចំណាត់ថ្នាក់ទី ៧៩ ក្នុងចំណោម ៨៩ ប្រទេស និងជាប្រទេសជាប់ចំណាត់ថ្នាក់ទី ១៤ ក្នុងចំណោម ១៥ ប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ពិន្ទុសម្រាប់ការរុករករ៉ែមាសនៅដំណាក់កាលដំបូង ដែលឆ្លុះបញ្ចាំងឱ្យ ឃើញ ពីការចាត់ថ្នាក់នៅមានភាពខ្សោយចំពោះថវិការជាតិ និងអាជ្ញាប័ណ្ណជាពិសេស។

ចំពោះគុណតម្លៃបរិស្ថាន រដ្ឋាភិបាលបានទទួលស្គាល់នូវការចូលរួមចំណែកទាំងផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍ នៅក្នុងវិស័យផ្សេងៗ នៃធនធានបរិស្ថាន និងធម្មជាតិរបស់ជាតិ ។ គោលនយោបាយវិស័យព្រៃឈើជាតិ សម្គាល់នូវការអភិវឌ្ឍ ផ្នែកសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ ដែលស្ថិតក្នុងចំណោមកត្តាចលករពីរ នៅក្នុងសកម្មភាព គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ទោះយ៉ាងណាក្តី របាយការណ៍មួយចំនួន បានឱ្យ

ដឹងថាទោះបីជាមាន ក្របខ័ណ្ឌច្បាប់មួយដែលរឹងមាំសម្រាប់បរិស្ថានក៏ដោយ ក៏របាយការណ៍នោះ មិនត្រូវបានអើពើ ឬបោះជំហានទៅម្ខាងទៀតដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរយៈពេលខ្លី។

ការអភិរក្សបរិស្ថាន បានចូលរួមចំណែកដោយប្រយោល ដល់ចំណូលបានមកពីវិស័យទេសចរណ៍ តាមរយៈកម្មវិធីអេកូទេសចរណ៍ ដែលទាក់ទាញភ្ញៀវទេសចរបានចំនួន ១.៣ ភាគរយ នៃចំនួន ភ្ញៀវទេសចរ ទាំងអស់នៅក្នុងឆ្នាំ ២០១៤។ ក្នុងឆ្នាំនោះដែរ វិស័យទេសចរណ៍ បានចូលរួមចំណែកនូវទឹកប្រាក់ ២.៧៣៦ ពាន់លានដុល្លារសហរដ្ឋអាមេរិចដល់សេដ្ឋកិច្ច។

ប្រទេសកម្ពុជា មានជីវៈចម្រុះដ៏សម្បូរបែប រួមមាន សត្វ និងរុក្ខជាតិចម្រុះជាច្រើនប្រភេទ និងមានធនធានព្រៃឈើ ដែលប្រជាជនក្រីក្រជាច្រើននៅតាមជនបទ ពឹងអាស្រ័យលើសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ទោះជាយ៉ាងណា ប៉ុន្មានឆ្នាំចុងក្រោយនេះ ធនធានព្រៃឈើកាន់តែស្ថិតនៅក្រោមសម្ពាធពីការប្រើប្រាស់ដីសេដ្ឋកិច្ចខ្លាំងឡើងៗ។ ទន្ទឹមនឹងនោះប្រទេសកម្ពុជា ជាប្រទេសងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ដោយសារតែសមត្ថភាពនៃការបន្សាំនៅទាប។ ប្រជាជននៅតាមជនបទ ភាគច្រើនស្ថិតក្នុងហានិភ័យដោយសារព្រឹត្តិការណ៍ អាកាសធាតុបំផ្លិចបំផ្លាញ ជាពិសេស ទឹកជំនន់ និងគ្រោះរាំងស្ងួត។[1]

### ១.១.១. និយមន័យ

បរិស្ថានមាននិយមន័យជាច្រើនដែលអ្នកវិទ្យាសាស្ត្របានកំណត់ និងបានចងក្រងឡើងមានដូចជា៖ **បរិស្ថាន** គឺជាមជ្ឈដ្ឋាន ដែលនៅជុំវិញខ្លួនយើង ឬជារបស់របរវត្ថុ ដែលនៅលោកព័ទ្ធយើង ហើយមានឥទ្ធិពលដល់ជីវិត និងការលូតលាស់របស់បណ្តាភាវៈ។ បរិស្ថានចែកចេញជា៣ផ្នែកគឺ ៖

- បរិស្ថានធម្មជាតិ រួមមានបរិស្ថានគ្មានជីវិត (ទឹក ដី ភ្លើង ខ្យល់ ភ្នំ ព្រៃឈើ) និងបរិស្ថានមានជីវិត មនុស្ស សត្វ និងរុក្ខជាតិ ។
- បរិស្ថានមនុស្សជាសំណុំលក្ខខណ្ឌរូបសាស្ត្រ គីមី ជីវសាស្ត្រ រួមជាមួយកត្តាសង្គមនានាដែលកំណត់ការរស់នៅរបស់មនុស្ស ក្នុងពេលជាក់លាក់ណាមួយ ។
- បរិស្ថានសង្គម មានដូចជាសំណង់អាគារហេដ្ឋារចនាសម្ព័ន្ធ ទីក្រុង ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រោងចក្រ សហគ្រាស សិប្បកម្ម សួនច្បារ វិមានរដ្ឋសភា វិមានរាជរដ្ឋាភិបាល និងសកម្មភាពសង្គមផ្សេងៗទៀត។[2]

[1] គេហទំព័រ https://opendevelopmentcambodia.net/km/topics/environment-and-natural-resources/ ដកស្រង់ថ្ងៃទី២៥ មីនា ២០២២

[2] គេហទំព័រ https://www.khsearch.com/qna/16521ដកស្រង់ថ្ងៃទី២៥ មីនា ២០២២

ទោះបីជាមានការអេះអាងខុសៗគ្នាក៏ដោយ តែជារួម **បរិស្ថាន** គឺសំដៅទៅលើអ្វីៗទាំងអស់ ដែលនៅជុំវិញខ្លួនយើង ទាំងមានជីវិត និងគ្មានជីវិត មានក្លិនគ្មានក្លិន អាចប៉ះបានមិនអាចប៉ះបាន អាចមើលឃើញមិនអាចមើលឃើញ ហើយដែលមានចំណងទាំងទងដោយផ្ទាល់ ឬដោយប្រយោល មកលើជីវិតយើងទាំងអស់គ្នា។

### ១.១.២. ប្រភេទនៃបរិស្ថាន

យើងដឹងហើយថា បរិស្ថាន (Environment) គឺជាអ្វីៗដែលនៅជុំវិញខ្លួនរបស់យើង ដែលយើងមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយវា ហើយជីវិតយើងត្រូវការវាមិនអាចខ្វះបានឡើយ។

បរិស្ថានមាន៣មានគឺ ប្រភេទគឺ ៖

- បរិស្ថានសង្គម-វប្បធម៌
- បរិស្ថានធម្មជាតិ
- បរិស្ថានមនុស្ស។[3]

## ១.២. ទំនាក់ទំនងបរិស្ថាន និងសង្គម

### ១.២.១. បរិស្ថានសង្គម-វប្បធម៌

**បរិស្ថានសង្គម វប្បធម៌** សំដៅលើអ្វីៗដែលប្រសូតឡើងដោយស្នាដៃពលកម្ម ផលិតកម្ម និងការចាត់តាំងប្រកបដោយបំនិនប្រសប់ និងដោយមានការច្នៃប្រឌិតរបស់មនុស្ស ដើម្បីបំពេីតាមសំណូមពរ និងតំរូវការចាំបាច់ក្នុងជីវភាពរស់នៅទាំងផ្នែកសំភារៈ និងស្មារតីព្រមទាំងការគ្រប់គ្រងដឹកនាំសង្គមឆ្ពោះទៅរកការរីកចម្រើន។[4]

បរិស្ថានសង្គម វប្បធម៌ ចែកចេញជាពីរ ៖

- **បរិស្ថាន សង្គមមានជីវិត ៖** សំដៅលើរាល់ស្ថាប័នសង្គមជាក់ស្តែង ដែលក្នុងនោះមានអ្នកដឹកនាំ និងអ្នកត្រូវគេដឹកនាំ ដើម្បីជានាសណ្តាប់ធ្នាប់ និងការអភិវឌ្ឍ។ តែវាក៏ជាសកម្មភាពសង្គមមួយដែលស្មុគស្មាញដែលផ្តើមចេញពីសកម្មភាពនយោបាយនឹងសេដ្ឋកិច្ច ដែលជាកត្តាសំខាន់ក្នុងចំណោមបញ្ហាសង្គម កត្តាច្នៃប្រឌិតធម្មជាតិ និងសមិទ្ធផលនានាផងដែរ ។
- **បរិស្ថានសង្គម វប្បធម៌គ្មានជីវិត ៖** សំដៅលើ រាល់វត្ថុប្រើប្រាស់គ្រប់បែបយ៉ាងដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រភូមិ ឬសំណង់នានា គ្រឿងដឹកជញ្ជូនគ្រប់ប្រភេទ និងសមិទ្ធផលវប្បធម៌ជាដើម។

---

[3] គេហទំព័រ ៖ https://www.khsearch.com/qna/8284 ដកស្រង់ថ្ងៃទី២៥ មីនា ២០២២

[4] គេហទំព័រ ៖ https://www.khsearch.com/qna/18682 ដកស្រង់ថ្ងៃទី២៥ មីនា ២០២២

### ១.២.២. បរិស្ថានធម្មជាតិ

**បរិស្ថានធម្មជាតិ** គឺសំដៅលើសរីរាង្គដែលកើតឡើងដោយឯកឯងក្រៅពីសកម្មភាពពលកម្ម និងផលិតកម្មរបស់មនុស្ស គឺវាកើតឡើងដោយលក្ខណៈធម្មជាតិរួមផ្សំបង្កើតឡើង ហើយវាមានមុនរួចជាស្រេច មុននឹងកកើតមានមនុស្សលើពិភពលោក។ បរិស្ថានធម្មជាតិ គឺជាការវិវត្តិតាមក្រឹត្យក្រមធម្មជាតិ វាមិនចំណុះឆន្ទៈរបស់មនុស្សឡើយ តែមនុស្សអាចស្វែងយល់បានពីក្រឹត្យក្រមរបស់វា និងធ្វើការអនុវត្តតាមក្រឹត្យក្រមនោះ ហើយទទួលបានផលពីវា។

បរិស្ថានធម្មជាតិ ចែកចេញជាពីរ ៖

- **បរិស្ថានធម្មជាតិមានជីវិត** រួមមានមនុស្ស សត្វ រុក្ខជាតិ សព្វសារពើ គឺរាប់តាំងពីសត្វតូចល្អិត ដែលមិនអាចមើលឃើញដោយភ្នែកទទេរហូតដល់សត្វ ឬរុក្ខជាតិធំៗ ហើយវាអាចបន្តពូជជពង្សវាក្នុងលក្ខខណ្ឌបរិស្ថានសមស្របរបស់វា។
- **បរិស្ថានធម្មជាតិគ្មានជីវិត** រួមមាន ទឹក ដី ភ្លើង ខ្យល់ ដែលជាសារធាតុចំបងក្នុងការបង្កើតមនុស្ស សត្វ និងរុក្ខជាតិ ពហុសណ្ឋានលើភពផែនដីយើងនេះ។[5]

### ១.២.៣. បរិស្ថានមនុស្ស

**បរិស្ថានមនុស្ស** គឺជាមនុស្សជាតិទូទៅ ដែលរស់នៅលើភពផែនដីយើងទាំងអស់នេះ។

បរិស្ថានមនុស្ស ចែកចេញជាពីរ ៖

- **បរិស្ថានមនុស្សមានជីវិត** ៖ មនុស្សដែលកំពុងរស់នៅប្រកបមុខរបរ ចិញ្ចឹមជីវិតប្រចាំថ្ងៃ។
- **បរិស្ថានមនុស្សឥតជីវិត** ៖ មនុស្សដែលបាត់បង់ជីវិតទៅ (បុព្វបុរស) និងមនុស្សជំនាន់មុន។

## ១.៣. សមត្ថកិច្ចគ្រប់គ្រងបរិស្ថាន

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលសម្បូរទៅដោយជីវៈចម្រុះជាច្រើន ក្នុងចំណោមបណ្ដាប្រទេសនានានៅតំបន់អាស៊ីអាគ្នេយ៍។ ជីវៈចម្រុះ ជួយទ្រទ្រង់ដល់ប្រជាជនកម្ពុជា ទាំងផ្នែកបរិស្ថាន សេដ្ឋកិច្ច និងវប្បធម៌។ ជីវៈចម្រុះ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់នូវផលប្រយោជន៍ ប្រព័ន្ធអេកូឡូស៊ីដល់ មនុស្សជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីឱ្យសម្រេចបាននូវ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ព្រមទាំងការកាត់បន្ថយភាពក្រីក្រផងដែរ។[6] ដោយមានប្រជាជន ៧៦ ភាគរយនៃចំនួនប្រជាជនសរុបកំពុងរស់នៅតាមតំបន់ជនបទ។ ប្រទេសកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានប្រជាជនរស់នៅតាមទីជនបទច្រើនជាងគេនៅលើពិភពលោកខណៈ

---

[5] គេហទំព័រ ៖ https://www.khsearch.com/qna/18681 ដកស្រង់ថ្ងៃទី២៥ មីនា ២០២២

[6] គេហទំព័រ ៖ https://opendevelopmentcambodia.net/km/topics/environmental-and-biodiversity-protection/ ដកស្រង់ថ្ងៃទី២៦ មីនា ២០២២

ដែលជីវភាពរស់នៅរបស់ពួកគេ ជិត ២ ភាគ ៣ គឺពឹងផ្អែកទៅលើកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នៅចំពោះមុខការពង្រីកគម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធដែលកំពុងបន្តសម្របសម្រួលដោយលំហូរមូលធនការវិនិយោគ ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពពិតជាមានការចាំបាច់ណាស់សម្រាប់សុខុមាលភាពប្រជាជនកម្ពុជារាប់លាននាក់។

ប្រព័ន្ធអេកូឡូស៊ីធម្មជាតិរបស់ប្រទេសកម្ពុជាគឺសំបូរបែបនិងមានភាពខុសប្លែកគ្នា រាប់បញ្ចូលទាំងព្រៃឈើ ពពួកសត្វ រ៉ែ ផ្កាថ្ម និងសត្វព្រៃជាច្រើនប្រភេទ។ ទោះបីដីជិត ៤០ភាគរយនៃប្រទេសកម្ពុជាត្រូវបានការពារក្រោមច្បាប់ក៏ដោយ ការរិចរិលបរិស្ថានកាន់តែធ្ងន់ធ្ងរកំពុងធ្វើឱ្យខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី គំរាមកំហែងដល់ជីវចម្រុះ សត្វព្រៃ និងធនធានធម្មជាតិ។ ការបំលែងដីព្រៃសម្រាប់គោលបំណងកសិកម្ម សកម្មភាពរុករករ៉ែ ការទាញយករ៉ែកំពុងបង្កើនអត្រានៃការរិចរិលដី និងការកាប់បំផ្លាញព្រៃឈើ។ រួមជាមួយនឹងការប្រមូលផលឈើខុសច្បាប់ ការបរបាញ់សត្វព្រៃ និងការនេសាទហួសកំរិត សកម្មភាពទាំងនេះកំពុងបង្កហានិភ័យធ្ងន់ធ្ងរដល់ជីជាតិដី ការប្រមូលផ្តុំនៃឧស្ម័នកាបូនឌីអុកស៊ីតក្នុងបរិយាកាស និងស្ថេរភាពនៃអាងស្តុកផ្ទៃរងទឹកភ្លៀង។ ការកាប់បំផ្លាញព្រៃឈើនឹងធ្វើឱ្យប្រទេសកម្ពុជាកាន់តែងាយរងគ្រោះខ្ពស់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការកើនឡើងនៃទឹកជំនន់ និងគ្រោះរាំងស្ងួត។ នៅពេលដែលរដូវវស្សាមានការផ្លាស់ប្តូរ ហើយការប្រមើលពីបរិមាណទឹកភ្លៀងបានតិចតួច នោះជីវភាពរស់នៅរបស់ប្រជាជនដែលបានមកពីការដាំដុះស្រូវ នេសាទ និងកសិកម្មនឹងត្រូវបានគំរាមកំហែង។[7]

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់សារៈសំខាន់នៃធនធានធម្មជាតិ និងជីវចម្រុះរបស់ប្រទេស។ តួនាទីរបស់រដ្ឋាភិបាលក្នុងការការពារបរិស្ថាន និងធនធានធម្មជាតិត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាដែលចែងអំពីការទទួលខុសត្រូវក្នុងការបង្កើតផែនការគ្រប់គ្រងច្បាស់លាស់ក្នុងការថែរក្សាដី ទឹក ខ្យល់ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូង ព្រៃឈើនឹងអនុផលព្រៃឈើ សត្វព្រៃ ត្រី និងធនធានជលផល។

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្នយើងឃើញថាការ អភិវឌ្ឍវិស័យសំណង់ ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍លើវិស័យផ្សេងទៀតកំពុងតែបានកើនឡើងជាបន្តបន្ទាប់ជាច្រើន ជាមួយនេះគ្នានេះផងដែរបញ្ហាបរិស្ថានក៏ត្រូវបានលើកឡើងដូចគ្នា ពីព្រោះដោយមូលហេតុថាកាលណាមានការសាងសង់ ក៏ដូចជាការបំលែងសកម្មភាពមួយជាសកម្មភាពមួយនោះគឺ តែងតែមានផលប៉ះពាល់ដល់បរិស្ថានជានិច្ច ប៉ុន្តែទោះបីជាយ៉ាងណា

[7] គេហទំព័រ ៖ https://opendevelopmentcambodia.net/km/topics/environment-and-natural-resources-policy-and-administration/#ref-78576-4 ដកស្រង់ថ្ងៃទី២៦ មីនា ២០២២

ក៏ដោយសកម្មភាពនៃការបង្កើតថ្មី ឬជាការពង្រីកទីក្រុងគឺវាមានផលប៉ះពាល់ជាច្រើន ទៅលើផលប៉ះពាល់ដល់បរិស្ថានដូចជា ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដី និងការបំពុលផ្សេងៗទៀត។ [8]

### ១.៣.១. ការគ្រប់គ្រងធនធានធម្មជាតិ

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទ៍ ដីធ្លី ទឹក អាកាស ខ្យល់ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាតនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើនិងអនុផល ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិវឌ្ឍន៍និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តភាពនឹងភាពស្ថិតស្ថេរ។[9] ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ និងផ្តល់យោបល់ជូនក្រសួងពាក់ព័ន្ធ ដើម្បីធានាឱ្យធនធានធម្មជាតិត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។[10]

ក្រសួងបរិស្ថានត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងពាក់ព័ន្ធ នៅពេលណាដែលក្រសួងបរិស្ថានពិនិត្យឃើញថាធនធានធម្មជាតិមិនមានការអភិរក្ស ការអភិវឌ្ឍ ឬការគ្រប់គ្រងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តភាពស្ថិតស្ថេរនោះទេ។[11] នៅក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៥ ស្តីពី សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ រៀបចំដោយក្រសួងបរិស្ថាន បានធ្វើបទបង្ហាញពីបទបញ្ញត្តិសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ។

ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ គឺជាផ្នែកមួយសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវនិរន្តរភាពបរិស្ថាន និងលើកកម្ពស់ជីវភាពប្រជាសហគមន៍។ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនេះ គឺទាមទារឱ្យមានការចូលរួមពីគ្រប់មូលដ្ឋាន និងត្រួតពិនិត្យវាយតម្លៃរាល់សកម្មភាពនានាដែលមានការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងការបង្កើតសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ សំដៅធ្វើយ៉ាងណាឱ្យធានាបាននូវការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ។

ទន្ទឹមនេះ ការគ្រប់គ្រងទេសចរណ៍ធម្មជាតិ គឺសំដៅដល់ការគ្រប់គ្រងតំបន់ដែលមានសក្តានុពលវិស័យបរិស្ថាន ធ្វើយ៉ាងណា ដែលការអនុវត្តមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានធម្មជាតិ និងបង្វែមកកៀរធនធានសម្រាប់បម្រើឱ្យសកម្មភាពអភិរក្សវិញ។ គួសបញ្ជាក់ដែរថា ទាំងនេះ ជាទិសដៅជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាព

[8] មាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[9] មាត្រាទី៨ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី២៤ ធ្នូ ឆ្នាំ១៩៩៦

[10] មាត្រាទី៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី២៤ ធ្នូ ឆ្នាំ១៩៩៦

[11] មាត្រាទី១១ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី២៤ ធ្នូ ឆ្នាំ១៩៩៦

នៃបរិស្ថាននៅកម្ពុជាតាមរយៈការការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ និងការពារបេតិកភណ្ឌវប្បធម៌នៅក្នុងតំបន់ការពារធម្មជាតិ។[12]

### **១.៣.២. កិច្ចការពារបរិស្ថាន**

ការទប់ស្កាត់ ការកាត់បន្ថយនឹងការត្រួតពិនិត្យការបំពុលអាកាស ទឹក ដី ការរំខានដោយសំឡេង និងរំញ័រ ព្រមទាំងសំណល់ សារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើររបស់ក្រសួងបរិស្ថាន។[13] ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួននៅក្នុងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ អាចចូលធ្វើអធិការកិច្ចក្នុងតំបន់ ទីក្នុងបរិវេណ អគារ ឬក្នុងមធ្យោបាយដឹកជញ្ជូន ឬទីកន្លែងណាមួយ។ល។ ក្នុងករណីដែលក្រសួងបរិស្ថានពិនិត្យឃើញថាប្រភពនោះធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពបរិស្ថាន ៖

- មន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថាន និងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅមុនពេលធ្វើអធិការកិច្ច។
- នៅពេលធ្វើអធិការកិច្ច កាលណាពិនិត្យឃើញថាមានបទល្មើសព្រហ្មទណ្ឌកើតឡើង នោះមន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់។
- នីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងបរិស្ថាន។[14]

[12] គេហទំព័រក្រសួងបរិស្ថាន https://www.moe.gov.kh/index/3321 ដកស្រង់ថ្ងៃទី២៦ មីនា ២០២២

[13] មាត្រាទី១៣ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី២៤ ធ្នូ ឆ្នាំ១៩៩៦

[14] មាត្រាទី១៥ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី២៤ ធ្នូ ឆ្នាំ១៩៩៦

# ជំពូកទី២

# ការបំពុលបរិស្ថានទាំង៥ ផលប៉ះពាល់ និងដំណោះស្រាយ

# ជំពូកទី២

# ការបំពុលបរិស្ថានទាំង៥ ផលប៉ះពាល់ និងដំណោះស្រាយ

## ២.១. មូលហេតុនៃការបំពុលទាំង៥

### ២.១.១. មូលហេតុនៃការបំពុលទឹក

ទឹក ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាមនុស្ស និងបរិស្ថានឱ្យមានសុខភាពល្អ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី។ ការបំពុលទឹកភាគច្រើន គឺបណ្តាលមកពីសំណល់ពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះ ដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វ ក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។[15]

- កត្តាមនុស្ស
  - **ការបង្ហូរទឹកកខ្វក់** ៖ មិនត្រឹមតែការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រ សហគ្រាស ដែលជាប្រភពនាំឱ្យមានការបំពុលទឹកនោះទេ ប៉ុន្តែក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងក៏ចូលរួមចំណែក ក្នុងការបំពុលទឹកដោយប្រយោលផងដែរ។ ទឹកកខ្វក់ទាំងនោះកើតឡើងពីការប្រើប្រាស់របស់យើងដូចជាការបញ្ចេញទឹកកខ្វក់ពីបន្ទប់ទឹក ផ្ទះបាយ ដែលទឹកកខ្វក់ទាំងនោះត្រូវបានបង្ហូរចូលទៅក្នុងប្រភពទឹក ដូចជា បឹងបួរ ត្រពាំង ព្រែក ស្ទឹង ទន្លេ។ ការបង្ហូរទឹកកខ្វក់ចូលទៅក្នុងប្រភពទឹកគឺជាការបំពុលដែលនាំឱ្យមានផលប៉ះពាល់ខ្លាំង ជាពិសេសនៅក្នុងរដូវប្រាំង ព្រោះរដូវប្រាំងប្រភពទឹករាក់ ដូចនេះនៅពេលដែលមានការបង្ហូរទឹកកខ្វក់ចូលទៅ នោះនាំឱ្យបរិមាណប្រភពមិនគ្រប់គ្រាន់ក្នុងការបន្សាបទឹកកខ្វក់ ដែលហូរចូលជាហេតុនាំឱ្យការបំពុលទឹកមានការប៉ះពាល់ខ្លាំងដល់សុខភាពប្រជាជន។ ជាពិសេសបងប្អូន ដែលរស់នៅតាមដងទន្លេសាប ដែលពួកគាត់បន្ទូរបង់នៅក្នុងទឹក រួចយកទឹកទន្លេនោះមកប្រើប្រាស់ដែលជាហេតុនាំឱ្យមានការបំពុលទឹកដោយផ្ទាល់។
  - **ការចោលសំរាមទៅក្នុងទឹក ៖** ការបោះចោលសំរាមនៅតាមទីសាធារណៈ ពីសំណាក់ពលរដ្ឋកម្ពុជាមិនមែនជារឿងថ្មីឬប្លែកទេ។ ប្រជាពលរដ្ឋកម្ពុជាបោះចោលសំរាមយ៉ាងអនាធិបតេយ្យយ៉ាងដូច្នេះតាំងពីយូរមកហើយ នៅគ្រប់ទីកន្លែង រាប់តាំងពីនៅមុខផ្ទះ តាមចិញ្ចើមផ្លូវ និងនៅតាមទីសាធារណៈនានា ជាពិសេសការបោះចោលទៅក្នុងប្រភពទឹក។ មានមតិមួយចំនួនមើលឃើញថា កាលដែលប្រជាពលរដ្ឋនិយមបោះចោលសំរាមពាសវាលពាសកាល មិនដាក់ចូលក្នុងធុងសំរាម គឺបណ្តាលមកពីទម្លាប់ និងខ្លះទៀតគិតថាសំរាមគឺមិនសូវមានការប៉ះពាល់ដល់ការបំពុលទឹកប៉ុន្មានទេ។ នៅពេលដែលសំរាមទាំងនោះធ្លាក់ចូលទៅក្នុងប្រភពទឹក គឺជាបញ្ហាធំដែលបង្កឱ្យកើតជាបាក់តេរី

[15] គេហទំព័រ ៖ https://opendevelopmentcambodia.net/km/topics/water-pollution/ ដកស្រង់ថ្ងៃទី២៧ មីនា ២០២២

និងសារជាតិពុលយ៉ាងខ្លាំងដល់សុខភាពអ្នកដែលបានប្រើប្រាស់។ សកម្មភាពទាំងអស់នេះហើយ ដែលធ្វើឱ្យទឹកមានការបំពុល ដល់ជីវៈជំរុះគ្រប់ប្រភេទ ទាំងនៅក្នុងទឹក ទាំងមនុស្ស និងសោភ័ណ្ឌភាពទីក្រុងផងដែល។[16]

- **ការបូមខ្សាច់ ៖** ការកើនទ្បើងនូវកំណើនប្រជាជនជារៀងរាល់ថ្ងៃ ដែលធ្វើឱ្យមានតម្រូវការចាំបាច់ជាច្រើនក្នុងការសាងសង់ផ្ទះ ឬអគារផ្សេងៗ ដែលត្រូវការខ្សាច់ជាចាំបាច់ ហេតុដូចនេះហើយទើបយើងត្រូវការខ្សាច់ដើម្បីសាងសង់ ក្នុងនោះផងដែល ការបូមខ្សាច់យើងត្រូវការឧបករណ៍មានស្តងដារ និងបច្ចេកទេសខ្ពស់ផងដែរ។ ការបូមខ្សាច់ខុសបច្ចេកទេសនេះហើយ ដែលជាហេតុធ្វើឱ្យមានការបំពុលទឹកដល់ជីវៈជំរុះផងដែល។
- **ជាតិពុលដែលចេញពីកប៉ាល ទូក និងនាវាផ្សេងៗ ៖** មិនថានៅក្នុងវិស័យណាមួយឡើយ ការប្រើប្រាស់កប៉ាល់ ទូក និងនាវាផ្សេងៗ ដែលជាមធ្យោបាយក្នុងការធ្វើដំណើរនៅលើប្រភពទឹក គឺសុទ្ធសឹងតែប្រើប្រាស់នូវប្រេងមាស៊ីន សាំង ម៉ាសូតផ្សេងៗ ដែលវាហូរចូលទៅក្នុងប្រភពទឹកតាមរយៈកប៉ាល់ ទូក និងនាវាផ្សេងៗ ដែលនាំឱ្យមានការបំពុលទឹកយ៉ាងខ្លាំង។

❖ កត្តាធម្មជាតិ

យើងដឹងហើយថា កត្តាអាកាសធាតុក៏ចូលរួមចំណែកក្នុងការបំពុលទឹក តាមរយៈកត្តាធម្មជាតិផងដែរ។ គ្រោះមហន្តរាយធម្មជាតិដែលកើតឡើងជាទូទៅ រួមមានទឹកជំនន់ ភ្លៀងអាស៊ីត និងខ្យល់ព្យុះ/ព្យុះទីហ្វុង។

- **ភ្លៀងអាស៊ីត** ៖ ភ្លៀងជាធម្មតាតែងតែមានកម្រិតជាតិអាស៊ីតតិចតួច ពីព្រោះតែវត្តមានរបស់ឧស្ម័នការបូនឌីអ៊ុកស៊ីត ($CO_2$) នៅក្នុងបរិយាកាស។ កម្រិតអាស៊ីតនេះនឹងត្រូវកើនឡើងគួរឱ្យកត់សំគាល់នៅពេលដែលបរិមាណនៃឧស្ម័នស្ពាន់ធ័រ (Sulfur) និងឧស្ម័នអាស៊ូតអ៊ុកស៊ីត (Nitrogen Oxide) បានបន្ថែមចូលទៅក្នុងបរិយាកាសដោយសារការដុតឥន្ធនៈហ្វូស៊ីល (Fossil Fuel)។ បរិមាណនៃឧស្ម័នទាំងនេះដែលភាយចូលទៅក្នុងបរិយាកាសតាមរយៈការដុតឥន្ធនៈហ្វូស៊ីល វាច្រើនជាងអ្វីដែលមានបំភាយដោយកត្តាធម្មជាតិ។ ខ្យល់បានបក់នាំនូវសារធាតុគ្រោះថ្នាក់ទាំងនេះ ដែលជាដើមចមនៃភ្លៀងអាស៊ីតនេះទៅគ្រប់ទីកន្លែង ពីកន្លែងដែលវាបានបំភាយ និងបានធ្វើឱ្យខូតខាតប្រព័ន្ធអេកូឡូស៊ី និងសំណង់អគារជាដើម។ ភ្លៀងអាស៊ីតបានហូរច្រោះចូលគ្រប់ទីកន្លែងស្តុកទឹកដូចជា ស្ទឹង ព្រែក ទន្លេ បឹងបួ ដែលជាប្រភពទឹកយ៉ាងសំខាន់សម្រាប់ជីវៈជំរុះគ្រប់ប្រភេទព្រមទាំងជីវភាពរបស់មនុស្សផងដែរ។[17]

[16] គេហទំព័រ ៖ https://www.rfi.fr/km/cambodia/rubbish-11-04-2016 ដកស្រង់ថ្ងៃទី២៧ មីនា ២០២២

[17] គេហទំព័រក្រសួងបរិស្ថាន ៖ https://www.moe.gov.kh/index/1894 ដកស្រង់ថ្ងៃទី២៧ មីនា ២០២២

➢ **ទឹកជំនន់** ៖ ទឹកជំនន់គឺជាគ្រោះធម្មជាតិដែលអាចនឹងកើតឡើងតាមរយៈការប្រែប្រួលអាកាសធាតុ គួបផ្សំនឹងការអភិវឌ្ឍទីក្រុងបានបណ្តាលឱ្យមានការកើនឡើងនូវគ្រោះទឹកជំនន់។ ទឹកជំនន់បាននាំមកនូវដីល្បាប់ ដីខ្សាច់ ហូរមកចាក់ចូលស្ទឹង ព្រែក ទន្លេ បឹងបួរ ធ្វើឱ្យមានការបំពុលទឹក។

## ២.១.២. មូលហេតុនៃការបំពុលខ្យល់

ការបំពុលខ្យល់គឺជាការបង្កើតឡើងដោយសារធាតុគីមី ឬជីវៈសរីរាង្គដែលបំផ្លាញ ឬបណ្តាលឱ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ បរិយាកាសគឺជាប្រព័ន្ធឧស្ម័នធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានា នៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូនគឺជាការបំផ្លាញរនាំងការពារផែនដីពីកាំរស្មីអ៊ុលតាវីយ៉ូលេដែលបង្កផលវិបាកដល់ជីវិតនៅលើផែនដី។ សរុបមកវិញការបំពុលខ្យល់ត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់មនុស្ស និងឋានប្រព័ន្ធនានា នៅលើផែនដី។ សារធាតុនៅក្នុងខ្យល់ ដែលអាចបង្កឱ្យមានអន្តរាយដល់មនុស្ស និងបរិស្ថាន ហៅថាខ្យល់ពុល។ ការបំពុលទាំងនោះអាចជាកំទេច ធូលី ដំណក់វត្ថុរាវ ឬឧស្ម័នមួយចំនួន។[18]

ខ្យល់ត្រូវបានបំពុលនៅពេលវាប៉ះពាល់នឹងភាពកខ្វក់នៃឧស្ម័នពុល និងភាគល្អិតតូចៗ។ ការបំពុលខ្យល់ភាគច្រើនត្រូវបានបង្កឡើងដោយការដុតឥន្ធនៈហ្វូស៊ីល (ប្រេង ធ្យូង ម៉ាស៊ូត សាំង) ដើម្បីដំណើរការម៉ាស៊ីនរោងចក្រ និងរោងចក្រថាមពល។ ខ្យល់នឹងភ្លៀងអាចនាំយកការបំពុលខ្យល់ទៅកាន់កន្លែងឆ្ងាយៗពីកន្លែងដែលវាកើតឡើង។ បែបនេះបណ្តាលឱ្យមានបញ្ហាសុខភាពដល់ប្រជាជននៅគ្រប់ទីកន្លែង។ ជាទូទៅការបំពុលខ្យល់មានសភាពធ្ងន់ធ្ងរនៅក្នុងទីក្រុង តំបន់ឧស្សាហកម្ម តំបន់ទំនាបឬតំបន់ដែលឡោមព័ទ្ធដោយភ្នំ និងកន្លែងដែលមានខ្យល់បក់មិនបានល្អ។[19]

❖ **ផ្សែងពុលចេញពីយានជំនិះគ្រប់ប្រភេទ** ៖ ការកកស្ទះចរាចរណ៍ ជាបញ្ហាមួយនៅក្នុងក្រុង ហើយពេលកកស្ទះនេះ យានយន្តជាច្រើន បានបញ្ចេញផ្សែងពុល ដែលជាចំហេះនៃប្រេងឥន្ធនៈ និងឧស្ម័នកាន់តែច្រើន។ យានយន្ត និងម៉ាស៊ីនផ្សេងៗទៀត ដែលដំណើរការដោយប្រេងឥន្ធនៈ និងឧស្ម័ន បានបញ្ចេញកាបូនខ្មៅ រួមជាមួយនឹងភាគល្អិតផ្សេងៗទៀត ទៅក្នុងបរិយាកាស។[20] បច្ចុប្បន្នចំនួនប្រជាជនកើនឡើងច្រើន ដូច្នេះហើយធ្វើឱ្យមានតម្រូវការយានយន្តកាន់តែកើនឡើងច្រើន ដែលជាហេតុនាំឱ្យមានការបំពុលពាសពេញបរិយាកាសដោយសារតែផ្សែងពុលដែលចេញមកពីយានយន្តទាំងអស់នោះមានកម្រិតខ្ពស់។

---

[18] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ ២០១៣

[19] គេហទំព័រ ៖ https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health ការបំពុលខ្យល់ ដកស្រង់ថ្ងៃទី៣០ មីនា ២០២២

[20] គេហទំព័រ ៖ https://khmernote.com.kh/news/60954 ដកស្រង់ថ្ងៃទី៣០ មីនា ២០២២

ម្យ៉ាងវិញទៀតគេសង្កេតឃើញថា ការប្រើប្រាស់យានយន្តចាស់ៗ វាប៉ះពាល់ខ្លាំងទៅក្នុងបរិយាកាស ពីព្រោះការប្រើប្រាស់យានយន្តចាស់ៗ វាបញ្ចេញផ្សែងពុលទៅក្នុងបរិយាកាសច្រើនជាង យានយន្តថ្មីៗ។

- **ផ្សែងពុលចេញពីឈាបនដ្ឋាន** ៖ នៅក្នុងលោកយើងនេះ ជាតិសាសនាណាក៏ដោយសុទ្ធតែមានជំនឿ ទំនៀមទំលាប់ ប្រពៃណីប្រចាំជាតិសាសន៍រៀងៗខ្លួនដែរ។ យើងក៏បានដឹងថានៅក្នុងប្រទេសកម្ពុជា យើងគោរពសាសនាព្រះពុទ្ធសាសនាជាគោលដែរជាសាសនារបស់រដ្ឋ រួមទៅនឹងវប្បធម៌ ប្រពៃណីយើង ពីបុរាណកាលមក កាលណាដែលមានមនុស្សស្លាប់ គេតែងតែយកទៅកប់ ឬក៏បូជា។ ប៉ុន្តែសព្វថ្ងៃនេះ គេពុំសូវយកទៅកប់ទេ ដោយខ្វះដីកប់ផង ហើយដោយទំនៀមទំលាប់ប្រែប្រួល គេយកសពមនុស្ស ដែលបានស្លាប់យកទៅបូជាវិញ។[21] ជាទូទៅការបូជាសពប្រព្រឹត្តទៅតាមទីវត្តអារាមដែលជាទីតាំងប្រារព្ធ ពិធីសាសនាផ្សេងៗ ជាហេតុដែលបណ្តាលឱ្យមានផ្សែងបំពុលដែលចេញមកពីការបូជាសពនោះ វាធ្វើឱ្យប៉ះពាល់ដល់បរិស្ថានយ៉ាងខ្លាំង និងធ្វើឱ្យមានការបំពុលខ្យល់យ៉ាងធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋដែលរស់ នៅតំបន់ជិតវត្តអារាម។ យើងបានដឹងហើយថា ប្រទេសកម្ពុជាយើងបានឆ្លងនៅជម្ងឺដ៏កាចសាហាវមួយ រួចមកហើយនៅចុងឆ្នាំ២០១៩ ដែលមានឈ្មោះថា កូរូណា វីរុស ( Corona Virus ) ឬកូវីត១៩ (COVID-19) ជម្ងឺក៏កាចសាហាវនេះហើយ ដែលធ្វើឱ្យមានប្រជាជនស្លាប់យ៉ាងច្រើន នៅដើមឆ្នាំ ២០២១ រាជរដ្ឋាភិបាលកម្ពុជាលោកបានកសាងកន្លែងបូជាសពអ្នកដែលបានស្លាប់ដោយសារជម្ងឺ កូវីត ១៩ (COVID-19) លើផ្ទៃដីប្រមាណ ១០ ហិកតានៅស្រុកឱរ៉ាល់។[22]
- **ការបំពុលដោយធូលី** ៖ ធូលី ក៏ជាបញ្ហាមួយដែលបណ្តាលឱ្យមានការបំពុលខ្យល់ដែលគួរឱ្យកត់ សំគាល់ផងដែរ។ ភាគច្រើនវាបណ្តាលមកការហុយធូលីមកពីយានយន្តដែលកំពុងធ្វើចរាចរណ៍នៅលើ ដងផ្លូវ ការបោសសំរាម ឬធូលីតាមទីសាធារណៈ ការសាងសង់ផ្ទះ ឬអគារនានា ការរៀបចំ ឬគ្រប់គ្រង គ្រឿងសំណង់ផ្សេងៗនៅពេលដឹកជញ្ជូនមិនបានត្រឹមត្រូវដូចជា ការដឹកខ្សាច់ ដី ស៊ីម៉ង់ជាដើម។ ហើយ ការដែលធ្វើឱ្យធ្លាក់ ឬប៉ើងតាមខ្យល់ជាហេតុបង្កឱ្យមានការបំពុលខ្យល់។ ម្យ៉ាងទៀត ការទុកសម្ភារៈ សំណង់មិនបានល្អនៅលើដងផ្លូវក៏ជាហេតុបង្កឱ្យមានការបំពុលទៅពាសពេញបរិយាកាសផងដែរ។

[21] សៀវភៅបុណ្យឈាបនកិច្ច ឬបុណ្យខ្មោច រៀបរៀងដោយ ព្រះគ្រូចៅអធិការ វត្តត្រពាំងធំ ខេត្តកំពង់ស្ពឺ

[22] គេហទំព័រ ៖ https://www.rfi.fr/km/កម្ពុជា/20210312-កម្ពុជា-សង្គម-កូវីដ១៩-រដ្ឋបាលរាជធានីភ្នំពេញ ដកស្រង់ថ្ងៃទី៣០ មីនា ២០២២

### ២.១.៣. មូលហេតុនៃការបំពុលសំឡេង

ការបំពុលសំឡេង គឺជាការបំពុលមួយដែលបញ្ចេញសំឡេងរំខានពាសពេញទីក្រុង ដោយប្រមូលផ្ដុំដោយ សំឡេង ចរាចរណ៍នានា តាមបណ្ដោយផ្លូវសាធារណៈ សំឡេងយន្តហោះ សំឡេងរថភ្លើង សំឡេងតន្ត្រី សំឡេងដែលចេញមកពីរោងចក្រ សហគ្រាស សិប្បកម្មជាច្រើនទៀត ឧបករណ៍បំពងសំឡេងនានា និងការសាងសង់អគារផ្សេងៗ ព្រមទាំងការអភិវឌ្ឍន៍ទីក្រុងផងដែរ រួមមាន ការសាងសង់ផ្លូវ ការសាងសងស្ពាន និងការឆ្ការព្រៃឈើជាដែរ។ល។ ដោយយោងទៅតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក, ស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយ សំឡេង ចុះនៅថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០០០ បានបង្ហាញថាមូលហេតុដែលនាំឱ្យមានការបំពុលដោយសំឡេងគឺមកពីរប្រភេពធំៗចំនួន ២ គឺ ៖

- **ប្រភពចល័ត** ៖ ការបំពុលសំឡេងដោយប្រភពចល័ត គឺសំដៅដល់ការបំពុលដោយសំឡេងដែលជាប្រភពដែលស្ថិតនៅទីតាំងមិនអចន្ត្រៃយ៍ជាអាទិ៍មាន យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត ឧបករណ៏ឃោសនស័ព្ទផ្សេងៗ បំពង់ស៊ីមាំងដែលកែច្នៃខុសបច្ចេកទេស និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។ ដោយសារតែកំណើតប្រជាជនកើនឡើង ធ្វើឱ្យមានតម្រូវការយានយន្តដែលធ្វើដំណើរតាមទីសាធារណៈកើនឡើងដូចគ្នា ទាំងនេះហើយដែលនាំឱ្យការបំពុលសំឡេងដោយប្រភពចល័តកើនឡើងដែរ។
- **ប្រភពអចល័ត** ៖ ការបំពុលសំឡេងដោយប្រភពអចល័ត សំដៅទៅលើការបំពុលដោយសំឡេងដែលស្ថិតនៅទីតាំងអចន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ កន្លែងកំសាន្ត ក្លឹបកំសាន្ត ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។[23]

### ២.១.៤. មូលហេតុនៃការបំពុលដី

ការបំពុលដីគឺជាការបំប្លែងផ្ទៃដីដែលបង្កឡើងដោយវត្តមានរបស់វត្ថុធាតុកខ្វក់ ឬរាវ ឬសារធាតុបំពុលដែលបង្កើតឱ្យមានការខ្សោះជីវជាតិទូទៅនៃផ្ទៃ ឬការពាក់មុខងារមួយ ឬច្រើនរបស់វា។[24] ដីជាប្រភពអាហារសំខាន់ដែលផ្ដល់ធនធានស្ទើរងដល់ទៅ ៩៥-៩៧% សម្រាប់ប្រជាជនពិភពលោក។ ផ្ទៃដីនៃធនធានដីរបស់ពិភពលោកគឺ១២៩ លានគីឡូម៉ែត្រការ៉េ ឬ៨៦.៥% នៃផ្ទៃដី។ ដីបង្កបង្កើនផល និងចម្ការដែលមានអាយុច្រើនឆ្នាំជាផ្នែកនៃដីកសិកម្មកាន់កាប់ប្រហែល 10% នៃដីវាលស្មៅ និងវាលស្មៅ -25% នៃផ្ទៃដី។[25] ប្រភពដែលបណ្ដាលឱ្យមានការការបំពុលដីមានដូចជា ៖

---

[23] មាត្រា៣ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

[24] គេហទំព័រ ៖ https://www.postposmo.com/km/contaminacion-del-suelo/#Contaminacion_del_Suelo ដកស្រង់ថ្ងៃទី០៣ មេសា ២០២២

[25] គេហទំព័រ ៖ https://studyboom.ru/km/zagryaznenie-i-istoshchenie-pochvy-prichiny-problemy-zagryazneniya-pochv-i-puti-ih/ ដកស្រង់ថ្ងៃទី០៣ មេសា ២០២២

- **សកម្មភាពកសិកម្ម** ៖ មូលហេតុដែលបណ្តាលឱ្យមានការបំពុលដីក្នុងសកម្មភាពកសិកម្មនេះបណ្តាលមកពី បងប្អូនប្រជាពលរដ្ឋ ប្រជាកសិករយើងប្រើប្រាស់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ ដូចជាការប្រើប្រាស់ជីគីមី ឬការបាញ់ថ្នាំសម្លាប់សត្វល្អិត ទៅក្នុងស្រែ ស្រូវ ផលដំណាំរបស់ពួកគាត់ ដោយសារតែជីគីមី ឬថ្នាំសម្លាប់សត្វល្អិតនេះមានផ្ទុកសារធាតុគីមី ជាតិពុលខ្លាំង ក្នុងរយៈពេលយូរ ដូច្នេះហើយមិនថាការប្រើប្រាស់ជីគីមី ឬការបាញ់ថ្នាំសម្លាប់សត្វល្អិត គឺធ្វើឱ្យដីមានជាតិពុល និងធ្វើឱ្យដីខូចគុណភាពទៅជារីង អស់ជីជាតិ ដែលបណ្តាលឱ្យផលដំណាំរបស់ពួកគាត់មិនសូវទទួលបានផលល្អដូចមុនទេ។
- **សំរាម** ៖ សំរាមក៏ជាបញ្ហាមួយដែលបង្កឱ្យមានការបំពុលដីផងដែរ។ ការវែកញែកសំរាមទៅតាមប្រភេទនៃសំរាមនីមួយៗឱ្យបានត្រឹមត្រូវ ឬការទុកដាក់សំរាមមិនបានត្រឹមត្រូវពាសពេញទីសាធារណៈ។ មិនថាសំរាមដែលគេទុកចោលគរលើគ្នាជាច្រើន ឬសំរាមដែលគេបានដឹកជញ្ជូនទៅទីលានចាក់សំរាមក៏ដោយ វាបានបញ្ចេញសារធាតុដែលផ្ទុកនៅក្នុងសំរាមនោះហូរចូលទៅក្នុងដី ដែលធ្វើឱ្យដីនៅតំបន់នោះមានសារធាតុពុលសម្បូរទៅដោយមេរោគ និងបាក់តេរីគ្រប់ប្រភេទដែលវាជាហេតុដែលបង្កឱ្យមានការបំពុលដី។
- **សំណល់ដែលចេញពីឧស្សាហកម្ម រោងចក្រ សហគ្រាស** ៖ ការបំពុលដោយឧស្សាហកម្ម រោងចក្រ និងសហគ្រាសនេះគឺបណ្តាលមកការហូរច្រោះនូវទឹកស្អុយ ឬទឹកដែលមានសារធាតុពុលចេញពីការផលិត ការកែច្នៃផ្សេងៗ ដែលឧស្សាហកម្ម រោងចក្រទាំងអស់នោះបង្ហូរចេញមកតាមប្រព័ន្ធលូដែលបណ្តាលឱ្យមានការបំពុលដីនៅតាមតំបន់នោះ។ សកម្មភាពឧស្សាហកម្មគឺជាអ្នករួមចំណែកដ៏ធំបំផុតចំពោះបញ្ហានៅក្នុងសតវត្សចុងក្រោយនេះ ជាពិសេសចាប់តាំងពីបរិមាណនៃការជីកយករ៉ែ និងការផលិតបានកើនឡើង។ ឧស្សាហកម្មភាគច្រើនពឹងផ្អែកលើការទាញយករ៉ែពីផែនដី។[26]

## ២.១.៥. មូលហេតុនៃការបំពុលសំណល់រឹង រាវ

ការបំពុលដោយសំណល់រឹង រាវគឺជាការបំពុលបរិស្ថានមួយដែលជះឥទ្ធិពលមកលើផែនដីយើងសព្វថ្ងៃនេះ ដែលបណ្តាលមកពីការមនុស្សមិនបានរៀបចំ ឬបែងចែកសំណល់រឹង ឬសំណល់រាវឱ្យបានត្រឹមត្រូវ ជាហេតុនាំឱ្យមានការបំពុលដល់បរិស្ថាន។ សព្វថ្ងៃនេះ សំណល់ដែលចេញមកពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីដ្ឋាន កន្លែងកម្សាន្ត មិនថាសំណល់រឹង ឬរាវទេ វាបង្កគ្រោះថ្នាក់ដល់ភាវៈរស់ទាំងអស់មិនថា មនុស្ស សត្វ ឬរុក្ខជាតិ តែងតែទទួលរងនូវឥទ្ធិពលពីប្រភពបំពុលសំណល់នេះ។

- **សំណល់រឹង** ៖ គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបង់បោះបង់។

[26] គេហទំព័រ https://www.conserve-energy-future.com/causes-and-effects-of-soil-pollution.php ដកស្រង់ថ្ងៃទី០៣ មេសា ២០២២

- **សំរាម** ៖ គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកម្សាន្ត។ល។
- **សំណល់ប្រកបដោយគ្រោះថ្នាក់** ៖ គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជម្ងឺមហារីក ចម្លងជម្ងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មផ្សេងៗ។ល។ [27]

❖ **សំណល់រាវ** ៖ គឺសំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថាន ដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[28] ឬម្យ៉ាងទៀតសំណល់រាវ គឺជាវត្ថុរាវ ដែលជាផលិតផល និងជាសារធាតុរួមផ្សំ ជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅតាមបណ្ដាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ។[29] សំណល់រាវនេះត្រូវបានបែងចែកចេញជាពីរប្រភពគឺ ប្រភពបំពុលរាយប៉ាយ និងប្រពភបំពុលចំណុច។

- **ប្រភពបំពុលរាយប៉ាយ** ៖ គឺជាប្រភពដែលបង្ករឱ្យមានការបំពុលដោយសារ សារធាតុបំពុលពីដីច្រើនកន្លែងដូចជា លំហូរកសិកម្ម សំណល់ចេញពីលំនៅដ្ឋាន សំណល់អាជីវកម្មរ៉ែ និងកំទេចកំទីពីការដ្ឋានសំណង់ជាដើម ហើយសំណល់ទាំងនេះហូរធ្លាក់ចូលទៅក្នុងទឹកលើផ្ទៃដីនៃតំបន់ដ៏ធំមួយ ហើយមិនងាយស្រួលក្នុងការត្រួតពិនិត្យ វាអាស្រ័យទៅលើការយល់ដឹងរបស់បុគ្គល គ្រួសារ និងសហគមន៍។
- **ប្រភពបំពុលចំណុច** ៖ គឺជាប្រពភដែលចេញពីកន្លែងច្បាស់លាស់តាមរយៈបំពង់បង្ហូរ ឬប្រឡាយទីតាំងឧស្សាហកម្ម រោងចក្រ និងបំពង់បង្ហូរទឹកលូសំអុយ ហើយងាយស្រួលក្នុងការត្រួតពិនិត្យ និងធ្វើប្រត្តិកម្មសំអាតទឹកឡើងវិញ។[30]

---

[27] មាត្រា៣ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ស្ដីពីការបំពុលសំណល់រឹង, ចុះនៅថ្ងៃទី២៧ មេសា ១៩៩៩

[28] មាត្រា៤ នៃអនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្ដីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, ចុះនៅថ្ងៃទី២៥ ធ្នូ ២០១៧

[29] គេហទំព័រ ៖ https://seylanote.wordpress.com/?s= សំណល់រាវ ដកស្រង់ថ្ងៃទី០៩ មេសា ២០២២

[30] គេហទំព័រ ៖ https://www.khsearch.com/qna/8874 ដកស្រង់ថ្ងៃទី០៩ មេសា ២០២២

## ២.២. ផលប៉ះពាល់នៃការបំពុលនាំទាំង៥

### ២.២.១. ផលប៉ះពាល់ដោយការបំពុលទឹក

ការបំពុលទឹកគឺជាសកម្មភាពមួយដែលធ្វើឱ្យប្រភពទឹកដូចជា សមុទ្រ ទន្លេ បឹងបួ ស្ទឹង ព្រែក កខ្វក់គ្មានអនាម័យ ហើយភាគច្រើននៃកខ្វក់ទឹកនេះ កើតឡើងដោយមនុស្សតែម្តង នៅពេលដែលគ្មានការតាមដានត្រួតពិនិត្យបានត្រឹមត្រូវ។ ការបំពុលទឹកនេះ ត្រូវបានគេយកចិត្តទុកដាក់ខ្លាំងណាស់នៅលើប្រទេសមួយចំនួនជុំវិញពិភពលោក ព្រោះវាផ្តល់ផលអាក្រក់ដល់សុខភាពរបស់មនុស្ស ក៏ដូចជាជីវិតរស់នៅរបស់សត្វ និងរុក្ខជាតិផងដែរ។[31] នៅពេលដែលមានការបំពុលទឹកកើនឡើង ធ្វើឱ្យភាវៈមានជីវិតទាំងអស់រងនូវការបំពុលដូចជា ៖

- **កង្វះទឹកស្អាតប្រើប្រាស់** ៖ បញ្ហាកង្វះអនាម័យ និងទឹកស្អាត បានធ្វើឱ្យប្រជាជននៅលើពិភពលោក ពិសេសអ្នករស់នៅតំបន់ជនបទជួបប្រទះជម្ងឺជាច្រើនដែលបណ្តាលមកពីការប្រើប្រាស់ប្រភពទឹកកខ្វក់ គ្មានបង្គន់ប្រើប្រាស់ និងមិនមានទម្លាប់លាងដៃជាមួយនឹងសាប៊ូ។ បញ្ហាទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងឈានទៅប៉ះសេដ្ឋកិច្ចជាតិទាំងមូល ប៉ុន្តែប្រជាជនទាំងនោះមិនបានយល់ថាការប៉ះពាល់នេះ វាមានទំហំប៉ុណ្ណានោះទេ។[32] បញ្ហាកង្វះទឹកស្អាត និងអនាម័យសម្រាប់ការបរិភោគ ការចម្អិនម្ហូប ការលាងសម្អាតខ្លួន ការបោកគក់ និងការបំពុលប្រភពទឹក ទាំងអស់នេះហើយគឺជាផលប៉ះពាល់យ៉ាងខ្លាំងដល់បញ្ហាសុខភាពផងដែរ។
  - **ការបរិភោគទឹកមិនស្អាត** ៖ កង្វះទឹកអនាម័យដោយការប្រើប្រាស់ទឹកមិនស្អាត សម្រាប់បរិភោគដោយមិនបានចម្អិនជាមុនឱ្យបានឆ្អិនល្អ វានាំមកនូវបញ្ហាសុខភាពដូចជា ៖ ជម្ងឺរាគរូស អាសន្នរោគ គ្រុនពោះវៀន ជម្ងឺថ្លើម A,E ពពួកព្រូនផ្សេងៗ ដែលតែងតែជួបប្រទះក្នុងជីវភាពរស់នៅតាមជនបទសព្វថ្ងៃ។
  - **ការលាងសម្អាតខ្លួន និងការបោកគក់** ៖ ការប្រើប្រាស់ទឹកមិនស្អាត តាមរយៈការលាងសម្អាតខ្លួន និងការបោកគក់ក៏ជះឥទ្ធិពលមកលើសុខភាពរបស់មនុស្សយើងផងដែរ។ ដែលវាបណ្តាលឱ្យមានជម្ងឺ ៖ សើរស្បែក កមរមាស់។[33]
- **ប្រភពទឹកមានការបំពុល** ៖ ការបំពុលទឹកអាចបំផ្លាញដល់អាយុជីវិតសត្វ និងរុក្ខជាតិ ដែលរស់នៅក្នុងទន្លេ ស្ទឹង បឹងបួ ឬសមុទ្រ ដែលមានការបំពុលទឹក ហើយវាក៏ប៉ះពាល់ដល់ដំណាំ ដែលប្រើប្រាស់ប្រភព

---

[31] គេហទំព័រ ៖ https://cambo-report.com/article/96 ដកស្រង់ថ្ងៃទី១០ មេសា ២០២២

[32] គេហទំព័រ ៖ https://www.lotus-radio.com/22-12-2017-health-pisey-radio-sanitation-and-clean-water-in-rural/ ដកស្រង់ថ្ងៃទី១០ មេសា ២០២២

[33] គេហទំព័រ ៖ https://openjicareport.jica.go.jp/pdf/11689353_08.PDF ដកស្រង់ថ្ងៃទី១០ មេសា ២០២២

ទឹកនោះផងដែលធ្វើឱ្យខូច ឬអាចប៉ះពាល់ដល់អាយុជីវិតសត្វ និងមនុស្ស នៅពេលដែលបរិភោគបន្លែដែលមានជាតិពុលនោះ។[34]

➢ **ប្រភពទឹក ៖** ជាធម្មតាមូសក៏ជាភ្នាក់ងារចម្លងមេរោគមួយផងដែរ។ នៅពេលដែលមានទឹកដក់យូរទៅវាបង្កឱ្យមានជង្ហុកទឹកដែលជាការកកើតរបស់សត្វមូស។ ជម្ងឺដែលអាចឆ្លងតាមរយៈមូសខាំមានដូចជា ៖ ជម្ងឺគ្រុនចាញ់ និងជម្ងឺគ្រុនឈាម។ ដើម្បីជៀសវាងនូវប្រភេទជម្ងឺទាំងនេះបានទាំងស្រុង គួរតែអនុវត្តន៍ទៅតាមក្បួនអនាម័យដូចដែលមានទៅតាមការអប់រំសុខភាពអនាម័យរបស់ក្រសួងសុខាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលបានផ្សព្វផ្សាយតាមរយៈ វិទ្យុ ទូរទស្សន៍ ខិតប័ណ្ណ តាមរូបភាពនានា ដែលទាក់ទងទៅនឹងការអប់រំសុខភាព និងអនាម័យផ្សេងៗទៀត។

### ២.២.២. ផលប៉ះពាល់ដោយការបំពុលខ្យល់

ការបំពុលខ្យល់ក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់បញ្ហាសុខភាពរបស់មនុស្សធ្ងន់ធ្ងរផងដែរ ដូចជាជម្ងឺមហារីក និងជម្ងឺផ្លូវដង្ហើមជាច្រើន ។ ការបំពុលខ្យល់បណ្តាលឱ្យមានភ្លៀងអាស៊ីតដែលបំផ្លាញព្រៃឈើ ប្រភពទឹក និងសំណង់អគារ ក៏ដូចជាសួតរបស់យើងផងដែរ។ ម្យ៉ាងទៀត ការបំពុលខ្យល់គឺជាមូលហេតុចម្បងមួយនៃការឡើងកម្តៅផែនដី។[35] នៅពេលដែលមានការបំពុលខ្យល់កើនឡើង ផែនដីរងនូវផលប៉ះពាល់ដូចជា ៖

❖ **បញ្ហាសុខភាព ៖** មានផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងជាច្រើនដែលការបំពុលបរិយាកាសអាចប៉ះពាល់ដល់សុខភាពមនុស្ស។ ជាការពិតណាស់ការបំពុលខ្យល់ក្នុងទីក្រុង បង្កើនហានិភ័យនៃជម្ងឺផ្លូវដង្ហើមស្រួចស្រាលដូចជា ជម្ងឺរលាកសួត និងរ៉ាំរ៉ៃ ដូចជាមហារីកសួត និងជម្ងឺសរសៃឈាមបេះដូង។ ការបំពុលខ្យល់ប៉ះពាល់ដល់ក្រុមមនុស្សផ្សេងៗគ្នាតាមវិធីផ្សេងៗគ្នា។ ផលប៉ះពាល់ធ្ងន់ធ្ងរបំផុត កើតឡើងចំពោះមនុស្សដែលមានជម្ងឺរួចទៅហើយ។ លើសពីនេះក្រុមដែលងាយរងគ្រោះបំផុតដូចជាកុមារ មនុស្សចាស់ និងក្រុមគ្រួសារដែលមានចំណូលទាបដែលមានសិទ្ធិទទួលបានសេវាថែទាំសុខភាពមានកំរិតងាយទទួលរងផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ពីបាតុភូតនេះ។ ការបំពុលបរិយាកាសមានឥទ្ធិពលផ្ទាល់ទៅលើសុខភាព និងជាពិសេសទៅលើសួត។ វាក៏មានះថ្នាក់ណាស់ចំពោះស្បែកនឹងហាក់ដូចជាបង្កើត ភាពចាស់នៃស្បែក ការខ្វះជាតិទឹកនៃស្បែក ការរីវត្តនៃមុន ការរិចរិលនៃកោសិកា។[36]

---

[34] គេហទំព័រ ៖ https://cambo-report.com/article/96 ដកស្រង់ថ្ងៃទី១០ មេសា ២០២២

[35] គេហទំព័រ ៖ https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health:ការបំពុលខ្យល់ ដកស្រង់ថ្ងៃទី២០ មេសា ២០២២

[36] គេហទំព័រ ៖ https://www.renovablesverdes.com/km/contaminacion-atmosferica/ ដកស្រង់ថ្ងៃទី២០ មេសា ២០២២

- **ឥទ្ធិពលលើសត្វព្រៃ ៖** ដូចមនុស្សដែរ សត្វក៏ប្រឈមនឹងឥទ្ធិពលបំផ្លិចបំផ្លាញនៃការបំពុលបរិយាកាសដែរ។ សារធាតុគីមីពុលដែលមាននៅក្នុងខ្យល់អាចបង្ខំឱ្យសត្វព្រៃផ្លាស់ទីទៅកន្លែងថ្មី និងផ្លាស់ប្តូរទីជម្រករបស់ពួកគេ។ សារធាតុពុលដែលដាក់លើផ្ទៃទឹក ហើយក៏អាចប៉ះពាល់ដល់សត្វសមុទ្រផងដែរ។
- **ការប្រែប្រួលអាកាសធាតុ ៖** ត្រូវបានផ្តល់និយមន័យថា ជាការបកស្រាយយោងទៅតាមស្ថិតិស្តីអំពីលំនាំ អាកាសធាតុដែលមានការប្រែប្រួលក្នុងរយៈពេលវែងមួយ។ ខណៈពេលអាកាសធាតុនៅលើផែនដីបានឆ្លងកាត់អំឡុងពេលនៃការប្រែប្រួល ភ័ស្តុតាងតាមបែបវិទ្យាសាស្ត្រសម័យទំនើបបានបង្ហាញថា ការកើនឡើងនឹងបំរែបំរួលធាតុអាកាសដ៏ឆាប់រហ័ស កំពុងតែកើតមានឡើងនៅទូទាំងពិភពលោក ហើយវាត្រូវបានហៅថា **"ការប្រែប្រួលអាកាសធាតុ"** ដែលជាលទ្ធផលកើតចេញពីសកម្មភាពរបស់មនុស្សទាក់ទងទៅនឹងការធ្វើឧស្សាហូបនីយកម្ម ការកាប់បំផ្លាញព្រៃឈើ និងបម្រែបម្រួលនៃការប្រើប្រាស់ដី។[37] ការផ្លាស់ប្តូរអាកាសធាតុគឺជាបញ្ហាធ្ងន់ធ្ងរបំផុត ហើយជាមួយនឹងសារៈសំខាន់កាន់តែច្រើនដែលមនុស្សជាតិប្រឈមមុខនៅថ្ងៃនេះ។ ចាប់តាំងពីវត្តមាននៃបដិវត្តឧស្សាហកម្មនឹងការដុតឥន្ធនៈផូស៊ីលសម្រាប់ការផលិតថាមពល និងការដឹកជញ្ជូនឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសរួមទាំងឧស្ម័នកាបូនិកបានកើនឡើងគួរឱ្យកត់សម្គាល់។[38] ជាមួយនឹងការកើនឡើងសីតុណ្ហភាពនៅទូទាំងពិភពលោក ការកើនឡើងនៃកម្រិតទឹកសមុទ្រ និងការរលាយនៃទឹកកកពីតំបន់ត្រជាក់ជាង និងផ្ទាំងទឹកកក ការផ្លាស់ទីលំនៅ និងការបាត់បង់ទីជម្រក គឺជាសញ្ញានៃគ្រោះមហន្តរាយដែលនឹងកើតឡើង ប្រសិនបើសកម្មភាពសម្រាប់ការអភិរក្ស និងការធ្វើឱ្យប្រក្រតីឡើងវិញមិនត្រូវបានធ្វើឡើងក្នុងពេលឆាប់ៗនេះ។[39]
- **ការថយចុះនៃស្រទាប់អូហ្សូន ៖** ស្រទាប់អូហ្សូនគឺជាខ្សែក្រវ៉ាត់នៃឧស្ម័នអូហ្សូនធម្មជាតិដែលមានទីតាំងស្ថិតនៅចន្លោះពី ១៥ ទៅ ៣០ គីឡូម៉ែត្រពីលើផែនដីដូចជាវាអញ្ចឹងដែរ ខែលការពារប្រឆាំងនឹងកាំរស្មីអ៊ុលត្រាវីយូដែលបង្កគ្រោះថ្នាក់ បញ្ចេញដោយព្រះអាទិត្យ។ អូហ្សូនគឺជាម៉ូលេគុលដែលមានប្រតិកម្មខ្ពស់ដែលមានអាតូមអុកស៊ីសែនបី។ វាត្រូវបានបង្កើតឡើងឥតឈប់ឈរនៅក្នុងបរិយាកាសខាងលើ ១០ ទៅ ៥០ គីឡូម៉ែត្រពីលើផែនដីក្នុងតំបន់ដែលគេហៅថា ស្រទាប់នៃបរិយាកាសរបស់ផែនដី។ នាពេលបច្ចុប្បន្នមានការព្រួយបារម្ភជាទូទៅថា ស្រទាប់អូហ្សូនកាន់តែយ៉ាប់យ៉ឺន ដោយសារតែការបញ្ចេញការបំពុលដែលផ្ទុកសារធាតុគីមីក្លរីននិងប្រូមូន។ ការខ្សោះជីវជាតិបែបនេះអនុញ្ញាតឱ្យមានកាំរស្មី

[37] របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១, ការកសាងភាពធន់៖ អនាគតរបស់អ្នកជនបទក្នុងការប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ. ក្រសួងបរិស្ថាន និងអង្គការ UNDP កម្ពុជា, ២០១១. https://opendevelopmentcambodia.net/km/topics/climate-change/#ref-74589-1 ដកស្រង់ថ្ងៃទី២០ មេសា ២០២២

[38] គេហទំព័រ ៖ https://www.renovablesverdes.com/km/contaminacion-atmosferica/ ដកស្រង់ថ្ងៃទី២០ មេសា ២០២២

[39] គេហទំព័រ ៖ https://www.conserve-energy-future.com/causes-effects-solutions-of-air-pollution.php ដកស្រង់ថ្ងៃទី២០ មេសា ២០២២

អ៊ុលត្រាវីយូច្រើនដល់ផែនដីដែលអាចបង្កឱ្យមានជម្ងឺមហារីកស្បែក និងជម្ងឺភ្នែកឡើងបាយចំពោះមនុស្សនិងបង្កអន្តរាយដល់សត្វ។[40]

### ២.២.៣. ផលប៉ះពាល់ដោយការបំពុលដោយសំឡេង

សំឡេងត្រូវបាន ក្លាយជាផ្នែកធម្មជាតិមួយ នៃជីវិតប្រចាំថ្ងៃរបស់យើងម្នាក់ៗ។ ប្រភពនៃការ បំពុលដោយសំឡេង មានដូចជា សំឡេងចរាចរណ៍ សំឡេងយន្តហោះ សំឡេងរថភ្លើង សំឡេងតន្ត្រី និងម៉ាស៊ីននៅក្នុងរោងចក្រជាដើម។ កម្រិតនៃការបំពុលដោយសំឡេង ដែលអាចទ្រាំបាន គឺមានកម្រិតដល់ ៤០ដេស៊ីបែល ( 40 decibel)។ គ្រប់ប្រភេទនៃសំឡេង ដែលកើនឡើងលើសពីកម្រិតនេះ គឺអាចបំផ្លាញដល់ សមត្ថភាពនៃការស្តាប់ និងលទ្ធផលសុខភាពរបស់អ្នក។ ខាងក្រោមនេះ គឺជាអំណះអំណាង ដែលបង្ហាញថាការបំពុលដោយសំឡេងគឺពិតជាជះឥទ្ធិពលអាក្រក់ ដល់យើងម្នាក់ៗមែនដូចជា ៖

- **ហ៊ឹងត្រចៀក** ៖ ជាបញ្ហាមួយផ្សេងទៀតដែលបណ្តាលមកពី ការបំពុលដោយសំឡេងនោះគឺការលាន់ស្នូរហ៊ឹងក្នុងត្រចៀក ដែលជាសំឡេងលាន់លឺ ងូងៗនៅក្នុងត្រចៀក។ ដោយសារតែការបំពុលដោយសំឡេង មានមនុស្សជាច្រើន ចាប់ផ្តើមលាន់លឺនៅសំឡេងរំខានបែបនេះនៅក្នុងត្រចៀកគេជានិច្ច។ វាអាចជះ ឥទ្ធិពលអាក្រក់ទៅដល់ប្រព័ន្ធប្រសាទ និងសុខភាពជាទូទៅរបស់អ្នកបាន។
- **មានភាពពិបាកក្នុងការរៀនសូត្រ** ៖ ការបំពុលដោយសំឡេងនេះ គឺពិតជាផ្តល់ផល អាក្រក់ទាំងចំពោះមនុស្សពេញវ័យ និងកុមារតូចៗ។ ការសិក្សាបានបង្ហាញថា កុមារដែលបានប្រឈមនឹងសំឡេងរំខានជាប្រចាំ និងមានបញ្ហាពិបាកក្នុងការសិក្សា។ សមត្ថភាពរបស់ពួកគេ ក្នុងការបំពេញបាននូវកាតព្វកិច្ចផ្សេងៗ ការរៀនភាសា និងបានជះឥទ្ធិពលមិនល្អជាច្រើនដោយសារតែការបំពុលដោយសំឡេងនេះ ។
- **បំផ្លាញដល់ការចងចាំ** ៖ ការបំពុលដោយសំឡេង ក៏អាចជះឥទ្ធិពលបានផងដែរដល់ការចងចាំ និងសមត្ថភាពនៃញ្ញាណដឹងរបស់មនុស្សម្នាក់ៗ។ ជាពិសេស ចំណុចនេះគឺផ្តល់ផលអាក្រក់ចំពោះកុមារដែលមានសមត្ថភាពនៃការរៀនសូត្រចុះខ្សោយដោយសារតែកត្តាបំពុលដោយសារសំឡេងនេះ។[41]
- **ការគេងមិនលក់** ៖ ការបំពុលដោយសំឡេង ក៏អាចរំខានដល់ដំណេករបស់អ្នកផងដែលដោយហេតុនាំឱ្យឆាប់ខឹង និងស្ថានភាពមិនស្រួល។ បើគ្មានការគេងលក់ស្រួលទេ អ្នកអាចជួបបញ្ហាជាច្រើនដែលទាក់ទងនឹងការអស់កម្លាំង។ វានឹងប៉ះពាល់ដល់ដំណើរការរបស់អ្នកនៅក្នុងការិយាល័យ ក៏ដូចជានៅផ្ទះ។ ដូច្នេះវាត្រូវបានណែនាំឱ្យគេងលក់ស្រួល ដើម្បីឱ្យរាងកាយរបស់អ្នកសម្រាកបានត្រឹមត្រូវ។ ប្រសិនបើមានសំឡេងរំខានជាក់លាក់ណាមួយកំពុងរំខានដល់ដំណេករបស់អ្នក សូមចាត់វិធានការណ៍

---

[40] គេហទំព័រ ៖ https://www.renovablesverdes.com/km/contaminacion-atmosferica/ ដកស្រង់ថ្ងៃទី២០ មេសា ២០២២

[41] គេហទំព័រ ៖ https://www.health.com.kh/archives/326971 ដកស្រង់ថ្ងៃទី២៤ មេសា ២០២២

ដើម្បីកាត់បន្ថយវា។ ខណៈពេលដែលនៅក្នុងករណីមួយចំនួនវាគឺជៀសមិនរួចទាំងស្រុងមានករណីផ្សេងទៀត (ដូចជាសំឡេងរំខានពីទូរទស្សន៍ ឬឧបករណ៍ឃោសនស័ព្ទផ្សេងៗ) ដែលអាចជៀសវាងបានយ៉ាងងាយដោយធ្វើការផ្លាស់ប្តូររបៀបរស់នៅល្អ។

- **បញ្ហាសរសៃឈាមបេះដូង** ៖ កម្រិតសម្ពាធឈាម ជម្ងឺសរសៃឈាមបេះដូង និងបញ្ហាបេះដូងដែលទាក់ទងនឹងស្ត្រេស កំពុងតែកើនឡើង។ ការសិក្សាបានណែនាំថា សំឡេងរំខានខ្លាំងធ្វើឱ្យសម្ពាធឈាមឡើងខ្ពស់ និងបង្កើនអត្រាចង្វាក់បេះដូង ព្រោះវារំខានដល់លំហូរឈាមធម្មតា។ ដោយសារការនាំយកអត្រាទាំងនេះទៅកម្រិតដែលអាចគ្រប់គ្រងបានអាស្រ័យលើការយល់ដឹងរបស់យើងអំពីការបំពុលដោយសំឡេង យើងត្រូវប្រុងប្រយ័ត្នចំពោះផលប៉ះពាល់ និងដោះស្រាយស្ថានភាពទាំងនេះដោយយកចិត្តទុកដាក់។[42]

### ២.២.៤. ផលប៉ះពាល់ដោយការបំពុលដី

ការបំពុលប្រភេទនេះគឺជាបញ្ហាដ៏ធំមួយសម្រាប់ផែនដី ដោយសារតែសកម្មភាពផ្សេងៗសម្រាប់ការអភិវឌ្ឍ និងការថែរក្សាសង្គមដូចជា កសិកម្ម ឧស្សាហកម្ម ឬការសាងសង់ទីក្រុងត្រូវបានអនុវត្តនៅលើស្រទាប់ខាងក្រោម។ ចាប់ពីពេលដែលទ្រព្យសម្បត្តិរបស់ដីត្រូវបានអន្តរាគមន៍ វិបត្តិស្បៀងអាហារត្រូវបានបង្កឡើងជាហេតុនាំឱ្យមានរបៀបរស់នៅ និងអនាគតនៃឆ្នាំខាងមុខ ចាប់តាំងពីទីកន្លែង ឬទីតាំងសម្រាប់ដាំដំណាំសម្រាប់ផ្គត់ផ្គង់ ហើយមានលទ្ធភាពតិចនៃការកសាងទីក្រុង។ ជាការពិត រូបរាងនៃភាពកខ្វក់នៅក្នុងដីត្រូវបានបង្ហាញភ្លាមៗនៅលើរុក្ខជាតិដែលបណ្តាលមកពីការរិចរិលរបស់វា ការថយចុះនៃប្រភេទសត្វដែលមានវត្តមាន និងតាមរបៀបដូចគ្នាទៅនឹងការប្រមូលផ្តុំភាពកខ្វក់នៅក្នុងរុក្ខជាតិ ដោយមិនបង្កការខូចខាតយ៉ាងសំខាន់។ ចំពោះមនុស្សផលប៉ះពាល់ត្រូវបានកំណត់ចំពោះការលេប និងទំនាក់ទំនងខាងក្រៅដែលពេលខ្លះវាបានបង្រួបបង្រួមដោយការពុលដោយលោហធាតុធ្ងន់ និងច្រើនជាងនេះទៅទៀតដោយសមាសធាតុសរីរាង្គឧស្ម័ន ឬពាក់កណ្តាលងាយនឹងបង្កជាហេតុ។[43]

ដីមានឥទ្ធិពលស្ទើរតែគ្រប់ទិដ្ឋភាពនៃជីវិតប្រចាំថ្ងៃរបស់យើង។ ពេលខ្លះយើងមិនយល់ពីវាជាលទ្ធផលនៃបញ្ហានេះ ពេលខ្លះយើងមិនយល់អំពីឥទ្ធិពលដែលការបំពុលដីមានលើជីវិតប្រចាំថ្ងៃរបស់យើង។ ដីដែលបំពុល

[42] គេហទំព័រ ៖ https://www.conserve-energy-future.com/causes-and-effects-of-noise-pollution.php ដកស្រង់ថ្ងៃទី២៤ មេសា២០២២

[43] គេហទំព័រ ៖ https://www.postposmo.com/km/contaminacion-del-suelo/#Consecuencias_de_la_Contaminacion_del_Suelo ដកស្រង់ថ្ងៃទី២៥ មេសា ២០២២

មានន័យថា ដំណាំក្រិន ឬសូម្បីតែតារាងទឹកក្រោមដីដែលមានជាតិពុល។ ផលប៉ះពាល់សំខាន់ៗមួយចំនួននៃការបំពុលដីត្រូវបានរៀបរាប់ខាងក្រោម ៖ [44]

- **ការចម្លងរោគដី ៖** ឬការផ្លាស់ប្តូរគុណភាពដីគឺបណ្តាលមកពីមូលហេតុផ្សេងៗគ្នាហើយផលវិបាករបស់វាច្រើនតែបង្កបញ្ហាធ្ងន់ធ្ងរដែលជះឥទ្ធិពលដល់រុក្ខជាតិសត្វ ឬសុខភាពមនុស្សក្នុងរយៈពេលយូរ។ ការចម្លងរោគដី តំណាងឱ្យស៊េរីនៃផលវិបាក និងផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់សម្រាប់មនុស្សក៏ដូចជាចំពោះសត្វនិងពពួកសត្វជាទូទៅ។ ផលប៉ះពាល់បំពុលមានភាពខុសប្លែកគ្នាគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើសារធាតុជាក់លាក់នីមួយៗដែលសុខភាពរបស់ដីត្រូវបានបំផ្លាញ។ ដំបូងផលវិបាក ការបំពុលនេះប៉ះពាល់ដល់រុក្ខជាតិត្រូវបានបំផ្លាញហើយប្រភេទសត្វជាច្រើនត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ប្រភេទដែលនៅរស់រាននឹងមានទិដ្ឋភាពទន់ខ្សោយហើយដំណើរការធម្មជាតិរបស់វានឹងពិបាក។ ការចម្លងរោគដីរារាំងការអភិវឌ្ឍជីវិតរបស់គ្រួសារ សត្វបើគ្មានអាហារឬទឹកស្អាតទេប្រភេទសត្វធ្វើចំណាកស្រុក ឬរងការខូចខាតដែលមិនអាចបំបែកបាននៅក្នុងខ្សែសង្វាក់បង្កើតកូនរបស់ពួកគេ។ ជាមួយនឹងដំណើរការនេះបន្ទាប់មកអ្វីដែលគេហៅថា "ការរិចរិលទេសភាព" ឬ "ការបាត់បង់តម្លៃដី" សកម្មភាពកសិកម្មត្រូវបានបញ្ឈប់ ហើយសត្វក៏បានបាត់បង់ និងដីគ្មានប្រយោជន៍។ ការបាត់បង់គុណភាពនៃដីពាក់ព័ន្ធនឹងផលវិបាកអវិជ្ជមានជាបន្តបន្ទាប់រាប់ចាប់ពីវា ការវាយតម្លៃដូចដែលយើងទើបតែបាននិយាយសូម្បីតែភាពមិនអាចទៅរួចនៃការប្រើប្រាស់ដើម្បីកសាងដាំដុះ ឬសាមញ្ញនឹងសាមញ្ញដើម្បីដាក់ប្រព័ន្ធអេកូឡូស៊ីដែលមានសុខភាពល្អ។[45]
- **ឥទ្ធិពលលើការលូតលាស់របស់រុក្ខជាតិ ៖** តុល្យភាពអេកូឡូស៊ីនៃប្រព័ន្ធណាមួយត្រូវបានរងផលប៉ះពាល់ដោយសារតែការរីករាលដាលនៃដី។ រុក្ខជាតិភាគច្រើនមិនអាចសម្របខ្លួនបាននៅពេលដែលគីមីសាស្ត្រនៃដីផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងរយៈពេលដ៏ខ្លី។ ផ្សិត និងបាក់តេរីដែលមាននៅក្នុងដីដែលភ្ជាប់វាជាមួយគ្នាចាប់ផ្តើមថយចុះ ដែលបង្កើតបញ្ហាបន្ថែមនៃសំណឹកដី។ ជីជាតិរបស់ដីថយចុះបន្តិចម្តងៗ ធ្វើឱ្យដីមិនអំណោយផលសម្រាប់កសិកម្ម និងបន្លែក្នុងស្រុកដើម្បីរស់។ ការបំពុលដីធ្វើឱ្យដីធំៗបង្កគ្រោះថ្នាក់ដល់សុខភាព។ [46]

---

[44] គេហទំព័រ ៖ https://www.conserve-energy-future.com/causes-and-effects-of-soil-pollution.php ដកស្រង់ថ្ងៃទី២៥ មេសា ២០២២

[45] គេហទំព័រ ៖ https://www.renovablesverdes.com/km/contaminacion-del-suelo/#Consecuencias_de_la_contaminacion_del_suelo ដកស្រង់ថ្ងៃទី២៥ មេសា ២០២២

[46] គេហទំព័រ ៖ https://www.conserve-energy-future.com/causes-and-effects-of-soil-pollution.php ដកស្រង់ថ្ងៃទី២៥ មេសា ២០២២

- **ការថយចុះនៃជីជាតិដី ៖** យើងត្រូវដឹងថា ៩៥% នៃចំណីអាហារដែលមនុស្សយើងបរិភោគ គឺបានមកពីដីទាំងអស់ដោយផ្ទាល់ និងដោយប្រយោល។ នេះបើយោងតាមតួលេខរបស់អង្គការស្បៀងអាហារពិភពលោក។ ដូច្នេះ បើដីខូចគុណភាព ខ្សោះគ្មានជីវជាតិ មានន័យថា ទិន្នផលនៃការដាំដុះគឺជាអ្នករងគ្រោះដំបូងគេបង្អស់។ ដីខូចគុណភាពកាន់តែច្រើនមានន័យថា ផ្ទៃដីដែលធ្វើកសិកម្មបានក៏កាន់តែរួញខើចដែរ។ បូកបន្ថែមជាមួយនឹងសកម្មភាពសាងសង់អាគារ ការចាក់បេតុង ការពង្រីកតំបន់ទីក្រុងទីប្រជុំជនផងនោះ គឺធ្វើឱ្យដីចំការ ដីស្រែ មានកាន់តែតិចទៅៗ។[47] សារធាតុពុលដែលមាននៅក្នុងដីអាចកាត់បន្ថយការមានជីជាតិរបស់ដី ដូច្នេះហើយទិន្នផលដីថយចុះ។ បន្ទាប់មកដីដែលមានមេរោគត្រូវបានប្រើប្រាស់សម្រាប់ផលិតបន្លែ និងផ្លែឈើ ដែលខ្វះសារធាតុចិញ្ចឹមប្រកបដោយគុណភាព និងអាចមានសារធាតុពុលមួយចំនួន ដែលបង្កបញ្ហាសុខភាពធ្ងន់ធ្ងរដល់អ្នកទទួលទាន។
- **ការផ្លាស់ប្តូររចនាសម្ព័ន្ធដី ៖** ការស្លាប់នៃសាកសពសារពាង្គកាយជាច្រើននៅក្នុងដីអាចនាំឱ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធដី។ ក្រៅពីនេះ វាក៏អាចបង្ខំឱ្យសត្វដែលស៊ីសាច់ដទៃជាអាហារផ្សេងទៀតផ្លាស់ទីទៅកន្លែងផ្សេងទៀតដើម្បីស្វែងរកអាហារ។ មធ្យោបាយមួយចំនួនត្រូវបានស្នើឡើង ដើម្បីទប់ស្កាត់អត្រានៃការបំពុលបច្ចុប្បន្ន។ ការព្យាយាមសម្អាតបរិស្ថានបែបនេះទាមទារពេលវេលា និងធនធានច្រើនដើម្បីដាក់ឱ្យដំណើរការ។ ឧស្សាហកម្មត្រូវបានផ្តល់បទប្បញ្ញត្តិសម្រាប់ការចោលកាកសំណល់គ្រោះថ្នាក់ដែលមានបំណងកាត់បន្ថយតំបន់ដែលក្លាយទៅជាការបំពុល។ វិធីសាស្ត្រកសិកម្មសរីរាង្គកំពុងត្រូវបានគាំទ្រ ដែលមិនប្រើប្រាស់ថ្នាំពុល និងជីគីមី។ ការប្រើប្រាស់រុក្ខជាតិដែលអាចដកជាតិពុលចេញពីដីកំពុងត្រូវបានលើកទឹកចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ផ្លូវខាងមុខគឺវែងឆ្ងាយ ហើយការទប់ស្កាត់ការបំពុលដីនឹងចំណាយពេលច្រើនឆ្នាំទៀត។
- **ការពុលនៃទឹកក្រោមដី ៖** ការបំពុលដីក៏នាំទៅដល់ការពុលនៃទឹកក្រោមដីផងដែរ។ ដោយសារទឹកនេះត្រូវបានរក្សាទុកនៅក្រោមស្រទាប់នៃដី ជាតិពុលនៅក្នុងដីងាយនឹងជ្រាបចូលបន្តិចម្តងៗ និងជាលំដាប់ទៅក្នុងប្រភពទឹក។ យើងត្រូវតែចងចាំផងដែរថានេះគឺជាទឹកដែលមានសម្រាប់ប្រើប្រាស់ និងប្រើប្រាស់តាមរយៈអណ្តូងទឹក និងអណ្តូងបំពង់។ នៅពេលដែលទឹកដែលមានជាតិពុលបែបនេះត្រូវបានប្រើប្រាស់ ឬប្រើប្រាស់ក្នុងរយៈពេលយូរ វាបណ្តាលឱ្យមានផលប៉ះពាល់ជាច្រើនដល់សុខភាពរបស់យើង។

[47] គេហទំព័រ ៖ https://www.rfi.fr/km/cambodia/បរិស្ថាន-ធម្មជាតិ-ស្ថានភាព-គុណភាព-ដី-ធ្លាក់ចុះ-ខ្លាំង-គ្រោះថ្នាក់-ដល់-មនុស្សជាតិ ដកស្រង់ថ្ងៃទី២៥ មេសា ២០២២

ជម្ងឺដូចជាការពុលអាសេនិច ការពុលអាហារ និងជម្ងឺផ្សេងៗទៀតគឺបណ្តាលមកពីការប្រើប្រាស់ទឹកក្រោមដីដែលមានជាតិពុលនេះយូរ។ ជម្ងឺទាំងនេះក៏អាចបង្ហាញថាជាជម្ងឺធ្ងន់ធ្ងរផងដែរ។[48]

## ២.២.៥. ផលប៉ះពាល់ដោយការបំពុលសំណល់រឹង រាវ

ការបំពុលដោយសំណល់គឺជាការប្រមូលផ្តុំនៃកាកសំណល់ដែលបង្កើតឡើងដោយសកម្មភាពរបស់មនុស្សនៅក្នុងបរិស្ថាន។ ការប្រមូលផ្តុំនៃការបំពុលសំណល់មិនថាសំណល់រឹង ឬសំណល់រាវនោះទេវាជាហេតុដែលនាំឱ្យមានការបំពុលទឹក ដី ខ្យល់យ៉ាងសកម្មទូទៅនៅក្នុងបរិស្ថាន។ ការគ្រប់គ្រងសំណល់មិនបានល្អត្រូវបានគេចាត់ទុកថាជាបុព្វហេតុផ្ទាល់នៃការបំពុលសំណល់។ កាកសំណល់ដែលផលិតដោយការផលិតទំនិញក្លាយជាសំរាមតែប៉ុណ្ណោះប្រសិនបើវាមិនត្រូវបានកែច្នៃត្រឹមត្រូវ។[49] សំណល់រឹងជាវត្ថុដែលយើងបានបោះបង់ចោល មិនថាសំណល់ផ្ទះបាយ សំណល់ឧស្សាហកម្ម ចំណីអាហារ ឬសម្ភារៈប្រើប្រាស់រាល់ថ្ងៃជាប្រចាំនោះទេ ប្រសិនបើយើងបោះចោលមិនបានត្រឹមត្រូវ ឬបែងចែកវាទៅតាមលក្ខណៈសំណល់នោះទេ វាអាចនឹងជះឥទ្ធិពលមកលើបរិស្ថានយើងទាំងស្រុង បូករួមទាំងមនុស្ស សត្វ និងរុក្ខជាតិផងដែរ។ ដោយសំណល់រាវ គឺសំដៅដល់វត្ថុរាវដែលជាផលិតផល និងជាសារធាតុរួមផ្សំ ជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅតាមបណ្តាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ។ ប្រសិនបើយើងនៅតែបន្តឱ្យមានការបំពុលដោយសំណល់រាវកាន់តែកើនឡើង នោះនាំឱ្យមានការបំពុលទឹក និងការបំពុលដីក៏កាន់ឡើងផងដែរ។

- **ផលប៉ះពាល់លើសុខភាពសាធារណៈ**៖ ការប្រមូលកាកសំណល់រឹង និងរាវតាមរបៀបមិនសមរម្យជះឥទ្ធិពលដោយផ្ទាល់ដល់ហានិភ័យនៃការរីករាលដាលនៃប្រជាជន។ ឧទាហរណ៍ការចាក់សំណល់ដោយគ្មានការត្រួតពិនិត្យការអនុគ្រោះដល់ការរីកសាយនៃសត្វល្អិតសត្វកកេរនិងសត្វដទៃទៀតដែលជាវ៉ិចទ័រនៃជម្ងឺ។ លើសពីនេះទៀត នៅពេលសំណល់កកកុញលក្ខខណ្ឌត្រូវបានបង្កើតឡើងនៅក្នុងបរិស្ថានដែលអនុគ្រោះដល់ការបង្កើតឡើងវិញនៃមីក្រូសរីរាង្គបង្កជម្ងឺ។ ទាំងនេះអាចបែកខ្ចាត់ខ្ចាយនៅពេលក្រោយដោយខ្យល់ ឬទឹកហើយប៉ះពាល់ដល់មនុស្ស។ អង្គការសុខភាពពិភពលោក (WHO) បង្ហាញថាក្នុងឆ្នាំ ២០១៧ មានទារកស្លាប់ជាង ១,៧ លាននាក់ដោយសារការបំពុលបរិស្ថាន។ ភាគច្រើននៃការស្លាប់ទាំងនេះគឺជាផលវិបាកនៃការបំពុលសំណល់នៅក្នុងតំបន់ក្រីក្របំផុតនៅលើពិភពលោក។ មានការចង្អុលបង្ហាញថាកុមារជាង ៣៦១.០០០ នាក់បានស្លាប់ដោយសារជម្ងឺក្រពះពោះវៀនដោយបានបរិភោគទឹកកខ្វក់ដែលមានសារធាតុបំពុលដោយសំណល់។ កុមារចំនួន ២០០.០០០ នាក់

[48] គេហទំព័រ ៖ https://www.conserve-energy-future.com/causes-and-effects-of-soil-pollution.php ដកស្រង់ថ្ងៃទី២៥ មេសា ២០២២

[49] គេហទំព័រ ៖ https://km.warbletoncouncil.org/contaminacion-por-basura-16524 ដកស្រង់ថ្ងៃទី៣០ មេសា ២០២២

ផ្សេងទៀតបានស្លាប់ដោយសារជម្ងឺដែលឆ្លងដោយសត្វល្អិតដែលបង្កាត់នៅក្នុងកាកសំណល់ដែលគ្រប់គ្រងមិនបានល្អ។

❖ **ផលប៉ះពាល់លើជីវចម្រុះ** ៖ ការបំពុលសំណល់មានផលប៉ះពាល់អវិជ្ជមានដល់ជីវចម្រុះ។ នៅពេលដែលមានការប្រមូលផ្តុំសំណល់នៅជិតប្រភពទឹកវានាំមេរោគ និងសារធាតុពុលផ្សេងៗចូលទីក្នុងប្រភពទឹកនោះ។ ម្យ៉ាងវិញទៀតការបំពុលទាំងនេះចូលទៅក្នុងច្រវ៉ាក់ដែលមានរាងដូចស្រ្តីងហើយត្រូវបានឆ្លងពីប្រភេទសត្វមួយទៅមួយទៀត។ ដូចគ្នានេះដែរពួកគេអាចប៉ះពាល់ដល់សុខភាពមនុស្សដែលបានបរិភោគសត្វដែលមានផ្ទុកសាធាតុពុល។ ការប្រមូលសំរាមនៅជិតទីជម្រកធម្មជាតិអាចបណ្តាលឱ្យសត្វជាច្រើនប្រភេទផ្លាស់ប្តូរទម្លាប់នៃការញុំា។ នេះដោយសារតែពួកគេរកឃើញប្រភពថាមពលអាហារមានតម្លៃសមរម្យដែលបង្កើតឱ្យមានបញ្ហាមេតាប៉ូលីសដែលប៉ះពាល់ដល់សុខភាពរបស់ពួកគេ។ ផលប៉ះពាល់មួយទៀតទៅលើជីវៈចម្រុះគឺថាសំណល់រួមបញ្ចូលសារធាតុគីមីដូចជាលោហធាតុធ្ងន់នឹងសារធាតុគីមីសាប៊ូចូលក្នុងបរិស្ថាន។ នេះបណ្តាលឱ្យមានការចម្លងរោគនៃប្រភពទឹកនឹងដីដែលជាកាកសំណល់វិទ្យុសកម្មដ៏ធ្ងន់ធ្ងរបំផុតមួយ។

❖ **ផលប៉ះពាល់លើគុណភាពបរិស្ថាន** ៖ នៅពេលដែលកាកសំណល់មានការកកកុញក្នុងបរិមាណច្រើន និងតាមរបៀបមិនសមរម្យវាចាប់ផ្តើមរលួយបង្កើតឧស្ម័នដែលបង្កគ្រោះថ្នាក់ដល់សុខភាព។ ក្នុងចំណោមទាំងនេះយើងមានកាបូនឌីអុកស៊ីត និងមេតានដែលជាឧស្ម័នផ្ទះកញ្ចក់។ ម្យ៉ាងទៀតឧស្ម័នមេតានគឺជាឧស្ម័នដែលងាយឆេះខ្លាំងហើយអាចចាប់ផ្តើមឆេះនៅពេលដែលមានដុតកាកសំណល់។ កាកសំណល់ទាំងនេះនៅពេលដែរត្រូវបានដុត វាបានបង្កើតជាឧស្ម័នពុលដែលបង្កឱ្យមានជម្ងឺផ្លូវដង្ហើមផ្សេងៗដល់ប្រភេទមហារីកមួយចំនួន។ បញ្ហាធ្ងន់ធ្ងរមួយទៀតជាមួយនឹងការបំពុលសំណល់គឺថាវាបន្ថយគុណភាពប្រភពទឹក។ ការដាក់បញ្ចូលលោហធាតុធ្ងន់ សាប៊ូបោកខោអាវ ឌីអុកស៊ីត ប្រេង និងសារធាតុពុលផ្សេងទៀតប៉ះពាល់ដល់សក្តានុពល និងអត្ថប្រយោជន៍របស់វាសម្រាប់ប្រព័ន្ធជាវាសាស្ត្រ។ក្នុងករណីខ្លះកំហាប់អុកស៊ីសែនរលាយអាចផ្លាស់ប្តូរដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ីក្នុងទឹក។ ដូចគ្នានេះផងដែរនៅពេលដែលសំណល់រលួយវាបញ្ចេញសារធាតុដែលត្រូវបានបង្ហូរដល់កំរិតទឹកក្រោមដីដែលបង្កឱ្យមានការបំពុលទឹកក្រោមដី។ ដូចគ្នានេះដែរដីក៏អាចត្រូវបានបំពុលដោយសមាសធាតុពុលដូចគ្នាដែលជះឥទ្ធិពលដល់រូបវន្តគីមីនឹងលក្ខណៈជីជាតិរបស់វា។[50]

[50] គេហទំព័រ ៖ https://km.warbletoncouncil.org/contaminacion-por-basura-16524 ដកស្រង់ថ្ងៃទី៣០ មេសា ២០២២

## ២.៣. វិធានការដោះស្រាយនៃការបំពុល

ជាការពិតណាស់នៅលើពិភពលោកគឺតែងតែរងទទួលឥទ្ធិពលនៃការបំពុលជាច្រើន រួមទាំងប្រទេសកម្ពុជាយើងក៏ការមានការចូលរួមទទួលផលប៉ះពាល់ផងដែរ ដែលភាគច្រើនទទួលរងការបំពុលពីការបំពុលទាំង៥ មានដូចជា ៖ ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដី ការបំពុលសំឡេង ការបំពុលដោយសំណល់រឹង ។ល។ ទោះបីជាយ៉ាងណាក៏ដោយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាស្ថាប័នពាក់ព័ន្ធក៏បាននឹងខិតខំកំពុងតែបានចូលរួមយ៉ាងសកម្មនៅក្នុងវិធានការដំណោះស្រាយនៃការបំពុលទាំងអស់នេះដែលផ្តោតសំខាន់ទៅលើការការពារ ក៏ដូចជាការចូលរួមយ៉ាងសំខាន់ដើម្បីថែរក្សាប្រទេសកម្ពុជាឱ្យមានបរិស្ថានល្អស្អាតឡើងវិញផងដែរ។ ខាងក្រោមនេះគឺជាវិធានការក្នុងការដោះស្រាយនៃការបំពុលទាំងអស់នេះ ៖

### ២.៣.១. វិធានការដោះស្រាយនៃការបំពុលទឹក

ការបំពុលទឹក ពិតជាបានផ្តល់ផលប៉ះពាល់ខ្លាំងមែនដល់អាយុជីវិត រុក្ខជាតិ សត្វ និង មនុស្ស ដូច្នេះ ដើម្បីការពារពីការកើតរោគផ្សេងៗ យើងត្រូវតែមានអនាម័យចំពោះការទទួលទានទឹក ដោយត្រូវដាំទឹកឱ្យពុះ ឬប្រើម៉ាស៊ីនចម្រុះទឹក ចៀសវាងការផឹកទឹកឆៅ ពីប្រភពទឹកទន្លេ ស្ទឹង បឹងបួ ជាដើម។[51] ក្នុងនោះផងដែរក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។[52] ដើម្បីចូលរួមកាត់បន្ថយការបំពុលទឹក យើងទាំងអស់គ្នាត្រូវមានវិធានការដូចខាងក្រោម ៖

- ប្រើប្រាស់ទឹកក្នុងការសន្សំសំចៃខ្ពស់
- មិនត្រូវបោះចោលកាកសំណល់ ទាំងឡាយណាដែលបណ្តាលឱ្យមានការកខ្វក់ទឹក
- មិនត្រូវប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងជីគីមីដែលមិនបានត្រួតពិនិត្យត្រឹមត្រូវ
- អប់រំប្រជាជនឱ្យបានយល់ច្បាស់អំពីបញ្ហាបរិស្ថាន និងតម្លៃនៃការខូចខាត ការបញ្ចូលការអប់រំបរិស្ថានក្នុងកម្មវិធី សិក្សាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់នៃប្រព័ន្ធអប់រំ
- ក្រសួងពាក់ព័ន្ធត្រូវមានវិធានការត្រឹមត្រូវក្នុងការថែរក្សាបរិស្ថាន ត្រូវចេះគ្រប់គ្រង និងតាមដានជាតិពុលទាំងឡាយដែលបណ្តាលឱ្យកខ្វក់ទឹក ហើយបណ្តុះបណ្តាលមន្ត្រីជំនាញក្នុងការត្រួតពិនិត្យ និងចេះប្រើប្រាស់ឧបករណ៍រកជាតិពុលក្នុងទឹកជាដើម
- ណែនាំអប់រំដល់ម្ចាស់រោងចក្រ សិប្បកម្ម សហគ្រាស រមណីដ្ឋាន ក៏ដូចជាភោជនីយដ្ឋានឱ្យធ្វើអាងសម្អាតកាកសំណល់ទាំងឡាយមុននឹងបង្ហូរចូលក្នុងទឹក

---

[51] គេហទំព័រ ៖ https://cambo-report.com/article/96 ដកស្រង់ថ្ងៃទី០១ ឧសភា ២០២២

[52] មាត្រា២៦ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក, ចុះនៅថ្ងៃទី ២៧ មេសា ១៩៩៩

- ➢ បង្កើតក្រុមចុះត្រួតពិនិត្យ និងធ្វើការដាក់ពិន័យចំពោះអ្នកទាំងឡាយណាដែលធ្វើឱ្យមានកខ្វក់ទឹក ។[53]

គួរបញ្ជាក់ផងដែរថា ការត្រួតពិនិត្យរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[54] ទន្ទឹមជាមួយគ្នានេះផងដែរ គឺត្រូវបានហាមឃាត់ជាដាច់ខាតរាល់ការចាក់ចោល ក៏ដូចជាការបង្ហូរចេញនូវសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តតាមកំរិតស្តង់ដារនៃការបញ្ចេញសំណល់រាវ។[55]

### ២.៣.២. វិធានការដោះស្រាយនៃការបំពុលខ្យល់

ជាការពិតណាស់ការបំពុលខ្យល់ ក៏មានការគ្រប់គ្រងពីក្រសួងស្ថាប័ននានាដែលពាក់ព័ន្ធ និងមានតួនាទីក្នុងការពិនិត្យមើលនូវបរិមាណនៃការបំពុលដែលមានផលប៉ះពាល់ទៅក្នុងបរិស្ថាន ។ នៅក្នុងនោះផងដែរក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា។[56] ទន្ទឹមក្នុងនេះផងដែលរាជរដ្ឋាភិបាលកម្ពុជាសង្កេតឃើញថាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ និងការគ្រប់គ្រងទីតាំងប្រភពការបំពុលខ្យល់នៅមានកម្រិត និងមិនទាន់ឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចជាតិ។ ដើម្បីគ្រប់គ្រងទីតាំងប្រភពបំពុលខ្យល់ឱ្យបានកាន់តែប្រសើរសំដៅធានាសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋព្រមទាំងកែលម្អសោភ័ណ្ឌភាពនៅតាមរាជធានី ខេត្ត រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួងស្ថានប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តវិធានការមួយចំនួនដូចខាងក្រោម ៖

- ❖ **ការគ្រប់គ្រងការដ្ឋានសំណង់**

១. ត្រូវពង្រឹងការគ្រប់គ្រងការហុយធូលី ឬភាគល្អិតនិចលទៅក្នុងខ្យល់ និងការបង្ហូរសំណល់ផ្សេងៗពីទីតាំងប្រភពបំពុលមានជាអាទិ៍ ការដ្ឋានសំណង់ ទីតាំងផលិតកម្មលាយបេតុងស្រេច ការដឹកជញ្ជូនគ្រួសខ្សាច់ ថ្ម ស៊ីម៉ង់ត៍ ឬបរិក្ខារសំណង់ផ្សេងៗ តាមរយៈការតម្រូវឱ្យមានការលាងសម្អាតកង់រថយន្តមុនចេញពីទីតាំងផលិតកម្ម ការបំពាក់ឧបករណ៍បាញ់ចំហាយទឹកដែលមានសម្ពាធខ្លាំង និងការគ្រប់គ្រងយានយន្តឱ្យបានមុននឹងចេញពីទីតាំងអាជីវកម្មដើម្បីចៀសវាងការកំពប់ ឬជ្រុះ និងការហុយធូលី ឬភាគល្អិតនិចលនៅតាមដងផ្លូវ។

២. ត្រូវពង្រឹងការចុះត្រួតពិនិត្យ និងអប់រំណែនាំដល់ម្ចាស់ការដ្ឋានសំណង់ទាំងអស់។

---

[53] គេហទំព័រ ៖ https://www.khsearch.com/qna/10411 ដកស្រង់ថ្ងៃទី០១ ឧសភា ២០២២

[54] មាត្រា១៨ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក, ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩

[55] មាត្រា៦ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុកទឹក, ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩

[56] មាត្រា២៦ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

- **ការគ្រប់គ្រងគុណភាពប្រេងឥន្ធនៈដែលមានផ្ទុកជាតិស្ពាន់ធ័រខ្ពស់**

១. លើកកម្ពស់ការអនុវត្តកម្រិតកំណត់ស្តង់ដាស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈ

២. នៅតាមស្ថានីយប្រេងឥន្ធនៈទាំងអស់ត្រូវបានជំរុញឱ្យដាក់ស្លាក់សញ្ញាសម្គាល់ប្រភេទប្រេងឥន្ធនៈ ដើម្បីឱ្យអ្នកប្រើប្រាស់អាចដឹងពីប្រភេទគុណភាព។

- **ការគ្រប់គ្រងការបញ្ចេញសារធាតុបំពុលខ្យល់ពីយានយន្ត**

១. លើកកម្ពស់ការអនុវត្តស្តង់ដានៃការបញ្ចេញសារធាតុបំពុលខ្យល់ពីយានយន្ត

២. ពង្រឹងការគ្រប់គ្រងចរាចរណ៍នៅតាមរាជធានី ខេត្ត ក្រុង និងទីប្រជុំជនតាមរយៈការបង្កើនប្រសិទ្ធិភាពមុខងារ ការរៀបចំប្លង់ទីក្រុង និងការកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងទីក្រុង។

៣. អនុវត្តយុទ្ធសាស្ត្រអាទិភាព សេវាដឹកជញ្ជូនសាធារណៈ និងបង្កើតការកសាងប្រព័ន្ធផ្លូវសម្រាប់ទោចក្រយាន និងថ្មើរជើង។

៤. ត្រូវមានផែនការកាត់បន្ថយការនាំចូលយានយន្តដែលប្រើរួច និងលើកទឹកចិត្តការប្រើប្រាស់យានយន្តថ្មី ឬយានយន្តដែលប្រើប្រាស់ថាមពលស្អាត ដើម្បីឈានទៅលុបបំបាត់ការនាំចូលយានយន្តចាស់ៗ។

៥. ពង្រឹងការគ្រប់គ្រង ត្រួតពិនិត្យគុណភាពប្រេងឥន្ធនៈ និងបង្ក្រាបលើការផលិត ការលក់ និងការចែកចាយផលិតផលប្រេងឥន្ធនៈដែលមិនឆ្លើយតបទៅនឹងស្តង់ដាគុណភាពប្រេងឥន្ធនៈ និងមានផ្ទុកបរិមាណស្ពាន់ធ័រខ្ពស់លើសពីកម្រឹតស្តង់ដារ។

៦. ពង្រឹងការត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់តាមរយៈការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត។

- **ការគ្រប់គ្រងការបញ្ចេញសារធាតុបំពុលខ្យល់ពីទីតាំងផលិតកម្ម**

ជំរុញការបំពាក់ឧបករណ៍ច្រោះសម្អាតផ្សែង និងធូលីតាមលក្ខណៈបច្ចេកទេសនៅតាមទីតាំងផលិតកម្ម ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពុលទៅក្នុងខ្យល់តាមរយៈការអនុវត្តនូវបច្ចេកវិទ្យាថ្មីៗមានអាទិ៍

- ការប្រើប្រាស់ថាមពលស្អាតជំនួសរួមមាន ការប្រើប្រាស់ឧស្ម័នធម្មជាតិថាមពលខ្យល់ ថាមពលទឹក ថាមពលព្រះអាទិត្យ និងថាមពលជីវម៉ាស់
- លើកកម្ពស់ការប្រើប្រាស់ប្រភពធ្យូងថ្មស្អាត មិនបង្កើតផេះច្រើន និងមានផ្ទុកស្ពាន់ធ័រកម្រិតទាប (មានផ្ទុកស្ពាន់ធ័រតូចជាង១ភាគរយ)។

- **ការគ្រប់គ្រងការដុតសំណល់នៅទីចំហ**

១. ត្រូវមានវិធានការបង្ការ និងទប់ស្កាត់ការកាប់ឆ្ការ ទន្ទ្រាន ឈូសឆាយ ដុតព្រៃឈើគ្រប់ប្រភេទ ការដុតសំរាម ការដុតសំណល់រឹងនៅតាមទីវាល ទីលានចាក់សំរាម និងទីលានសាធារណៈ។

២. ត្រូវចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបញ្ឈប់ការដុតសំរាម ការដុតសំណល់រឹង ការដុតវាលស្មៅ ការដុតគល់ជញ្ជ្រាំង និងសំណល់កសិកម្មផ្សេងៗទៀត។

៣. ក្នុងករណីកើតមានភ្លើងឆេះព្រៃធ្ងន់ធ្ងរ ត្រូវចាត់វិធានការទប់ស្កាត់ជាបន្ទាន់ដោយប្រើប្រាស់គ្រប់មធ្យោបាយតាមតែអាចធ្វើបានដើម្បីរួមគ្នាពន្លត់ភ្លើងព្រៃឱ្យមានប្រសិទ្ធិភាព។

- **ការកែលម្អការគ្រប់គ្រង និងធ្វើឱ្យប្រសើរឡើងបរិស្ថានទីប្រជុំជន**

១. ត្រូវរៀបចំកម្មវិធីសម្អាតអនាម័យបរិស្ថាននៅតាមទីសាធារណៈ និងបោសលាងសម្អាតធូលីតាមដងផ្លូវឱ្យបានស្អាតជាប់ជាប្រចាំ។

២. ត្រូវពង្រីកវិសាលភាពតំបន់បៃតងក្នុងការកសាងសំណង់ទីក្រុង និងតំបន់ព័ទ្ធជុំវិញដែលបាននឹងកំពុងសាងសង់។

- **ការបង្កើតប្រព័ន្ធតាមដាន និងព្យាករណ៍ការបំពុលខ្យល់**

១. ក្រសួងបរិស្ថានត្រូវសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីដំឡើងឧបករណ៍អង្កេតតាមដាន និងត្រួតពិនិត្យគុណភាពខ្យល់នៅតាមរាជធានី ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

២. ក្រសួងបរិស្ថានត្រូវរៀបចំផែនការសកម្មភាពដើម្បីបង្កើតប្រព័ន្ធតាមដាន និងព្រមានទុកជាមុនសម្រាប់ការបំពុលខ្យល់ធ្ងន់ធ្ងរ និងផ្សព្វផ្សាយជូនដល់សាធារណៈជនឱ្យទាន់ពេលវេលាដើម្បីត្រៀមខ្លួនក្នុងការទប់ស្កាត់ទៅនឹងហានិភ័យផ្សេងៗដល់សុខភាព។

៣. ក្នុងករណីតំបន់ណាមួយត្រូវបានទទួលការបំពុលខ្យល់ធ្ងន់ធ្ងរ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងស្ថានប័នពាល់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចាត់វិធានការជាបន្ទាន់ដើម្បីស្តារស្ថានភាពនៃការបំពុលខ្យល់ក្នុងតំបន់ឱ្យបានប្រសើរឡើងវិញ។[57]

## ២.៣.៣. វិធានការដោះស្រាយនៃការបំពុលដី

- បញ្ឈប់រាល់សកម្មភាពនៃការបោះចោលសំណល់រឹងទៅលើដី
- ត្រូវធ្វើការរៀបចំ គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់សំណល់រឹងទាំងអស់ឱ្យបានល្អ
- ធ្វើការរៀបចំកន្លែង និងបច្ចេកទេសនៃការបំផ្លាញចោលនូវកាកសំណល់ប្រកបដោយប្រសិទ្ធភាព និងមិនប៉ះពាល់ដល់បរិស្ថាន
- ការកំណត់ប្រភេទ ឬកម្រាស់ ឬទំហំនៃថង់ប្លាស្ទិក។ អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិចបានកំណត់ហាមឃាត់ការនាំចូល ការផលិតក្នុងស្រុក ការប្រើប្រាស់ និងចែកចាយនូវថង់ប្លាស្ទិចស្តើងមានដៃយួរ

[57] សារាចរស្តីពីវិធានការ ទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ ,ចេញនៅថ្ងៃទី០២ មករា ២០២០

គ្រប់ប្រភេទ លើកលែងតែថង់ផ្លាស្ទិចនោះមានកម្រាស់ចាប់ពី ០,០៣ មីលីម៉ែត្រឡើងទៅ និងមានរង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥ សង់ទីម៉ែត្រ ឬ១០ អ៊ីងឡើងទៅ

- ធ្វើការផ្សព្វផ្សាយ ព្រមទាំងលើកទឹកចិត្តឱ្យសាធារណៈជនចូលរួមក្នុងសកម្មភាពកិច្ចការពារបរិស្ថាននានា
- រាល់លំនៅឋាន ផ្សារទំនើប កន្លែងកំសាន្ត និងស្ថាប័នទាំងអស់ មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់រឹងដាច់ដោយឡែកពីសំណល់ផ្សេងៗទៀត តាមគោលការណ៍របស់ក្រសួងបរិស្ថាន
- រាល់ការប្រមូល ស្តុកទុក ដោះបំបែក ធ្វើប្រតិកម្ម ឬបោះបង់ចោល សំណល់រឹង ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន
- ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់ដែលបង្កឱ្យមានប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។ ឧទាហរណ៍ ៖ សំណល់អាគុយ សំណល់ថ្មពិល ឬសំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិច ។[58]

### ២.៣.៤. វិធានការដោះស្រាយនៃការបំពុលសំឡេង

ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃការបំពុលសំឡេង ឬសំឡេងរំខានត្រូវមានវិធានការមួយចំនួនដែលអាចអនុវត្តបានដោយប្រជាពលរដ្ឋគ្រប់រូបដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត។[59] បើយោងទៅតាម អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងបានកំណត់អំពីការត្រួតពិនិត្យនូវ សំឡេងរំខានពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[60] ចំពោះការត្រួតពិនិត្យនូវការរំខានដោយសំឡេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[61] កំរិតកំណត់ស្តង់ដារ អតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត។[62] កំរិតស្តង់ដារបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំឡេងអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។[63]

---

58 មាត្រា ១៤ នៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, ចុះនៅថ្ងៃទី ១០ តុលា ២០១៧

59 គេហទំព័រ ៖ https://km.warbletoncouncil.org/tipos-contaminacion-acustica-16274#menu-14 ដកស្រង់ថ្ងៃទី០៥ ឧសភា ២០២២

60 មាត្រា១៧ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

61 មាត្រា១៨ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

62 មាត្រា៥ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

63 មាត្រា៧ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

## ២.៣.៥. វិធានការដោះស្រាយនៃការបំពុលសំណល់រឹង រាវ

តាមប្រកាសអន្តរក្រសួងលេខ៨០រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង មានវិសាលភាពគ្រប់គ្រងសំណល់រឹងទាំងឡាយ ដោយរាប់បញ្ចូលទាំងការប្រមូល ការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោលសំរាមសំណល់រឹងគ្រប់ប្រភេទ ដែលមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចដែលពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ រាជធានីខេត្ត ក្រុង ប្រកបដោយប្រសិទ្ធិភាពទូទាំងប្រទេស។ ប្រកាសអន្តរក្រសួងលេខ៨០ ផ្តល់ទៅឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ការដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីធានានូវសោភ័ណ្ឌភាព និងបរិស្ថាន
- ដាក់ស្លាកហាមឃាត់ចោលសំរាម និងអប់រំឱ្យមានការទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្នឱ្យបានសមរម្យ ដោយគ្មានការរំខានដល់ចរាចរណ៍ សុខភាពសាធារណៈ សោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់សង្គម
- ប្រមូលសំរាម និងដឹកជញ្ជូនសំរាម សំណល់រឹងទៅបោះចោលឱ្យបានទៀងទាត់ នៅទីលានចាក់សំរាមដែលបានកំណត់ដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចដែលពាក់ព័ន្ធ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការសហការជាមួយស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនានា ត្រូវអប់រំ និងផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណៈជន អំពីការទុកដាក់សំរាម សំណល់រឹង តាមរយៈវិធីសាស្ត្រប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។ ដើម្បីកាត់បន្ថយសំរាម សំណល់រឹង ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែជម្រុញ និងលើកទឹកចិត្តឱ្យមានសកម្មភាពកែច្នៃសំរាម ឬដំណើរការកែច្នៃសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន
- មន្ទីរបរិស្ថានខេត្ត/ក្រុង និងការិយាល័យបរិស្ថានស្រុកខណ្ឌ ត្រូវដើរតួនាទីជាសេនាធិការឱ្យអាជ្ញាធរមូលដ្ឋាន ក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមបង្កើតផែនការសកម្មភាពក្នុងការប្រមូល ការស្តុកសំរាមបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាម ដោយត្រូវសហការ និងតាមដានការអនុវត្តផែនការទាំងនោះផងដែរ។ រាយការណ៍អំពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន អំពីការប្រមូល ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាម

ដោយត្រូវផ្ញើរបាយការណ៍នេះទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ព្រមទាំងក្រសួងដែលមានការពាក់ព័ន្ធនានាទៀតផង។[64]

យោងតាមអនុក្រឹត្យលេខ១១៣ ដែលទទួលបានការអនុម័តកាលពីខែសីហា ឆ្នាំ២០១៥ បានកំណត់អាណត្តិកាន់តែច្បាស់លាស់ និងមានភាពប្រសើរដល់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។ ដោយអនុក្រឹត្យលេខ១១៣ នេះមានគោលបំណងដូចខាងក្រោមៈ

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា លើការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនឹងស្រុក និងបានធ្វើប្រតិភូកម្មមុខងារនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាល រាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សម្រាប់សំណល់រឹងទីប្រជុំជន
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។[65]
- បញ្ឈប់រាល់សកម្មភាពនៃការបោះចោលសំណល់រឹងទៅលើដី
- ត្រូវធ្វើការរៀបចំ គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់សំណល់រឹងទាំងអស់ឱ្យបានល្អ
- ធ្វើការរៀបចំកន្លែង និងបច្ចេកទេសនៃការបំផ្លាញចោលនូវកាកសំណល់ដែលប្រកបដោយប្រសិទ្ធភាព និងមិនប៉ះពាល់ដល់បរិស្ថាន
- រៀបចំគោលនយោបាយក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។ ឧ. ការអនុវត្តគោលការណ៍ «*ការផ្តល់ថង់ប្លាស្ទិកដល់អតិថិជនត្រូវគិតតម្លៃបន្ថែម*» ឬការជំរុញឱ្យប្រើប្រាស់ ថង់ក្រដាសជំនួសឱ្យថង់ប្លាស្ទិក។[66]
- ការកំណត់ប្រភេទ ឬកម្រាស់ ឬទំហំនៃថង់ប្លាស្ទិក។ [67] ឧ. មាត្រា ១៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិច ឆ្នាំ ២០១៧ បានកំណត់ហាមឃាត់ការនាំចូល ការផលិតក្នុងស្រុក ការប្រើប្រាស់ និងចែកចាយ

[64] ប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង

[65] មាត្រា២ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

[66] មាត្រា១៩ នៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, ចុះនៅថ្ងៃទី ១០ តុលា ២០១៧

[67] មាត្រា១៤ នៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, ចុះនៅថ្ងៃទី ១០ តុលា ២០១៧

នូវថង់ផ្លាស់ស្ទិចស្តើងមានដៃយួរគ្រប់ប្រភេទ លើកលែងតែថង់ផ្លាស្ទិចនោះមានកម្រាស់ចាប់ពី ០,០៣ មីលីម៉ែត្រ ឡើងទៅ និងមានវង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥ សង់ទីម៉ែត្រ ឬ១០ អ៊ីង ឡើងទៅ

- ធ្វើការផលិតថង់ ឬសម្ភារៈវេចខ្ចប់ ពីសារធាតុងាយពុកផុយ ឬជីវប្លាស្ទិក
- លើកទឹកចិត្ត ដល់ការកែច្នៃ និងផលិតក្នុងប្រទេសនូវសម្ភារៈនានា អំពីសំណល់ថង់ប្លាស្ទិកក្នុងស្រុក
- ធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យសាធារណៈជនចូលរួមក្នុងសកម្មភាពកិច្ចការពារបរិស្ថាននានា
- រាល់លំនៅដ្ឋាន ផ្សារទំនើប កន្លែងកំសាន្ត និងស្ថាប័នទាំងអស់ មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់រឹង ដាច់ដោយឡែកពីសំណល់ផ្សេងៗទៀត តាមគោលការណ៍របស់ក្រសួងបរិស្ថាន
- រាល់ការប្រមូល ស្តុកទុក ដោះបំបែក ធ្វើប្រតិកម្ម ឬបោះបង់ចោល សំណល់រឹង ត្រូវអនុវត្តឱ្យ បានត្រឹមត្រូវតាមគោលការណែនាំរបស់ក្រសួងបរិស្ថាន
- ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់ ដែលបង្កឱ្យប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។ ឧ. សំណល់អាគុយ សំណល់ថ្មពិល[68] ឬសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិច[69]។

ជាមួយគ្នានេះផងដែរយើងក៏មាននូវ គោលការណ៍ដែលត្រូវបានកំណត់សម្រាប់រោងចក្រសហគ្រាសផងដែរព្រោះ ការបំពុលដោយសំណល់រាវភាគច្រើនចេញមកពី រោងចក្រ សហគ្រាស និងសិប្បកម្មដែលមិនមានការអនុវត្តត្រឹមត្រូវទៅតាមបទដ្ឋានគតិយុត្ត ។ ការកំរិតស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពទាំងឡាយ។

- ហាមឃាត់ដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញនៅសំណល់រាវ ពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតស្តង់ដារ
- ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពនៃការបំពុលទៅទីកន្លែងដទៃ ក្នុងគោលបំណងណាមួយត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងផ្ញើពាក្យចម្លងនោះទៅក្រសួង នឹងស្ថាប័នពាក់ព័ន្ធ
- ការត្រួតពិនិត្យនូវរាល់ការបញ្ចេញចោល ឬបង្ហូរចេញសំណល់រាវពីប្រភពនៃការបំពុល គឺជាសមត្ថកិច្ចស្ថិតក្រោមការត្រួតពិនិត្យនៃ ការដោះស្រាយនៃ ក្រសួងបរិស្ថាន
- ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពនៃការបំពុល ត្រូវចូលរួមសហការអនុវត្តជាមួយមន្ត្រីមានសមត្ថកិច្ចដែលមានកាតព្វកិច្ច ដើម្បីធានាឱ្យមានការបង្កើតភាពងាយស្រួលក្នុងការបំពេញកាងារតាមលក្ខណៈបច្ចេកទេស

[68] ប្រកាសលេខ៤៤២ ប្រក ស្តីពីការគ្រប់គ្រងសំណល់អាគុយ និងសំណលថ្មពិល, ឆ្នាំ ២០១៦
[69] អនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គីសនី និងអេឡិចត្រូនិច, ចុះនៅថ្ងៃទី០១ កុម្ភៈ ២០១៦

- ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំពីស្ថានភាពនៃការបំពុល ទឹកនៅតាមតំបន់ ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាម សាធារណៈ
- ការគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតម្លៃពីគុណភាពនៃទឹកនៅតាមតំបន់ សាធារណៈជាប្រចាំ
- ការផ្សព្វផ្សាយជាសាធារណៈនៃស្ថានភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់សាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ការទទួលពាក្យបណ្តឹង និងសេចក្តីរាយការណ៏ប្រភពនៃការបំពុលណាមួយបានបង្ហូរចេញនូវសំណល់ រាវ ដែលមានផ្ទុកសារជាតិពុលបង្ករឱ្យប៉ះពាល់ទៅដល់សុខភាព មនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្ករឱ្យមានការបំពុលទឹកសាធារណៈក្រសួងបរិស្ថាននឹងស្ថាប័នពាក់ព័ន្ធត្រូវចុះត្រួតពិនិត្យ និងយកគំរូ តាងទាំងនោះមកវិភាគនឹងចាត់នីតិវិធីជាបន្ទាន់បើសិនរកឃើញថាមានសារជាតិពុលដែលប៉ះពាល់ដល់ សុខភាពមនុស្ស សត្វ
- ករណីដែលមានការរំលោភបំពានទៅដល់ការអនុវត្តបទដ្ឋានគតិយុត្តទាំងអស់ ស្ថាប័នដែលមាន សមត្ថកិច្ចត្រូវធ្វើនីតិវិធីរៀបចំឯកសារដែលជាវត្ថុតាងទាំងអស់ គឺសម្រាប់ការធានាឱ្យបានថាគ្មាន សកម្មភាពល្មើសមួយណាអាចមិនទទួលទណ្ឌកម្មតបពីច្បាប់បានទេ
- យោងតាមសកម្មភាពកន្លងមកបានឱ្យឃើញថាសកម្មភាពនៃការបំពុលកត្តាសំខាន់ផ្តើមចេញពីម្ចាស់ កម្មសិទ្ធទៅលើរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលមានកង្វះខាតទៅលើការអនុវត្តនៃការណែនាំពី ស្ថាប័នមានសមត្ថកិច្ច បន្ថែមពីលើនេះផងដែរការអនុវត្តរបស់មន្ត្រីមានដែនសមត្ថកិច្ចនៅមានកម្រិត នៅឡើយ ។

ជាមួយគ្នានេះផងដែរ នៅប្រទេសកម្ពុជា ការដុតសំរាមនៅតែជាការអនុវត្តជាទូទៅពិសេសនៅតាមជនបទ ដោយសារតែកង្វះខាតទីកន្លែងសម្រាប់ចាក់សំរាម ឬសេវាប្រមូលសំរាម។ ការដុតសំរាម ត្រូវបានទទួលស្គាល់ ថាគឺជាវិធីចោលសំរាមដ៏ងាយស្រួលបំផុត។ នៅក្នុងឆ្នាំ២០១៥អ្នកនាំពាក្យក្រសួងបរិស្ថានបានឱ្យដឹងថាកន្លែង ចាក់សំរាមនៅកម្ពុជាភាគច្រើនមិនមានការបែងចែកត្រឹមត្រូវរវាងប្រភេទសំរាមបំបែកសរីរាង្គបាន និងសំរាមមិន អាចបំបែកសរីរាង្គបាននោះទេ។

បើយោងតាមការសិក្សាមួយនៅក្នុងឆ្នាំ២០១៥ ដែលបានដឹកនាំដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និង អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) ក៏បានឱ្យដឹងផងដែរថាកាលពីឆ្នាំ២០១៣ រាជធានីភ្នំពេញ បានបញ្ចេញកាកសំណល់ប្រមាណ ១,២៨៦ តោនក្នុងមួយថ្ងៃ។ នៅមុន២០៣០ បរិមាណសំរាមត្រូវបានគេ

ទស្សន៍ទាយថានឹងកើនឡើងទ្វេដងរហូតដល់ ៣,១១២ តោនក្នុងមួយថ្ងៃ។ ការសិក្សានេះក៏បានប្រមើលឃើញថា ទីលានចាក់សំរាមទាំងពីរទីតាំងនៅទីក្រុងភ្នំពេញ ដែលស្ថិតនៅខណ្ឌដង្កោរ និងផ្ទុកដល់ចំណុះរបស់វា នៅត្រឹមឆ្នាំ២០២០ ខាងមុខនេះ។

ឆ្លើយតបទៅនឹងការរកឃើញនេះ នៅចុងឆ្នាំ២០១៥ ត្រូវបានរាយការណ៍ថា សាលារាជធានីភ្នំពេញគ្រោងនឹងសាងសង់កន្លែងគ្រប់គ្រងសំរាមថ្មីចំនួនពីរទីតាំងបន្ថែមទៀត ដែលស្ថិតក្នុងសង្កាត់ជ្រោយចង្វារ និងច្បារអំពៅ។ ទោះជាយ៉ាងណា មិនមានការបញ្ជាក់ថា គម្រោងនេះនឹងចាប់ផ្តើមនៅពេលណានោះទេ។ បន្ថែមពីនេះទៅទៀតរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងការគ្រប់គ្រងគឺការគ្រប់គ្រងសំណល់រឹងស្ថិតនៅក្រោមសមត្ថកិច្ចនៃក្រសួងបរិស្ថាន។ តាមច្បាប់ ការគ្រប់គ្រងសំណល់រឹងសំដៅលើការដឹកជញ្ជូន ការទុកដាក់ ការចាក់សំរាម និងប្រព្រឹត្តកម្មសំណល់។ ក្រសួងមានតួនាទីទទួលខុសត្រូវលើការបង្កើតច្បាប់ គោលការណ៍ណែនាំ និងវិន័យនានាសម្រាប់ការងារគ្រប់គ្រង និងការងារត្រួតពិនិត្យទៅលើកាកសំណល់ដែលរួមទាំងសំណល់ពីមន្ទីរពេទ្យ សំណល់ពីរោងចក្រ និងសំណល់ដែលបង្កគ្រោះថ្នាក់។

ដោយមានការគាំទ្រពីសហភាពអ៊ឺរ៉ុប ក្រសួងបរិស្ថាន អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) បានសហការរួមគ្នា បង្កើតគោលការណ៍ណែនាំបរិស្ថានស្តីពីការគ្រប់គ្រងសំណល់រឹង នៅក្នុងឆ្នាំ២០០៦។ គោលការណ៍ណែនាំទាំងនេះ បានផ្តល់ដាក់ចុះនូវគោលដៅ និងការចង្អុលបង្ហាញរួមមាន ការរៀបចំការប្រតិបត្តិ ការថែទាំ និងការបិទដំណើរការទីលានចាក់សំរាម វិធីសាស្ត្រធ្វើជីកំប៉ុស្តិ៍ ការគ្រប់គ្រងសំណល់បរិក្ខារពេទ្យ ការអប់រំពីបរិស្ថាន និងគោលការណ៍ណែនាំផ្សេងៗទៀត។ បន្ថែមពីនេះបទប្បញ្ញត្តិជាក់លាក់នានាត្រូវបានចែងនៅក្នុងអនុក្រឹត្យចំនួនបី ៖

- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងទីក្រុង ឆ្នាំ២០១៥
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអេឡិចត្រូនិច ឆ្នាំ២០១៥។

ការប្រមូល ការដឹកជញ្ជូន ការកាត់បន្ថយ ការកែច្នៃឡើងវិញ និងការចាក់សំរាម គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរខេត្ត និងក្រុង។ ការអនុវត្ត គឺត្រូវបានចាត់ចែង និងត្រួតពិនិត្យដោយក្រសួងបរិស្ថាន។ នៅក្នុងរាជធានីភ្នំពេញ សេវាប្រមូលសំរាម គឺត្រូវបានចុះកិច្ចសន្យាដោយសាលារាជធានីភ្នំពេញ និងក្រុមហ៊ុនស៊ីនទ្រី។ សេវាប្រមូលសំរាមនៅកម្ពុជា គឺជាសេវាកម្មដែលទទួលបានការផ្តល់សិទ្ធិផ្តាច់មុខ។ នៅក្នុងឆ្នាំ២០០២ ក្រុមហ៊ុនស៊ីនទ្រី ជាក្រុមហ៊ុនតែមួយគត់ដែលទទួលបានកិច្ចសន្យារយៈពេល ៤៧ឆ្នាំ លើការផ្តល់សេវាប្រមូលសំរាមនេះ។ យ៉ាងនេះក្តី ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ សាលារាជធានីភ្នំពេញបានព្រមានដល់ក្រុមហ៊ុន ស៊ីនទ្រីទៅលើ

ប្រតិបត្តិការ និងសេវាកម្មរបស់ក្រុមហ៊ុននេះដោយសារតែមានសេចក្តីរាយការណ៍អំពីបញ្ហាកូដកម្មរបស់កម្មករ និងពាក្យបណ្តឹងពីប្រជាពលរដ្ឋ។

ជាមួយគ្នានេះការផ្តួចផ្តើមរិមជ្ឈការ គឺនៅខែមីនា ឆ្នាំ២០១៥ ដោយរដ្ឋាភិបាលបានប្រកាសថា ខ្លួននឹងត្រៀមថវិកាមូលនិធិចំនួន ៥លានដុល្លារអាមេរិក ដើម្បីផ្តល់ឱ្យស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ប្រើប្រាស់ក្នុងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាមនៅតាមទីក្រុងរបស់ពួកគេ។ ចំពោះការផ្តួចផ្តើមនេះ គឺត្រូវបានសម្របសម្រួលដោយក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងក្រសួងមហាផ្ទៃ ព្រមទាំងបណ្តាសាលាក្រុង។ អាជ្ញាធរថ្នាក់ក្រោមជាតិនីមួយៗ ត្រូវបានផ្តល់អំណាចនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមឯកជននានា។

តាមរយៈការផ្តួចផ្តើមនេះ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមក្នុងទីក្រុង និងការគ្រប់គ្រងសំណល់រឹង ថ្មីមួយទៀតត្រូវបានបង្កើតឡើង។ វាមានគោលបំណងពង្រឹង និងផ្ទេរការទទួលខុសត្រូវទៅរដ្ឋាភិបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំរាម និងសំណល់នៅតាមបណ្តាក្រុងរបស់ខ្លួន។ វាក៏បានចែងលម្អិតអំពីទំនួលខុសត្រូវនានា របស់អាជ្ញាធរពាក់ព័ន្ធដែលរួមមាន ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ និងអង្គភាពគ្រប់គ្រង នៅថ្នាក់ក្រោមជាតិ។ អនុក្រឹត្យនេះ មិនបានគ្របដណ្តប់លើបញ្ហាសំណល់រោងចក្រ និងសំណល់ដែលបង្កគ្រោះថ្នាក់នោះទេ។

ទោះបីជាយ៉ាងណាក៏ដោយក៏ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញជាសកលការអនុវត្ត 3Rs មិនមែនជារឿងថ្មីនោះទេ ប៉ុន្តែវានៅតែជាការអនុវត្តមួយដែលមិនទាន់ត្រូវបានស្គាល់ច្រើនពីសំណាក់មនុស្សទូទៅអំពីការគ្រប់គ្រងសំណល់នៅក្នុងប្រទេសកម្ពុជា។ ប្រភេទសំណល់សរីរាង្គ និងសំណល់ប្លាស្ទិច គឺត្រូវបានដាក់លាយឡំគ្នា។ ការជម្រុញឱ្យមានការយកចិត្តទុកដាក់ជាសាធារណៈអំពីសារៈប្រយោជន៍នៃការបែងចែកសំណល់ គឺជាបញ្ហាប្រឈមសំខាន់មួយនៅក្នុងប្រទេសនេះ។ ការសិក្សាជាច្រើនបានបង្ហាញថាប្រទេសកម្ពុជាស្ទើរតែគ្មានហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការកែច្នៃឡើងវិញនោះទេ។ សំណល់កែច្នៃមួយចំនួនត្រូវបាននាំចេញទៅកែច្នៃឡើងវិញ នៅប្រទេសថៃ និងប្រទេសវៀតណាម។ ការផ្តួចផ្តើមពីរដែលគួរឱ្យចាប់អារម្មណ៍ត្រូវបានដាក់នៅក្នុង3Rs[70] ៖ គឺប្រែក្លាយសំណល់ទៅជាថាមពល តាមរយៈការផ្តល់មូលនិធិដោយ សហភាពអឺរ៉ុប SWITCH-Asia, អង្គការSNVកម្ពុជា បានអនុវត្តគម្រោងប្រែក្លាយសំណល់ទៅជាថាមពលសម្រាប់ប្រើប្រាស់ក្នុងរោងកិនស្រូវ (បច្ចេកវិទ្យាដើម្បីបំលែងថាមពលអគ្គីសនីពីអង្កាម) ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥។ គម្រោងនេះបានសម្រេចជ្រើសរើសខេត្តគោលដៅនៅទូទាំងប្រទេសកម្ពុជាមានចំនួន៩ មានដូចជា៖ ខេត្តបាត់ដំបង

[70] reducing waste, reusing and recycling resources ដកស្រង់ថ្ងៃទី១៤ ឧសភា ២០២២

ពោធិ៍សាត់ កំពង់ស្ពឺ បន្ទាយមានជ័យ កំពង់ធំ សៀមរាប កណ្ដាល កំពង់ចាម និងព្រៃវែង។ គម្រោងនេះមានគោលបំណងធ្វើឱ្យវិស័យឧស្សាហកម្មកាន់តែមានពណ៌បៃតងកាន់តែស្អាត និងកាត់តែប្រកួតប្រជែង។

យុទ្ធនាការប្រឆាំងការប្រើប្រាស់ថង់ប្លាស្ទិច ៖ អង្គការយូណេស្កូកម្ពុជា ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងសហព័ន្ធសហភាពយុវជនកម្ពុជា បានសហការគ្នារៀបចំយុទ្ធនាការប្រឆាំងការប្រើប្រាស់ថង់ប្លាស្ទិច ដើម្បីជម្រុញឱ្យមានការយកចិត្តទុកដាក់ជាសាធារណៈលើការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច និងការកែច្នៃប្រើប្រាស់ឡើងវិញ។ យុទ្ធនាការនេះ ក៏មានគោលបំណងដើម្បីឱ្យមានឥទ្ធិពលផ្លាស់ប្តូរលើអាកប្បកិរិយានៅក្នុងចំណោមប្រជាជនកម្ពុជា។

ការផ្តួចផ្តើមថ្នាក់តំបន់ គម្រោងថ្នាក់តំបន់រយៈពេលប្រាំឆ្នាំ ដែលផ្តោតទៅលើការកែលម្អការគ្រប់គ្រងសំណល់ ត្រូវបានបើកដំណើរការនៅក្នុងឆ្នាំ ២០១៥។ សមាជិកគម្រោងនេះ រួមមានប្រទេសកម្ពុជា ហ្វីលីពីន វៀតណាម ឡាវ និងម៉ុងហ្គោលី។ មូលនិធិបរិស្ថានសកលលោក បានផ្តល់ថវិកាចំនួន ៧.៥ លានដុល្លារអាមេរិកសម្រាប់គម្រោងនេះ។ នៅប្រទេសកម្ពុជា គម្រោងនេះនឹងត្រូវអនុវត្តដោយក្រសួងបរិស្ថាន អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម (UNIDO) និងសាលារាជធានីភ្នំពេញ ហើយវានឹងត្រូវចាប់ផ្តើមដំបូងជាមួយនឹងទីលានចាក់សំរាមដ៏ធំបំផុតមួយរបស់ទីក្រុងភ្នំពេញ ជើងឯក។[71]

ជាមួយគ្នានេះផងដែរ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ បានបង្កើតក្រុមការងារថ្មីដើម្បីត្រួតពិនិត្យ និងដាក់បញ្ចូលវិធានការអនាម័យ និងបរិស្ថានទៅក្នុងលក្ខណសម្បត្តិនៃគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីបំផុសស្មារតីពលរដ្ឋឱ្យយកចិត្តទុកដាក់រក្សាអនាម័យ គ្រប់គ្រងសំណល់រឹងឱ្យបានល្អ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន បានចុះហត្ថលេខាលើសេចក្តីប្រកាសអន្តរក្រសួង កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។

នៅក្នុងសេចក្តីប្រកាសអន្តរក្រសួង ក្រុមការងារថ្មីនេះមានតួនាទីពិនិត្យឡើងវិញនូវលក្ខណសម្បត្តិនៃគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដើម្បីកែសម្រួលឱ្យបានសមស្របជាមួយសភាពការណ៍វិវត្តប្រែប្រួលនៃបទល្មើស និងការចូលរួមរបស់ពលរដ្ឋ។ ក្រុមការងារមានភារកិច្ចសិក្សាពិនិត្យ និងកែសម្រួលគោលការណ៍ វិធានការ និងយន្តការនានានៃចលនាប្រឡងប្រណាំងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព។[72]

---

[71] គេហទំព័រ https://opendevelopmentcambodia.net/km/topics/solid-waste/ ដកស្រង់ថ្ងៃទី១៤ ឧសភា ២០២២

[72] គេហទំព័រក្រសួងបរិស្ថាន https://www.moe.gov.kh/index/28428 ដកស្រង់ថ្ងៃទី១៤ ឧសភា ២០២២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីបរិស្ថាន និងការបំពុល ជាមួយនឹងប្រភពក៏ដូចជាផលប៉ះពាល់ជាច្រើន និងដំណោះស្រាយនៃការបំពុលកន្លងមក យើងឱ្យយើងសន្និដ្ឋានបានថា បរិស្ថានពិតជាមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ទំនាក់ទំនងជីវៈចម្រុះគ្រប់ប្រភេទ។ ស្របជាមួយគ្នានេះផងដែរ ការបំពុលពិតជាបញ្ហាដ៏ធំមួយដែលរំខានដល់ការរស់នៅ និងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងចំពោះសង្គមបច្ចុប្បន្ន។ ជាក់ស្តែង ផលប៉ះពាល់ដែលបានកើតចេញមកពីការបំពុល មិនត្រឹមតែផ្តល់ភាពរំខានដល់ការរស់នៅជីវភាពប្រចាំថ្ងៃរបស់មនុស្សប៉ុណ្ណោះទេ វាបានផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះអាយុជីវិតគ្រប់ប្រភេទ លើសពីនេះទៅទៀតវិស័យមួយចំនួនដែលជាសសរក្នុងការទ្រទ្រង់ប្រទេសជាតិត្រូវបានរងផលប៉ះពាល់ និងចុះអន់ថយផងដែរដោយសារការបំពុលទាំងនេះ។ តាមតថបទបច្ចុប្បន្ន វិស័យទេសចរណ៍ជាវិស័យដែលរងនូវឥទ្ធិពលយ៉ាងខ្លាំងខ្លាពីសំណាក់ការបំពុលក្នុងប្រទេសកម្ពុជា។ សោភ័ណ្ឌភាពទីក្រុង ទីជនបទ និងតំបន់ទេសចរណ៍ត្រូវបានបំផ្លាញបន្តិចម្តងៗដោយសារការបំពុល។ ដូច្នេះវិធានការ និងយន្តការនានា របស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ ក្នុងការទប់ស្កាត់ឱ្យបាននូវការបំពុល ជាកត្តាចំបងដែលអាចជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើន និងប្រកបដោយភាពស្រស់បំព្រង។

យន្តការនៃការដោះស្រាយបញ្ហាទាំងឡាយនៃការបំពុល ត្រូវបានកំណត់ តាមរយៈការដោះស្រាយតាមផ្លូវច្បាប់ និងយន្តការដោះស្រាយដោយការចូលរួម។ ការបំពុលមួយចំនួនត្រូវបានកាត់បន្ថយដោយសារការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ដោះស្រាយបញ្ហានេះ។ ដោយមានមូកហេតុថារាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីដាក់ចេញនូវវិធានការដើម្បីទប់ស្កាត់ សារាចរណែនាំនានា ដល់ប្រជាជនទូទៅអាចយល់ដឹងកាន់តែច្បាស់អំពី ផលវិបាកនៃបញ្ហាការបំពុលបរិស្ថាន។

សរុបរួមមក ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដោយសំឡេង ការបំពុលដី ការបំពុលដោយសំណល់រឹង-រាវ ពិតជាផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះជីវភាព និងការរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិ ព្រមទាំងបរិស្ថានជុំវិញ។ ដើម្បីរារាំង និងទប់ស្កាត់បញ្ហាដែលកើតមានឡើងដោយកត្តាទាំងនេះ ត្រូវមានការចូលរួមសហការគ្នាពីសំណាក់ប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធគ្រប់សន្ទាប់ថ្នាក់ ក្នុងការអនុវត្តទៅតាមវិធានការនានា ដែលបង្កើតឡើងក្នុងគោលបំណងអភិវឌ្ឍន៍ជាតិ។ សេដ្ឋកិច្ចប្រទេសជាតិមានការលូតលាស់បណ្តាលឱ្យសេដ្ឋកិច្ចគ្រួសារមានការរីកចម្រើន កាលណាគ្មានការបំពុល និងរំខានដោយកាកសំណល់ជាពិសេសជាងនេះទៅទៀតនោះគឺ បរិស្ថានស្អាតគ្មានការបំពុលសុខភាពក៏ល្អប្រសើរជាមួយការរស់នៅ ដូចនេះយើងទាំងអស់គ្នាត្រូវចូលរួមទាំងអស់គ្នាដើម្បីថែរក្សាបរិស្ថានឱ្យបានល្អស្អាត ស្របតាមពាក្យស្លោករបស់ក្រសួងបរិស្ថាន "បរិស្ថានស្អាតផ្តើមចេញពីយើងទាំងអស់គ្នា"។

# អនុសាសន៍

# អនុសាសន៍

បើទៅយោងតាមការពិនិត្យមើលអំពីស្ថានភាពជាក់ស្តែង បរិស្ថាននៃប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះទោះបីជាការទទួលរងនៅការបំពុលជាច្រើនក៏ពិតមែន ក៏ប៉ុន្តែរាជរដ្ឋាភិបាលបច្ចុប្បន្នក្រសួងស្ថាប័នដែលពាក់ព័ន្ធនានា ដូចជាក្រសួងបរិស្ថាន ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បាននឹងកំពុងខិតខំប្រឹងប្រែងក្នុងការយកចិត្តទុកដាក់ ក្នុងការស្វែងរកវិធានការ និងយន្តការដោះស្រាយនៃការបំពុលនៅកម្ពុជា។ មិនតែប៉ុណ្ណោះមានទាំងការផ្សព្វផ្សាយនូវព័ត៌មាននៅតាមគ្រប់មធ្យោបាយ អំពីការយល់ដឹងអំពីផលប៉ះពាល់នៃការបំពុល បរិស្ថានដែលជាកត្តាចាំបាច់ដែលរាជរដ្ឋាភិបាលត្រូវផ្សព្វផ្សាយ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបអាចយល់ដឹង និងបង្កើនចំណេះសដឹងកាន់តែច្បាស់អំពីផលប៉ះពាល់យ៉ាងធ្ងន់ធរដែលកើតចេញពីការបំពុល។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះខ្ញុំបាទសូមសេចក្តីអនុញ្ញាតបញ្ចេញនូវមតិដូចតទៅ ៖

- ការកាត់បន្ថយការបំពុលបន្តិចម្តងៗ ដែលកើតចេញពីសកម្មភាពប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗដោយការសហការរួមគ្នា និងទប់ស្កាត់កុំឱ្យកើតមានការបំពុលខាងលើដែលជាដំណោះស្រាយដែលមានគុណប្រយោជន៍ និងគុណតម្លៃខ្ពស់ចំពោះការយន្តការនេះ
- ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការទប់ស្កាត់ការបំពុលមិនឱ្យមានការីករាលដាលពីមួយថ្ងៃទៅមួយថ្ងៃ វាកើតចេញពីនាក់ទាំងអស់ដគ្នាចូលរួមរីករាយសហការយ៉ាងជិតស្និតនៅក្នុងការអនុវត្តនូវវិធានការនានា ដែលបានដាក់ចេញរបស់រាជរដ្ឋាភិបាល តាមរយៈអនុក្រឹត្យ សេចក្តីប្រកាស សារាចរជាដើម
- ការរួមចំណែកពីនាក់ទាំងអស់គ្នាជាចំណែកដ៏ធំធេង ក្នុងការធ្វើឱ្យប្រទេសមានការរីកចម្រើនលូតលាស់ប្រកបដោយនិរន្តភាព និងភាពគង់វង្សស្ថិតស្ថេរ
- រោងចក្រសហគ្រាស កន្លែងដែលពាក់ព័ន្ធផ្សេងៗទៀតត្រូវតែអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល
- អនុវត្តយ៉ាងតឹងរឹងចំពោះអ្នកដែលប្រព្រឹត្តល្មើស ឬផ្ទុយពីគោលការណ៍របស់រាជរដ្ឋាភិបាល
- ការអនុវត្តធ្វើជាគំរូល្អសម្រាប់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន មិនថាប្រជាពលរដ្ឋ និងបុគ្គលដែលពាក់ព័ន្ធជាដើម។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ
- អនុក្រឹត្យលេខ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក ចុះនៅថ្ងៃទី ១០ ខែតុលា ២០១៧
- អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ចុះនៅថ្ងៃទី២៥ ខែធ្នូ ២០១៧
- អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គីសនី និងអេឡិចត្រូនិច ចុះនៅថ្ងៃទី០១ ខែកុម្ភៈ ២០១៦
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ២០១៥
- អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះនៅថ្ងៃទី ១០ ខែកក្កដា ២០០០
- អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការបំពុលសំណល់រឹង ចុះនៅថ្ងៃទី២៧ ខែមេសា ១៩៩៩
- ប្រកាស ស្តីពី ការគ្រប់គ្រងសំណល់អាគុយ និងសំណលថ្មពិល ឆ្នាំ ២០១៦
- ប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង
- សារាចរស្តីពីវិធានការ ទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ,ចេញនៅថ្ងៃទី០២ ខែមករា ២០២០

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- សៀវភៅអប់រំបំណិនជីវិតស្តីពិបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ ២០១៣
- សៀវភៅបុណ្យឈាបនកិច្ច ឬបុណ្យខ្មោច រៀបរៀងដោយ ព្រះគ្រូចៅអធិការ វត្តត្រពាំងធំ ខេត្តកំពង់ស្ពឺ

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រក្រសួងបរិស្ថាន https://www.moe.gov.kh/index/3321
- គេហទំព័រក្រសួងបរិស្ថាន https://www.moe.gov.kh/index/1894
- គេហទំព័រក្រសួងបរិស្ថាន https://www.moe.gov.kh/index/28428
- គេហទំព័រ https://www.khsearch.com/qna/8284

- គេហទំព័រ https://www.khsearch.com/qna/18682
- គេហទំព័រ https://www.khsearch.com/qna/18681
- គេហទំព័រ https://www.khsearch.com/qna/8874
- គេហទំព័រ https://www.khsearch.com/qna/10411
- គេហទំព័រ https://km.warbletoncouncil.org/tipos-contaminacion-acustica-16274#menu-14
- គេហទំព័រ https://km.warbletoncouncil.org/contaminacion-por-basura-16524
- គេហទំព័រ https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health ការបំពុលខ្យល់
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/
- គេហទំព័រ https://www.rfi.fr/km/cambodia/rubbish-11-04-2016
- គេហទំព័រ https://khmernote.com.kh/news/60954
- គេហទំព័រ https://seylanote.wordpress.com/?s= សំណល់រាវ
- គេហទំព័រ https://www.rfi.fr/km/cambodia/បរិស្ថាន-ធម្មជាតិ-ស្ថានភាព-គុណភាព-ដី-ធ្លាក់ចុះ-ខ្លាំង-គ្រោះថ្នាក់-ដល់-មនុស្សជាតិ
- គេហទំព័រ https://cambo-report.com/article/96
- គេហទំព័រ https://www.conserve-energy-future.com/causes-effects-solutions-of-air-pollution.php
- គេហទំព័រ https://www.conserve-energy-future.com/causes-and-effects-of-noise-pollution.php
- គេហទំព័រ https://www.conserve-energy-future.com/causes-and-effects-of-soil-pollution.php
- គេហទំព័រ https://www.health.com.kh/archives/326971
- គេហទំព័រ https://www.postposmo.com/km/contaminacion-del-suelo/#Consecuencias_de_la_Contaminacion_del_Suelo
- គេហទំព័រ https://www.postposmo.com/km/contaminacion-del-suelo/#Contaminacion_del_Suelo

- គេហទំព័រ https://www.renovablesverdes.com/km/contaminacion-atmosferica/
- គេហទំព័រ https://www.renovablesverdes.com/km/contaminacion-del-suelo/#Consecuencias_de_la_contaminacion_del_suelo
- គេហទំព័រ https://studyboom.ru/km/zagryaznenie-i-istoshchenie-pochvy-prichiny-problemy-zagryazneniya-pochv-i-puti-ih/
- គេហទំព័រ https://www.lotus-radio.com/22-12-2017-health-pisey-radio-sanitation-and-clean-water-in-rural/
- គេហទំព័រ https://openjicareport.jica.go.jp/pdf/11689353_08.PDF
- reducing waste, reusing and recycling resources
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/solid-waste/
- របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១, ការកសាងភាពធន់៖ អនាគតរបស់អ្នកជនបទក្នុងការប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ. ក្រសួងបរិស្ថាន និងអង្គការ UNDP កម្ពុជា, ២០១១. https://opendevelopmentcambodia.net/km/topics/climate-change/#ref-74589-1
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/environmental-and-biodiversity-protection/

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១ ៖ ការបំពុលទឹក

ឧបសម្ព័ន្ធទី២ ៖ ការបំពុលខ្យល់

ឧបសម្ព័ន្ធទី៣ ៖ ការបំពុលដី

ឧបសម្ព័ន្ធទី៤ ៖ ការបំពុលសំឡេង

ឧបសម្ព័ន្ធទី៥ ៖ ការបំពុលសំណល់រឹង រាវ

## ឧបសម្ព័ន្ធគតិយុត្ត

ឧបសម្ព័ន្ធទី១ ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ឧបសម្ព័ន្ធទី២ ៖ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ

ឧបសម្ព័ន្ធទី៣ ៖ អនុក្រឹត្យលេខ១៦៨ ស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិក ចុះនៅថ្ងៃទី ១០ តុលា ២០១៧

ឧបសម្ព័ន្ធទី៤ ៖ អនុក្រឹត្យលេខ២៣៥ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ចុះនៅថ្ងៃទី២៥ ធ្នូ ២០១៧

ឧបសម្ព័ន្ធទី៥ ៖ អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិច ចុះនៅថ្ងៃទី០១ កុម្ភៈ ២០១៦

ឧបសម្ព័ន្ធទី៦ ៖ អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

ឧបសម្ព័ន្ធទី៧ ៖ អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះនៅថ្ងៃទី ១០ កក្កដា ២០០០

ឧបសម្ព័ន្ធទី៨ ៖ អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩

ឧបសម្ព័ន្ធទី៩ ៖ អនុក្រឹត្យលេខ៣៦ ស្តីពីការបំពុលសំណល់រឹង ចុះនៅថ្ងៃទី២៧ មេសា ១៩៩៩

ឧបសម្ព័ន្ធទី១០ ៖ ប្រកាស ស្តីពី ការគ្រប់គ្រងសំណល់អាគុយ និងសំណលថ្មពិល ឆ្នាំ ២០១៦

ឧបសម្ព័ន្ធទី១១ ៖ សារាចរស្តីពីវិធានការ ទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ, ចេញនៅថ្ងៃទី០២ មករា ២០២០

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធរូបភាពទី១ ៖ ការបំពុលទឹក



ការបង្ហូរទឹកកខ្វក់ចូលប្រភពទឹក



ការចោលសម្រាមទៅក្នុងទឹក



ការបូមខ្សាច់




ជាតិពុលដែលចេញពី កប៉ាល ទូក នាវាផ្សេងៗ

## ឧបសម្ព័ន្ធរូបភាពទី២ ៖ ការបំពុលខ្យល់



ផ្សែងពុលចេញពីយានយន្ត



ផ្សែងពុលចេញពីឈាបទដ្ឋាន



ការបំពុលដោយធូលី

## ឧបសម្ព័ន្ធរូបភាពទី៣ ៖ ការបំពុលសំឡេង



ការបំពុលដោយប្រភពចល័ត




ការបំពុលដោយប្រភពអចល័ត

## ឧបសម្ព័ន្ធរូបភាពទី៤ ៖ ការបំពុលដី



សកម្មភាពកសិកម្ម



ការបំពុលដោយសំរាម



សំណល់ដែលចេញពីឧស្សាហកម្ម រោងចក្រ សហគ្រាស

# ឧបសម្ព័ន្ធរូបភាពទី៥ ៖ ការបំពុលដោយសំណល់រឹង រាវ




ការបំពុលដោយសំណល់រឹង




ការបំពុលដោយសំណល់រាវ

# ឧបសម្ព័ន្ធគតិយុត្ត

ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បកចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**_

អនុក្រឹត្យនេះមានគោលបំណងបង្កើនប្រសិទ្ធភាពលើការកាត់បន្ថយ ការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ថង់ប្លាស្ទិក សំដៅធានាបាននូវកិច្ចគាំពារសុខភាពសាធារណៈ បរិស្ថាន និងសោភ័ណភាព។

**មាត្រា២._**

អនុក្រឹត្យនេះមានគោលដៅ ដូចតទៅ៖

- កំណត់តួនាទី និងពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិលើការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ថង់ប្លាស្ទិក និងការកែច្នៃសំណល់ថង់ប្លាស្ទិក
- កំណត់អំពីវិធានការទូទៅលើការគ្រប់គ្រងថង់ប្លាស្ទិក
- កំណត់នូវវិធានការគិតកម្រៃបន្ថែមលើការប្រើប្រាស់ថង់ប្លាស្ទិករបស់អតិថិជន
- អប់រំ និងលើកកម្ពស់ការយល់ដឹងសាធារណៈនិងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តកម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និង
- ជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការកែច្នៃសំណល់ថង់ប្លាស្ទិកនៅក្នុងស្រុក និងការផលិតសម្ភារប្លាស្ទិកដែលងាយពុកផុយ។

**មាត្រា៣._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ថង់ប្លាស្ទិកស្តើងមានដៃយួរ និងការកែច្នៃសំណល់ថង់ប្លាស្ទិកក្នុងស្រុក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤._**

និយមន័យវាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ៖

១. **ថង់ប្លាស្ទិក** សំដៅដល់វត្ថុផលិតពីប្លាស្ទិកទន់អាចបត់បែនស្រួលនិងមិនងាយពុកផុយ ប្រើសម្រាប់ផ្ទុក វេចខ្ចប់ទំនិញនិងសម្ភារផ្សេងៗ។

២. **ថង់ប្លាស្ទិកស្តើងមានដៃយួរ** សំដៅដល់ថង់ប្លាស្ទិកដែលត្រូវបានផលិតឡើងសម្រាប់ប្រើប្រាស់ដើម្បីវេចខ្ចប់ក្នុងការទិញទំនិញផ្សេងៗ ដែលមានដៃយួរ ទម្ងន់ស្រាល និងកម្រាស់ស្តើង។

៣. **ទីតាំងអាជីវកម្ម** សំដៅដល់ទីតាំងប្រកបមុខរបរទិញលក់ ចែកចាយទំនិញ និងសម្ភារនានា។

៤. **ទីតាំងសេវាកម្ម** សំដៅដល់ទីតាំងផ្តល់សេវា(បម្រើ)នានា ដូចជា ភោជនីយដ្ឋាន សណ្ឋាគារ រមណីយដ្ឋានទេសចរណ៍។ល។

៥. **ផ្សារទំនើប** សំដៅដល់អគារលក់ទំនិញចម្រុះ រួមមានសម្ភារប្រើប្រាស់ក្នុងលំនៅដ្ឋាន បន្លែ ត្រី សាច់ គ្រឿងទេស គេសជ្ជៈ សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ។ល។ ដែលអតិថិជនអាចធ្វើការជ្រើសរើសដោយខ្លួនឯង និងមានប្រព័ន្ធគិតប្រាក់រួម។

៦. **មជ្ឈមណ្ឌលពាណិជ្ជកម្ម** សំដៅដល់អគារទំនើបដែលមានស្តង់ ឬហាងលក់ទំនិញចម្រុះច្រើនប្រភេទ ហើយមានម្ចាស់និងមានកន្លែងគិតប្រាក់ដាច់ដោយឡែកពីគ្នា។

៧. **វត្ថុជំនួសថង់ប្លាស្ទិក** សំដៅដល់វត្ថុប្រើប្រាស់ក្នុងការផ្ទុក ការវេចខ្ចប់ចំណីអាហារនិងសម្ភារផ្សេងៗ ដែលមិនមែនជាប្លាស្ទិកដូចជា៖ ស្លឹកឈូក ស្លឹកចេក ថង់ក្រណាត់ ឬថង់បរិស្ថាន។ល។

៨. **តំបន់គ្មានថង់ប្លាស្ទិក** សំដៅដល់ទីតាំង ដែលត្រូវបានហាមឃាត់ការប្រើប្រាស់ថង់ប្លាស្ទិកគ្រប់ប្រភេទរួមមាន៖ តំបន់អភិរក្សជីវៈចម្រុះ តំបន់ឧទ្យានធម្មជាតិ តំបន់ដងទន្លេនិងច្រាំងទន្លេ តំបន់បឹង ស្រះ ត្រពាំង តំបន់សមុទ្រនិងមាត់សមុទ្រ តំបន់សួនច្បារសាធារណៈ។ល។

៩. **ការគ្រប់គ្រងថង់ប្លាស្ទិក** សំដៅដល់ការគ្រប់គ្រងវដ្តរបស់ថង់ប្លាស្ទិក គឺគិតចាប់ផ្តើមពីការផលិត ការចែកចាយ ការប្រើប្រាស់ ការនាំចូល ការកែច្នៃ និងការបោះបង់ចោល។

១០.**វត្ថុជាតុងាយពុកផុយ** សំដៅវត្ថុដែលអាចបំបែកជាតុដោយឆាប់រហ័សក្រោមអំពើរបស់បាក់តេរី ឬជីវសរីរាង្គ។

១១.**ជីវប្លាស្ទិក** សំដៅដល់ប្លាស្ទិកដែលផលិតចេញពីធនធានជីវមាសដែលអាចកកើតឡើងវិញ ដូចជា ម្សៅ ឬប្រេងធម្មជាតិ ។ល។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥.**_

ក្រសួងបរិស្ថានមានភារកិច្ច៖

- ដឹកនាំ និងសម្របសម្រួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក
- ដឹកនាំរៀបចំតាក់តែងគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងផ្តល់ជំនាញបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពនូវវិធានការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក
- សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានអប់រំ អង្គការជាតិ និងអន្តរជាតិ និងវិស័យឯកជន ធ្វើការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយគ្រប់រូបភាពជូនដល់សាធារណជនឱ្យយល់ដឹងពីផលប៉ះពាល់លើការប្រើប្រាស់និងការបោះចោលសំណល់ថង់ប្លាស្ទិក
- ជំរុញ តាមដាន និងផ្សព្វផ្សាយលទ្ធផលអនុវត្តការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកថ្នាក់ជាតិប្រចាំឆ្នាំ និងលើកទិសដៅអនុវត្តឆ្នាំបន្តបន្ទាប់
- រៀបចំយន្តការលើកសរសើរ និងជូនរង្វាន់ដល់បុគ្គល ឬអង្គភាពដែលមានស្នាដៃលើការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងការកែច្នៃសំណល់ប្លាស្ទិកជារៀងរាល់ឆ្នាំ និង
- ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវព័ត៌មានស្តីពីហានិភ័យពាក់ព័ន្ធនឹងការនាំចូល និងការចែកចាយថង់ប្លាស្ទិក ដើម្បីជាមូលដ្ឋានពង្រឹងប្រសិទ្ធភាពគ្រប់គ្រងមុខទំនិញនេះនៅមាត់ច្រកព្រំដែន។

**មាត្រា៦.**_

ក្រសួងមហាផ្ទៃមានភារកិច្ច៖

- ចូលរួមរៀបចំគោលនយោបាយ យុទ្ធសាស្ត្រនិងគោលការណ៍ណែនាំនានា សំដៅបម្រើដល់

ការងារកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និង

- ផ្តល់កិច្ចសហការក្នុងការគាំទ្រ និងចូលរួមក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងថង់ប្លាស្ទិក។

**មាត្រា៧._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចក្នុងការពិនិត្យលទ្ធភាព ឬភាពចាំបាច់នៃការដាក់ចេញនូវគោលការណ៍និងលិខិតបទដ្ឋាននានាដែលទាក់ទងទៅនឹង៖

- ការកំណត់អត្រាការប្រមូលពន្ធ អាករ និងនីតិវិធីពាក់ព័ន្ធចាំបាច់នានាផ្សេងៗទៀត ដើម្បីគាំទ្រការអនុវត្តសកម្មភាពកាត់បន្ថយថង់ប្លាស្ទិក និង
- ចងក្រងទិន្នន័យពីបរិមាណនៃការនាំចូលថង់ប្លាស្ទិកប្រចាំឆ្នាំ និងបញ្ជូនមកក្រសួងបរិស្ថាន ដើម្បីជាមូលដ្ឋានក្នុងវាយតម្លៃការអនុវត្តការកាត់បន្ថយថង់ប្លាស្ទិក។

**មាត្រា៨._**

ក្រសួងទេសចរណ៍មានភារកិច្ច៖

- ដឹកនាំអនុវត្តស្របតាមតួនាទីរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បញ្ចូលនូវសូចនាករប្រសិទ្ធភាពទុកដាក់សំណល់ថង់ប្លាស្ទិកក្នុងទីក្រុង ទីប្រជុំជន ដើម្បីវាយតម្លៃសោភ័ណភាពទីក្រុងស្អាត និង
- សហការអប់រំ និងផ្សព្វផ្សាយជូនដល់សាធារណជនឱ្យយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់ និងការបោះចោលសំណល់ថង់ប្លាស្ទិក។

**មាត្រា៩._**

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់ការគាំទ្រនិងការសម្របសម្រួល ព្រមទាំងដឹកនាំអនុវត្តការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋាន និងវិធានការចាំបាច់នានាក្នុងការណែនាំ និងជំរុញការអនុវត្តការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក
- លើកទឹកចិត្ត និងគាំទ្រការកែច្នៃឡើងវិញសំណល់ថង់ប្លាស្ទិក
- រៀបចំបង្កើតតំបន់គ្មានថង់ប្លាស្ទិក នៅតាមទីបរិវេណ ឬទីសាធារណៈមួយចំនួនដូចជា តំបន់ទន្លេ តំបន់សមុទ្រ បូជនីយដ្ឋាន សួនច្បារ ឧទ្យាននានា សណ្ឋាគារ និងរមណីយដ្ឋាន ដោយពង្រីកជាបណ្តើរៗក្នុងដែនភូមិសាស្ត្រខ្លួន
- ជំរុញ និងគាំទ្រការអប់រំផ្សព្វផ្សាយពាក់ព័ន្ធនឹងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងការបង្កើនការប្រើប្រាស់វត្ថុជំនួសថង់ប្លាស្ទិក និង
- ដឹកនាំអនុវត្តវិធានការតាមនីតិវិធីចំពោះអំពើល្មើសនានា ដែលពាក់ព័ន្ធនឹងការមិនគោរពតាមបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះ។

**មាត្រា១០._**

រដ្ឋបាលរាជធានី ខេត្ត អាចផ្ទេរភារកិច្ចចាំបាច់ និងសមស្របមួយចំនួនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីអនុវត្តការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១១._**

មន្ទីរបរិស្ថានរាជធានី ខេត្ត បំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងថង់ប្លាស្ទិក និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការអប់រំនិងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់ពីការប្រើប្រាស់ថង់ប្លាស្ទិក
- ជំរុញការអនុវត្តសកម្មភាពកាត់បន្ថយថង់ប្លាស្ទិកនៅគ្រប់គោលដៅផលិត និងចែកចាយថង់ប្លាស្ទិក
- ជំរុញសកម្មភាពកែច្នៃសំណល់ថង់ប្លាស្ទិក និងលើកសំណើដើម្បីបង្កើតតំបន់គ្មានថង់ប្លាស្ទិក និង
- សហការត្រួតពិនិត្យ និងអនុវត្តវិធានការតាមនីតិវិធីលើអំពើល្មើសពាក់ព័ន្ធនឹងការមិនគោរពលើបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

## ជំពូកទី៣
## ភាតព្វកិច្ចក្នុងការចូលរួមកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក

**មាត្រា១២._**

ប្រជាពលរដ្ឋគ្រប់រូបត្រូវមានកាតព្វកិច្ចចូលរួមចំណែកក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកតាមតែអាចធ្វើទៅបាន តាមរយៈការនាំយកថង់ប្លាស្ទិកមកប្រើប្រាស់ឡើងវិញ ឬប្រើប្រាស់វត្ថុជំនួសថង់ប្លាស្ទិក ។

**មាត្រា១៣._**

ម្ចាស់ទីតាំងអាជីវកម្ម និងម្ចាស់សេវាកម្មនានាដែលមានការផ្តល់ថង់ប្លាស្ទិកដល់អតិថិជន ហើយស្ម័គ្រចិត្តចូលរួមអនុវត្តកម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកត្រូវបានទទួលការលើកទឹកចិត្ត។

## ជំពូកទី៤
## វិធានការឆ្ពោះទៅលើការគ្រប់គ្រងថង់ប្លាស្ទិក

**មាត្រា១៤._**

ថង់ប្លាស្ទិកស្តើងមានដៃយួរគឺជាប្រភេទទំនិញហាមឃាត់លើការនាំចូល ការផលិតក្នុងស្រុក ការចែកចាយ និងការប្រើប្រាស់ លើកលែងតែ៖

ក-ថង់ប្លាស្ទិកនោះ មានកម្រាស់ចាប់ពី ០,០៣ មីល្លីម៉ែត្រ ឡើងទៅ និង

ខ-ថង់ប្លាស្ទិកនោះមានរង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥ សង់ទីម៉ែត្រ ឬ១០ អ៊ីង ឡើងទៅ។

រាល់ការនាំចូលនិងការផលិតថង់ប្លាស្ទិកក្នុងស្រុក ប្រភេទនៅក្នុងចំណុច(ក) និង(ខ) ខាងលើ ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន លើកលែងតែការនាំចូលគ្មានលក្ខណៈពាណិជ្ជកម្មក្នុងបរិមាណតិចជាង ១០០គីឡូក្រាម។

**មាត្រា១៥.**_

ក្នុងករណីចាំបាច់ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលអំពីការកំណត់ប្រភេទ ឬកម្រាស់ ឬរង្វាស់ទទឹងបាតថង់ប្លាស្ទិក ដូចមានចែងក្នុងមាត្រា១៤ ឱ្យស្របទៅតាមស្ថានភាព ឬភាពដែលអាចអនុវត្តបាន។

**មាត្រា១៦.**_

ការនាំចូលនិងការផលិតថង់ ឬសម្ភារវេចខ្ចប់ដែលផលិតពីវត្ថុធាតុងាយពុកផុយ (Biodegradable) ឬជីវប្លាស្ទិក (Bioplastic) ត្រូវបានដាក់អាករពិសេសជាបន្ទុករបស់រដ្ឋ។ ធុរជនពាក់ព័ន្ធត្រូវស្នើសុំដាក់អាករពិសេសជាបន្ទុករបស់រដ្ឋទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីក្រសួងបរិស្ថាន។

**មាត្រា១៧.**_

លើកទឹកចិត្តដល់ការកែច្នៃនិងការផលិតក្នុងប្រទេសនូវសម្ភារនានាអំពីសំណល់ថង់ប្លាស្ទិកក្នុងស្រុក តាមរយៈការសរសើរ ការជូនរង្វាន់ និងការដាក់អាករពិសេសជាបន្ទុករបស់រដ្ឋ។ ធុរជនពាក់ព័ន្ធត្រូវស្នើសុំដាក់អាករពិសេសជាបន្ទុករបស់រដ្ឋទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីក្រសួងបរិស្ថាន។

**មាត្រា១៨.**_

ការផ្តល់ថង់ប្លាស្ទិកជូនដល់អតិថិជននៅតាមផ្សារទំនើបនិងមជ្ឈមណ្ឌលពាណិជ្ជកម្ម ត្រូវគិតកម្រៃបន្ថែម។ កម្រៃបន្ថែមនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្រៃបន្ថែមដែលទទួលបានពីការលក់ថង់ប្លាស្ទិក ត្រូវគិតបញ្ចូលទៅក្នុងវិក្កយបត្រលក់ទំនិញ។

ក្នុងករណីចាំបាច់ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសអន្តរក្រសួងដើម្បីកែសម្រួលអំពីការកំណត់កម្រៃបន្ថែមពីអតិថិជនលើការប្រើប្រាស់ថង់ប្លាស្ទិក និងទីតាំង ឱ្យស្របទៅតាមស្ថានភាព ឬភាពដែលអាចអនុវត្តបាន។

**មាត្រា១៩.**_

ការអនុវត្តនូវគោលការណ៍ «ការផ្តល់ថង់ប្លាស្ទិកដល់អតិថិជនត្រូវគិតកម្រៃបន្ថែម» នៅតាមគ្រប់ទីតាំងអាជីវកម្មនិងសេវាកម្មទាំងអស់ នឹងត្រូវអនុវត្តពេញលេញនៅទូទាំងប្រទេស នៅកាលបរិច្ឆេទដែល

ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ។

**មាត្រា២០._**

ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំឱ្យមានយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការយកកម្រៃបន្ថែមពីអតិថិជនលើការប្រើប្រាស់ថង់ប្លាស្ទិក ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

**មាត្រា២១._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ត្រូវពិនិត្យលទ្ធភាពផ្តល់កញ្ចប់ថវិកាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តកម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

**មាត្រា២២._**

ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ត្រូវរៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាព និងបញ្ហាប្រឈមក្នុងការអនុវត្តអនុក្រឹត្យនេះ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា២៣._**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការដកហូតថង់ប្លាស្ទិកដែលល្មើស
- ការផ្អាកសកម្មភាពអាជីវកម្ម ឬសកម្មភាពផលិតជាបណ្តោះអាសន្ន
- ការផ្អាក ឬដកហូតការអនុញ្ញាតក្នុងការនាំចូល ឬការផលិតថង់ប្លាស្ទិកក្នុងស្រុក និង
- ការពិន័យអន្តរការណ៍។

ការអនុវត្តទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែការផ្អាក ឬដកហូតការអនុញ្ញាតក្នុងការនាំចូល ឬការផលិតថង់ប្លាស្ទិកក្នុងស្រុក ដែលជាសមត្ថកិច្ចផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនានារបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុវត្តជំពូកនេះ មានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

យន្តការ និងនីតិវិធីសម្រាប់ការអនុវត្តទណ្ឌកម្មខាងលើ និងការចាត់ចែងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដែលកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌។

**មាត្រា២៤._**

ពិន័យជាប្រាក់ដែលមានចែងក្នុងជំពូកនេះ អាចត្រូវបានអនុវត្តជាពិន័យអន្តរការណ៍ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

**មាត្រា២៥._**

ការផលិតក្នុងស្រុក ឬការចែកចាយថង់ប្លាស្ទិកដែលមានកម្រាស់ និងមានទទឹងផ្នែកបាតមិនគោរពតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច(ក) និង(ខ) កថាខណ្ឌទី១ នៃមាត្រា១៤ នៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ។
- ការដកហូតថង់ប្លាស្ទិកដែលល្មើស។
- ការផ្អាកសកម្មភាពអាជីវកម្ម ឬសកម្មភាពផលិតជាបណ្តោះអាសន្នក្នុងរយៈពេលមិនលើសពី ១ (មួយ) ឆ្នាំ។
- ការផ្អាក ឬដកហូតការអនុញ្ញាតក្នុងការផលិតថង់ប្លាស្ទិកក្នុងស្រុក។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវដកហូតថង់ប្លាស្ទិកដែលល្មើស និងត្រូវទទួលការពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ឬស្មើនឹង ២ (ពីរ) ដងនៃតម្លៃសរុបរបស់ថង់ប្លាស្ទិកដែលល្មើសក្នុងការផលិតក្នុងស្រុក ឬចែកចាយ។

**មាត្រា២៦._**

ផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម និងទីតាំងអាជីវកម្ម និងសេវាកម្មនានាដែលប្រើប្រាស់ ឬផ្តល់ឱ្យប្រើប្រាស់នូវថង់ប្លាស្ទិកដែលមានកម្រាស់ និងមានទទឹងផ្នែកបាតមិនគោរពតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច(ក) និង(ខ) កថាខណ្ឌទី១ នៃមាត្រា១៤ នៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ។
- ការដកហូតថង់ប្លាស្ទិកដែលល្មើស។
- ការពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**មាត្រា២៧._**

ការផលិតថង់ប្លាស្ទិកនៅក្នុងស្រុក ដែលល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា១៤ នៃអនុក្រឹត្យនេះ

ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការដកហូតថង់ប្លាស្ទិកដែលល្មើស។
- ការផ្អាកសកម្មភាពអាជីវកម្ម ឬសកម្មភាពផលិតជាបណ្ដោះអាសន្នក្នុងរយៈពេលមិនលើស ពី ១ (មួយ) ឆ្នាំ។
- ការផ្អាក ឬដកហូតការអនុញ្ញាតក្នុងការផលិតថង់ប្លាស្ទិកក្នុងស្រុក។
- ការពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ឬស្មើនឹង ២ (ពីរ) ដងនៃតម្លៃសរុបរបស់ថង់ប្លាស្ទិកដែលល្មើស។

**មាត្រា២៨._**

ការផ្ដល់ថង់ប្លាស្ទិកដល់អតិថិជនមិនគិតកម្រៃបន្ថែម ឬគិតកម្រៃបន្ថែមមិនស្របទៅនឹងការកំណត់ នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមបណ្ដាផ្សារ ទំនើបនិងមជ្ឈមណ្ឌលពាណិជ្ជកម្ម ដូចមានចែងនៅក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការព្រមាន ជាលាយលក្ខណ៍អក្សរ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវទទួលការពិន័យជាប្រាក់ ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា២៩._**

ចំពោះថង់ប្លាស្ទិកដែលមានកម្រាស់ស្តើងជាង ០,០៣ មីលីម៉ែត្រ និងមានទទឹងផ្នែកបាតក្រោម តូចជាង ២៥ សង់ទីម៉ែត្រ ឬ ១០ អ៊ីង ហើយមានក្នុងស្តុកបច្ចុប្បន្ន អាចអនុញ្ញាតឱ្យធ្វើការចែកចាយ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានរហូតដល់ដំណាច់ឆ្នាំ២០១៧។

**មាត្រា៣០._**

បទប្បញ្ញត្តិនៃមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តក្នុងរយៈពេល ០៦ ខែ ក្រោយពេល អនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា៣១._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ម្ចាស់ផ្សារទំនើប ម្ចាស់មជ្ឈមណ្ឌលពាណិជ្ជកម្ម និងប្រជាពលរដ្ឋទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៩ ៧ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី ក្រសួងទេសចរណ៍**

**ថោង ខុន**

**រដ្ឋមន្ត្រី ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**<u>កន្លែងទទួល៖</u>**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសុវត្ថិភាព សុខភាពសាធារណៈ និងការអភិរក្សជីវចម្រុះ។



ka

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- រៀបចំ កែសម្រួល និងពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ប្រគល់មុខងារប្រតិបត្តិការ និងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ
- កំណត់នូវវិធានការចាំបាច់នានាដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ អំពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន ក្នុងការអភិវឌ្ឍន៍ ឬវិនិយោគសាងសង់ ប្រតិបត្តិការនិងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ ពុំមានវិសាលភាពអនុវត្តលើការគ្រប់គ្រងសំណល់រាវឧស្សាហកម្មឡើយ។

**មាត្រា៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- ទឹកកខ្វក់ សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់ រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅដ្ឋាន បុរីលំនៅដ្ឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និង តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
- សំណល់រាវ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម
- ប្រព័ន្ធលូ សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ(បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)
- បណ្តាញលូរួម សំដៅដល់បណ្តាញលូប្រមូល និងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងជាមួយគ្នា។



kr

- បណ្ដាញលូដាច់ដោយឡែក សំដៅដល់បណ្ដាញលូប្រមូលនិងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងញែកដាច់ផ្សេងពីគ្នា
- បណ្ដាញលូមេ សំដៅដល់បណ្ដាញលូដែលភ្ជាប់ទៅនឹងអាងស្តុក ស្ថានីយ៍បូម ឬស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្ដាញលូមេរង សំដៅដល់ប្រព័ន្ធលូដែលភ្ជាប់ទៅនឹងបណ្ដាញលូមេ និងទទួលទឹកកខ្វក់ពីបណ្ដាញលូខ្នែង
- បណ្ដាញលូខ្នែង សំដៅដល់បណ្ដាញលូដែលភ្ជាប់ទៅនឹងបណ្ដាញលូមេ ឬបណ្ដាញលូ មេរង។
- បណ្ដាញលូខ្នែងរង សំដៅដល់បណ្ដាញលូដែលភ្ជាប់ទៅនឹងបណ្ដាញលូខ្នែង និងទទួលទឹកកខ្វក់ពីទីតាំង ឬប្រភពបញ្ចេញ
- ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយ៍បូមទឹកលូ ឬទឹកភ្លៀង បណ្ដាញលូមេ បណ្ដាញលូមេរង ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ
- អាងស្តុកធម្មជាតិ សំដៅដល់អាងស្តុកទឹក បឹង ប្រឡាយ ឬស្រះសាធារណៈ ដែលបានប្រើប្រាស់សម្រាប់ស្តុក និងសម្អាតទឹកកខ្វក់តាមលក្ខណៈធម្មជាតិ
- ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ
- តំបន់ទឹកសាធារណៈ សំដៅដល់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជា ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ បឹង ស្រះ ត្រពាំង សមុទ្រ ដៃសមុទ្រ ពាម ប្រព័ន្ធប្រឡាយធារាសាស្ត្រ ទឹកក្រោមដី។ល។
- ទីប្រជុំជន សំដៅដល់ទីប្រជុំជនរាជធានី ទីប្រជុំជនខេត្ត ទីប្រជុំជនក្រុង ទីប្រជុំជនស្រុក និងទីប្រជុំជនខណ្ឌ
- ទីតាំង សំដៅដល់លំនៅដ្ឋាន លំនៅដ្ឋានប្រមូលផ្តុំ បុរីលំនៅដ្ឋាន អគារអាជីវកម្ម និងទីក្រុងរណប
- លំនៅដ្ឋាន សំដៅដល់ផ្ទះស្នាក់នៅជាលក្ខណៈឯកជនផ្ទាល់ខ្លួន
- លំនៅដ្ឋានប្រមូលផ្តុំ សំដៅដល់ផ្ទះស្នាក់នៅដែលទទួលសិទ្ធិកាន់កាប់បន្តពីអាជីវកម្មសាងសង់លំនៅដ្ឋានលក់ តែពុំមានអ្នកទទួលខុសត្រូវរួម
- បុរីលំនៅដ្ឋាន សំដៅដល់តំបន់អភិវឌ្ឍន៍លំនៅដ្ឋានប្រមូលផ្តុំដែលមានម្ចាស់បុរីនៅបន្តទទួលខុសត្រូវរួម
- អគារអាជីវកម្ម សំដៅដល់ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន ទីផ្សារ ផ្សារទំនើប អគារពាណិជ្ជកម្ម អគារសេវាកម្ម ទីសត្តឃាត អាផាតមែន និងអគារខុនដូ



ಒ

- **ទីក្រុងរណប** សំដៅដល់តំបន់អភិវឌ្ឍន៍ចម្រុះ រួមមាន៖ លំនៅដ្ឋានទំនើប អាផាតមែន អគារខុនដូ ផ្សារទំនើប សណ្ឋាគារ ភោជនីយដ្ឋាន អគារពាណិជ្ជកម្ម អគារសេវាកម្ម មណ្ឌលកំសាន្ត។ល។
- **អាងសិបទិច** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ
- **កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ** សំដៅដល់ការបង់ថ្លៃសម្រាប់ការថែទាំ ជួសជុល ស្តារ និងពង្រីកអណ្តូងលូ បណ្តាញលូ ប្រឡាយចំហ អាងស្តុក និងដំណើរការស្ថានីយ៍បូមទឹកកខ្វក់
- **កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ការបង់ថ្លៃសម្រាប់ការសម្អាតទឹកកខ្វក់
- **សំណល់ភក់** សំដៅដល់កាកសំណល់ពីអាងសិបទិច ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- **រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត** សំដៅដល់ទីកន្លែងសម្រាប់អ្នកទេសចរទៅទស្សនា និងសម្រាកលំហែរកាយ ដែលមានផ្តល់នូវសេវាម្ហូបអាហារ ភេសជ្ជៈ កន្លែងស្នាក់ កីឡា កម្សាន្ត និងទិញទំនិញ។ល។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងការងារបច្ចេកទេសប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ និងផែនការអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច
- រៀបចំបទដ្ឋានបច្ចេកទេសស្តីពីការសាងសង់ គ្រប់គ្រង ប្រតិបត្តិការ និងការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនក្នុងការវិនិយោគសាងសង់ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គាំទ្រធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជន អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទដ្ឋានបច្ចេកទេស

- សហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំរុញដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងប្រតិបត្តិការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សម្របសម្រួល និងកៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៦.-**

ក្រសួងបរិស្ថានមានតួនាទីដឹកនាំនយោបាយ និងកំណត់យុទ្ធសាស្ត្រអំពីការគ្រប់គ្រងទឹកកខ្វក់ និងត្រួតពិនិត្យដំណើរការប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រ សម្រាប់គ្រប់គ្រងការបំពុលទឹកតំបន់ទឹកសាធារណៈបង្កពីការបញ្ចេញទឹកកខ្វក់
- រៀបចំស្តង់ដាបញ្ចេញទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងស្តង់ដាបញ្ចេញទឹកសម្អាតរួច ចេញពីស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម
- ចូលរួមផ្តល់ប្រឹក្សាបច្ចេកទេសលើសំណើវិនិយោគបង្កើតប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យវាយតម្លៃការបំពាក់បរិក្ខារ ដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម និងការបញ្ចេញទឹកកខ្វក់ក្រោយការធ្វើប្រព្រឹត្តកម្ម
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនលើការងារវិនិយោគប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជនអំពីសេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងគោលដៅការពារគុណភាពបរិស្ថាន។

**មាត្រា៧.-**

ក្រសួងមហាផ្ទៃមានតួនាទីគាំទ្រ សម្របសម្រួល និងជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ផ្តល់ការអន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញ និងផ្តល់ការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងនាមអាណាព្យាបាលលើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៨.-**

រដ្ឋបាលរាជធានី ត្រូវបំពេញតួនាទីដឹកនាំគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការមេសម្រាប់អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំ និងគ្រប់គ្រងបណ្តាញលូមេ មេរង និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យការប្រមូលកម្រៃសេវាប្រើប្រាស់បណ្តាញលូមេ មេរង និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្ម ទឹកកខ្វក់
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូមេ មេរង និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូ
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូមេ មេរង និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- កៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៩.-**

រដ្ឋបាលខណ្ឌ ត្រូវបំពេញតួនាទីប្រតិបត្តិការងារគ្រប់គ្រងបណ្តាញលូខ្នែង និងខ្នែងរងដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំបណ្តាញលូខ្នែង និងខ្នែងរង



Vf

- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- រៀបចំ និងគ្រប់គ្រងសេវាប្រើប្រាស់បណ្តាញលូខ្នែងនិងខ្នែងរង
- ផ្តល់ការអនុញ្ញាតការស្នើសុំតភ្ជាប់បណ្តាញលូ ការស្នើសុំប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ធ្វើការតភ្ជាប់តំណ លូទឹកកខ្វក់ចេញពីលំនៅដ្ឋានមកបណ្តាញលូខ្នែង និងខ្នែងរង ដោយទទួលកម្រៃសេវាកំណត់
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូខ្នែង និងខ្នែងរង
- អនុវត្តការប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូខ្នែង និងខ្នែងរង
- អាចធ្វើប្រតិភូកម្មលើការងារមួយផ្នែកនៃការគ្រប់គ្រង បណ្តាញលូខ្នែង និងខ្នែងរងជូនរដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជំរុញឱ្យមានការចូលរួមពីរដ្ឋបាលសង្កាត់ក្នុងការអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាព
- កៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូខ្នែង និងខ្នែងរង
- ជំរុញការអប់រំប្រជាពលរដ្ឋក្នុងការថែទាំ និងចូលរួមប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា១០.-**

រដ្ឋបាលខេត្ត ត្រូវបំពេញតួនាទីគាំទ្រ និងជំរុញប្រតិបត្តិការ ការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- សហការរៀបចំផែនការមេសម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមទីប្រជុំជនក្រុង ស្រុក
- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំការអនុវត្តន៍វិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សម្របសម្រួលការរៀបចំសេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- អនុវត្ត និងសម្របសម្រួលក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និង ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់



ᥰ

- កៀរគរកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមទីប្រជុំជនក្រុង ស្រុក។

**មាត្រា១១.-**

រដ្ឋបាលក្រុង ស្រុក ត្រូវបំពេញតួនាទីប្រតិបត្តិការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារកសាង ជួសជុល ស្តារ ថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- ធ្វើការតភ្ជាប់តំណលូទឹកកខ្វក់ចេញពីលំនៅដ្ឋានមកបណ្តាញលូខ្មែង និង ខ្មែងរងដោយទទួលកម្រៃសេវាកំណត់
- រៀបចំ និងគ្រប់គ្រងសេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ផ្តល់ការអនុញ្ញាតការស្នើសុំតភ្ជាប់បណ្តាញលូ ការសុំប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អនុវត្តការប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញការអប់រំប្រជាពលរដ្ឋក្នុងការថែទាំ និងចូលរួមប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អាចធ្វើប្រតិភូកម្មលើការងារមួយផ្នែកនៃការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជូនរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជំរុញឱ្យមានការចូលរួមពីរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាព
- កៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារក្នុងការអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា១២.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធ

ប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការមេសម្រាប់គ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ពិនិត្យផ្តល់យោបល់ការស្នើសុំតភ្ជាប់បណ្តាញលូ ការប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងចូលរួមសហការអនុវត្តទណ្ឌកម្មលើបទល្មើស
- លើកកម្ពស់ការយល់ដឹងប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំផ្សព្វផ្សាយពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាពនិងដំណើរការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា១៣.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការងារគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញក្រោយប្រព្រឹត្តកម្ម និងមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការមេសម្រាប់គ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើគម្រោងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញ
- ផ្តល់យោបល់លើការស្នើសុំការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ឬតំបន់ទឹកសាធារណៈ
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបញ្ចេញទឹកកខ្វក់ ឬការបំពុលទឹក និងចូលរួមសហការអនុវត្តទណ្ឌកម្មលើបទល្មើស
- លើកកម្ពស់ការយល់ដឹងប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំផ្សព្វផ្សាយពីការគ្រប់គ្រងទឹកកខ្វក់
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីការគ្រប់គ្រង និងការបញ្ចេញទឹកកខ្វក់។

## ជំពូកទី៣

## វិធានការលើការគ្រប់គ្រងទឹកកខ្វក់ ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

**មាត្រា១៤.-**

ស្តង់ដានៃការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន

ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម គឺមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

ស្តង់ដានៃការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្តដែលបានឆ្លងកាត់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬចូលទៅក្នុងប្រព័ន្ធលូមុនការធ្លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈ គឺមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា១៥.-**

ក្នុងករណីចាំបាច់ ដើម្បីធានាការការពារសុខភាពសាធារណៈ និងអភិរក្សជីវចម្រុះនៃតំបន់ទឹកសាធារណៈណាមួយ ក្រសួងបរិស្ថានអាចពិនិត្យសម្រេចរៀបចំស្តង់ដានៃការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬចូលទៅក្នុងប្រព័ន្ធលូមុនការធ្លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយឡែកពីស្តង់ដាដែលមានចែងក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ។

ស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែក ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា១៦.-**

ម្ចាស់លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- រៀបចំអាងសិបទិចអនុលោមតាមលិខិតអនុញ្ញាតសាងសង់
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ
- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងករណីដែលទឹកកខ្វក់ក្នុងតំបន់ទីប្រជុំជនត្រូវបានប្រមូលទៅសម្អាតនៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា១៧.-**

ម្ចាស់អគារអាជីវកម្មដែលទីតាំងស្ថិតនៅក្នុងតំបន់ទីប្រជុំជនមានស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- រៀបចំអាងសិបទិចរួមអនុលោមតាមលិខិតអនុញ្ញាតសាងសង់
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូ ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញបោលទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូ ដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម



ល

- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា ១៨.-**

ម្ចាស់អគារអាជីវកម្ម ដែលទីតាំងស្ថិតនៅក្នុងតំបន់ទីប្រជុំជនពុំមានស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- រៀបចំអាងសិបទិចរួមអនុលោមតាមលិខិតអនុញ្ញាតសាងសង់
- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ឱ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២នៃ អនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែកដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មុននឹងបញ្ចេញចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងករណីត្រូវប្រើប្រាស់សម្រាប់ការបញ្ចេញទឹកកខ្វក់ដែលសម្អាតរួច
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ចូលក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ។

**មាត្រា ១៩.-**

ម្ចាស់អគារអាជីវកម្ម និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ដែលមានទីតាំងនៅតាមដងឬដីចំណីសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹង ។ល។ ឬស្ថិតនៅលើផ្ទៃទឹក ដែលទទួលបានសិទ្ធិអាជីវកម្មស្របច្បាប់ ត្រូវទទួលខុសត្រូវគ្រប់គ្រងទឹកកខ្វក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួន ដូចខាងក្រោម៖

- មិនធ្វើការបង្ហូរទឹកកខ្វក់ ដែលមិនទាន់បានឆ្លងកាត់ប្រព្រឹត្តកម្មសម្អាតចូលទៅក្នុងតំបន់ទឹកសាធារណៈ
- រៀបចំប្រព័ន្ធស្តុកទឹកកខ្វក់រួម សម្រាប់ការបូមបញ្ចេញទៅក្នុងប្រព័ន្ធលូសាធារណៈ ឬ ដឹកជញ្ជូនចេញយកទៅសម្អាតនៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម តាមការតម្រូវរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ឱ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃ អនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែកដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មុននឹងបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈ
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ដែលសម្អាតរួចចូលទៅក្នុងតំបន់ទឹកសាធារណៈ។

**មាត្រា ២០.-**

ម្ចាស់បុរីលំនៅដ្ឋាន និងទីក្រុងរណប ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ក្នុងតំបន់គ្រប់គ្រងរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែក ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មុននឹងបញ្ចេញចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងករណីត្រូវការប្រើប្រាស់សម្រាប់ការបញ្ចេញទឹកកខ្វក់ដែលសម្អាតរួច
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ។

**មាត្រា ២១.-**

បន្ថែមលើកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចមានចែងក្នុងមាត្រាទី២០ នៃអនុក្រឹត្យនេះ ម្ចាស់គម្រោងអភិវឌ្ឍន៍នៃសំណង់បុរីលំនៅដ្ឋាន ឬទីក្រុងរណបថ្មី ត្រូវទទួលខុសត្រូវរៀបចំបណ្តាញលូទឹកកខ្វក់ដាច់ដោយឡែកពីបណ្តាញលូទឹកភ្លៀងនៅក្នុងតំបន់របស់ខ្លួន។

**មាត្រា ២២.-**

ការសុំតភ្ជាប់បណ្តាញលូពីទីតាំងណាមួយចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយត្រូវមានការផ្តល់យោបល់បច្ចេកទេសពី៖

- ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ ចំពោះទីតាំងមានបរិវេណក្រោម ៣០.០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាអគារតូចជាង ៥.០០០ ម៉ែត្រក្រឡា
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ចំពោះទីតាំងមានបរិវេណចាប់ពី ៣០.០០០ ម៉ែត្រក្រឡាដល់ ១០០.០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាអគារចាប់ពី ៥.០០០ ម៉ែត្រក្រឡាដល់ ១៥.០០០ ម៉ែត្រក្រឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន ចំពោះទីតាំងមានផ្ទៃក្រឡាលើសពី ១០០.០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាអគារធំជាង ១៥.០០០ ម៉ែត្រក្រឡា។

យន្តការនៃការផ្តល់សេវាពាក់ព័ន្ធនឹងការស្នើសុំតភ្ជាប់បណ្តាញលូ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

នីតិវិធីលម្អិតក្នុងការស្នើសុំតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ដូចមានចែងតម្រូវក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២៣.-**

ការសុំបញ្ចេញចោលទឹកកខ្វក់ពីទីតាំងអាជីវកម្ម ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវមានការ



1R

អនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត ដោយមានការផ្តល់យោបល់ពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

ការសុំបញ្ចេញចោលទឹកកខ្វក់ពីទីតាំងបុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត ដោយមានការផ្តល់យោបល់ពីមន្ទីរបរិស្ថានរាជធានី ខេត្ត និងឬការផ្តល់យោបល់បច្ចេកទេសពីក្រសួងបរិស្ថាន។

យន្តការនៃការផ្តល់សេវាពាក់ព័ន្ធនឹងការស្នើសុំបញ្ចេញចោលទឹកកខ្វក់ពីទីតាំងអាជីវកម្ម ទីតាំងបុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

នីតិវិធីលម្អិតក្នុងការស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ ឬទឹកកខ្វក់ដែលបានសម្អាតរួចចូលទៅក្នុងបណ្តាញលូ ឬតំបន់ទឹកសាធារណៈ ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

### មាត្រា ២៤.-

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ក្នុងការៈ

- ទប់ស្កាត់ការរំលោភយកដីសាធារណៈនៃប្រព័ន្ធលូ ឬការសាងសង់សំណង់ផ្សេងៗដែលធ្វើឱ្យខូចខាតប្រព័ន្ធលូ ឬរាំងស្ទះដល់ចរន្តហូរនៃប្រព័ន្ធលូ
- ទប់ស្កាត់ការរំលោភយកដីសាធារណៈនៃអាងស្តុកធម្មជាតិ ឬការចាក់ដីលុបអាងស្តុកធម្មជាតិដែលធ្វើឱ្យបាត់បង់សមត្ថភាពស្តុក ឬសម្អាតទឹកកខ្វក់
- សិក្សា និងធ្វើការបង្វែរប្រព័ន្ធលូបញ្ចេញទឹកកខ្វក់ទីប្រជុំជនដែលហូរចូលផ្ទាល់ទៅក្នុងតំបន់ទឹកសាធារណៈ ឱ្យហូរឆ្លងកាត់អាងស្តុកធម្មជាតិ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជាមុន
- រៀបចំផែនការ និងជំរុញការអនុវត្តការស្តារអាងស្តុកធម្មជាតិ ដើម្បីធានាសមត្ថភាពស្តុក និងសម្អាតតាមលក្ខណៈធម្មជាតិនៃទឹកកខ្វក់ទីប្រជុំជន
- ធ្វើការគ្រប់គ្រង និងដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ដើម្បីធានាគុណភាពទឹកកខ្វក់សម្អាតរួចដែលត្រូវបញ្ចេញ គឺឆ្លើយតបនឹងស្តង់ដារបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែក ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

### មាត្រា ២៥.-

ហាមឃាត់ជាដាច់ខាត ការចាក់សំរាម សំណល់រឹង សំណល់ប្រេងឥន្ធនៈ សារធាតុគីមី សំណល់កកពីអាងសិបទិច ឬពីប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវរោងចក្រ ចូលទៅក្នុងប្រព័ន្ធលូ អាងស្តុកធម្មជាតិ ឬចូលទៅក្នុងតំបន់ទឹកសាធារណៈ។

## ជំពូកទី៤
## សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

**មាត្រា២៦.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង និងការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូដែលស្ថិតក្នុងដែនសមត្ថកិច្ច ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុវត្ថិភាពបរិស្ថាន។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចផ្តល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូ ទៅឱ្យអង្គភាពជំនាញ ឬក្រុមហ៊ុនឯកជនជាអ្នកទទួលអនុវត្តជំនួស។

ការប្រគល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូទៅឱ្យក្រុមហ៊ុនឯកជន ត្រូវធ្វើឡើងស្របតាមនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា២៧.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង និងការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ចឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុវត្ថិភាពបរិស្ថាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក អាចផ្តល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ទៅឱ្យអង្គភាពជំនាញ ឬក្រុមហ៊ុនឯកជនជាអ្នកទទួលអនុវត្តជំនួស។

ការប្រគល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ទៅឱ្យក្រុមហ៊ុនឯកជន ត្រូវធ្វើឡើងស្របតាមនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា២៨.-**

ការកំណត់នីតិវិធី យន្តការ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងបរិស្ថាន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៩.-**

ចំណូលដែលប្រមូលបានពីកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ត្រូវបង់ចូលក្នុងចំណូលផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ ជួលជុល ស្តារ ឬថែទាំប្រព័ន្ធលូ។

ចំណូលដែលប្រមូលបានពីកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវបង់ចូលក្នុងចំណូលផ្ទាល់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក សម្រាប់ប្រើប្រាស់ក្នុងដំណើរការ ជួលជុល ថែទាំប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងសម្រាប់ការតាមដានត្រួតពិនិត្យគុណភាពទឹកកខ្វក់ដែលសម្អាតរួច។

**មាត្រា៣០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យលទ្ធភាពផ្តល់កញ្ចប់ថវិកាបន្ថែមទៅដល់រដ្ឋបាលថ្នាក់ក្រោម



ck

ជាតិសម្រាប់គាំទ្រអនុវត្តការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ។

## ជំពូកទី៥
## ការត្រួតពិនិត្យ និងអធិការកិច្ច

**មាត្រា៣១.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត និងការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើការត្រួតពិនិត្យលើការងារតភ្ជាប់លូ ឬបណ្តាញលូចេញពីទីតាំង ចូលទៅក្នុងប្រព័ន្ធលូសាធារណៈដែលបានស្នើសុំនៅក្រោមបញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៣២.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចលើបញ្ហាពាក់ព័ន្ធករណី៖

- ការលួចតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈដោយពុំមានលិខិតអនុញ្ញាត
- ការបង្កឱ្យមានការខូចខាតប្រព័ន្ធលូសាធារណៈ ឬប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ឬឯកជន
- បណ្តឹងពីករណីស្ទះ ឬខូចខាតប្រព័ន្ធលូ។

**មាត្រា៣៣.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវចុះធ្វើការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការបំពាក់បរិក្ខារ និងដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមទីតាំងផ្ទាល់ និងការយកសំណាកទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តរួចមកវិភាគឱ្យបានជាប់ជាប្រចាំ។

**មាត្រា៣៤.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចលើបញ្ហាពាក់ព័ន្ធករណី៖

- ការលួចបញ្ចេញទឹកកខ្វក់ពីទីតាំងចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយផ្ទាល់ ឬមិនផ្ទាល់ ដោយពុំមានលិខិតអនុញ្ញាត
- ការលួចបញ្ចេញទឹកកខ្វក់ពីទីតាំង ដោយពុំឆ្លងកាត់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្តឹង ឬការទទួលបានព័ត៌មានពីការបំពុលតំបន់ទឹកសាធារណៈពីការបញ្ចេញទឹកកខ្វក់។

**មាត្រា៣៥.-**

មន្ត្រីដែលត្រូវបំពេញភារកិច្ចក្នុងការចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ដូចមានចែងក្នុងមាត្រា៣២ មាត្រា៣៣ មាត្រា៣៤ និងមាត្រា៣៥ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖



kR

- បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួនពេលចូលទៅក្នុងទីតាំង ដើម្បីធ្វើការត្រួតពិនិត្យឬធ្វើអធិការកិច្ច យកគំរូតាង និងកំណត់ត្រា
- ធ្វើកំណត់ហេតុ ឬរបាយការណ៍នៅទីតាំងដែលធ្វើការត្រួតពិត្យ ឬធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួម
- ត្រូវធ្វើការសាកសួរ ឬតម្រូវឱ្យម្ចាស់ទីតាំងឬអ្នកទទួលខុសត្រូវផ្តល់ព័ត៌មាន ឬឯកសារចាំបាច់ពាក់ព័ន្ធនានា សម្រាប់ប្រើប្រាស់ក្នុងការធ្វើកំណត់ហេតុ ឬរបាយការណ៍ និងដាវត្ថុតាង
- ត្រូវផ្តល់ច្បាប់ចំលងនៃកំណត់ហេតុ ឬរបាយការណ៍ឱ្យម្ចាស់ទីតាំង ឬអ្នកទទួលខុសត្រូវ អ្នកចូលរួមពីស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ សាក្សី និងរក្សាច្បាប់ដើមសម្រាប់ប្រើប្រាស់ក្នុងនីតិវិធីបន្ត។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា៣៦.-**

ទណ្ឌកម្មក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការតម្រូវសំណងជួសជុល ឬស្តារការខូចខាតប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការតម្រូវសំណងជួសជុល ឬស្តារការខូចខាតបរិស្ថាន
- ការពិន័យអន្តរការណ៍។

ការអនុវត្តទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែការតម្រូវសំណងជួសជុលឬស្តារការខូចខាតបរិស្ថាន ដែលជាសមត្ថកិច្ចផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា៣៧.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេច ពីការអនុវត្តទណ្ឌកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តជំពូកនេះ មានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតអនុវត្តទណ្ឌកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅ៖

- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ករណីពាក់ព័ន្ធការតភ្ជាប់បណ្តាញលូ ការងារសេវាប្រើប្រាស់ប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬ
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ករណីពាក់ព័ន្ធការស្នើសុំ និងការបញ្ចេញទឹកកខ្វក់ពីទីតាំង។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវធ្វើការឆ្លើយតបនឹងបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬ រដ្ឋមន្ត្រីក្រសួងបរិស្ថានខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។



1/12

**មាត្រា៣៨.-**

ការពិន័យអន្តរការណ៍ អាចអនុវត្តបានក្នុងករណីដែលជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ស្របតាមទោសប្បញ្ញត្តិនៃអនុក្រឹត្យនេះ។ ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរលត់បណ្តឹងអាជ្ញា ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងនៃបទល្មើសហើយបញ្ជូនទៅតុលាការតាមនីតិវិធី ។ ក្នុងករណីនេះ ទោសពិន័យអន្តរការណ៍ ត្រូវក្លាយជាទោសពិន័យជាប្រាក់។

**មាត្រា៣៩.-**

នីតិវិធីសម្រាប់ការចាត់ចែងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសដែលកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌។

**មាត្រា៤០.-**

លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ដែលតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈដោយពុំបានសុំការអនុញ្ញាត ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន)រៀល ទៅ ១០០.០០០ (ដប់ម៉ឺន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។

**មាត្រា៤១.-**

លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ដែលពុំព្រមបង់ប្រាក់សេវាប្រើប្រាស់ប្រព័ន្ធលូ ឬសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៣០.០០០ (បីម៉ឺន) រៀល ទៅ ១០០.០០០ (ដប់ម៉ឺន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

**មាត្រា៤២.-**

អគារអាជីវកម្មដែលពុំបានរៀបចំអាងសិបទិចរួម ឬតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈ ដោយ



kr

ពុំបានសុំការអនុញ្ញាត ឬធ្វើការបញ្ចេញចោលទឹកកខ្វក់ចូលប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ ដោយពុំបានសុំកាអនុញ្ញាតដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន)រៀល ទៅ ១.០០០.០០០ (មួយលាន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល។

**មាត្រា៤៣.-**

អគារអាជីវកម្ម បុរីលំនៅស្ថាន ឬទីក្រុងរណប ដែលពុំព្រមបង់ប្រាក់សេវាប្រើប្រាស់ប្រព័ន្ធលូ ឬសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្ម មួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

**មាត្រា៤៤.-**

អគារអាជីវកម្ម តំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្តដែលពុំបានធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ ឬធ្វើការបញ្ចេញទឹកកខ្វក់ចូលប្រព័ន្ធលូឬតំបន់ទឹកសាធារណៈ ដែលគុណភាពមិនឆ្លើយតបនឹងស្តង់ដារបញ្ចេញទឹកកខ្វក់ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ២០០.០០០ (ម្ភៃម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា៤៥.-**

អគារអាជីវកម្ម តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្តតាំងនៅតាមដង ឬជិតចំណីតំបន់ទឹកសាធារណៈ ឬស្ថិតនៅលើផ្ទៃទឹក ដែលពុំបានរៀបចំប្រព័ន្ធស្តុកទឹកកខ្វក់រួម ឬលួចធ្វើការបង្ហូរទឹកកខ្វក់ចូលតំបន់ទឹកសាធារណៈ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖



kr

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី៥០០.០០០(ហាសិបម៉ឺន)រៀលទៅ៥.០០០.០០០(ប្រាំលាន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

**មាត្រា៤៦.-**

បុរីលំនៅស្ថាន ឬទីក្រុងរណបដែលពុំបានធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ ឬធ្វើការបញ្ចេញទឹកកខ្វក់ចូលប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ ដែលគុណភាពមិនឆ្លើយតបនឹងស្តង់ដាបញ្ចេញទឹកកខ្វក់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន)រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល។

**មាត្រា៤៧.-**

បុរីលំនៅស្ថាន ឬទីក្រុងរណបដែលធ្វើការតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈដោយពុំបានសុំការអនុញ្ញាត ឬធ្វើការបញ្ចេញចោលទឹកកខ្វក់ចូលប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈដោយពុំបានសុំការអនុញ្ញាត ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៥០០.០០០(ហាសិបម៉ឺន)រៀលទៅ៣.០០០.០០០(បីលាន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

**មាត្រា៤៨.-**

សំណង់បុរីលំនៅស្ថាន ឬទីក្រុងរណបជាគម្រោងអភិវឌ្ឍន៍ថ្មី ដែលពុំបានរៀបចំបណ្តាញលូទឹកកខ្វក់ដាច់ដោយឡែកពីបណ្តាញលូទឹកភ្លៀងនៅក្នុងតំបន់របស់ខ្លួន ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ១០.០០០.០០០(ដប់លាន)រៀល។

**មាត្រា៤៩.-**

បុគ្គលដែលបង្កឱ្យមានការបាក់បែក ឬខូចខាតប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬបង្កឱ្យខូចខាតបរិក្ខារគ្រឿងចក្រនៃស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ឬបង្កឱ្យមានការរអាក់រអួលនៃដំណើរការស្ថានីយ៍

ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល
- ការបង់ប្រាក់សំណងជួសជុលការបាក់បែកឬខូចខាតប្រព័ន្ធលូសាធារណៈ
- ការបង់ប្រាក់សំណងជួសជុលការខូចខាតបរិក្ខារគ្រឿងចក្រនៃស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ឬការធ្វើឱ្យមានប្រក្រតីភាពនៃដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា៥០.-**

បុគ្គលដែលយកសំរាម សំណល់រឹង សំណល់ប្រេងឥន្ធនៈ សារធាតុគីមី ឬសំណល់កក់ ចាក់ចូលប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល
- ការប្រមូលយកសំណល់ ឬសារធាតុដែលបានចាក់ចូលចេញពីប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៥១.-**

បទប្បញ្ញត្តិនៃមាត្រា២១ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍន៍នៃសំណង់បុរីលំនៅដ្ឋាន ឬទីក្រុងរណបថ្មី ដែលទទួលបានច្បាប់សាងសង់ក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

**មាត្រា៥២.-**

បទប្បញ្ញត្តិនៃជំពូកទី៦ ទោសប្បញ្ញត្តិ ត្រូវយកមកអនុវត្តចំពោះទីតាំងដែលមានការផ្តល់ជូននូវសេវាកម្មប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ។

ទីតាំងដែលមានការផ្តល់ជូននូវសេវាកម្មប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងក្រសួងសាធារណការ និងដឹកជញ្ជូន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៥៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងស្មារតីនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



ఱ

**មាត្រា៥៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៨ កើត ខែ បុស្ស ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ គ.ស ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធទី១

## ស្តង់ដារបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម

| លរ | ប៉ារ៉ាម៉ែត្រ | ឯកតា | កម្រិតកំណត់ស្តង់ដារ |
|---|---|---|---|
| | | | កម្រិតសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញ ចូលទៅក្នុងប្រព័ន្ធលូ |
| ១ | ប៉េហាស់ ( pH ) | - | ៥ - ៩ |
| ២ | សារធាតុរឹងដែលអណ្តែតក្នុងទឹក (TSS) | mg/l | < ១៥០ |
| ៣ | ប្រេង ឬខ្លាញ់ | mg/l | < ២០ |
| ៤ | $BOD_5$ ( 5 days at 20 $^0$C ) | mg/l | < ៨០ |
| ៥ | COD ($Cr_2O_7^{2-}$ ) | mg/l | < ១២០ |
| ៦ | សាប៊ូ (Detergents -LAS) | mg/l | < ១៥ |
| ៧ | អាសូតសរុប (T-N) | mg-N/l | < ១០ |
| ៨ | ផូស្វ័រសរុប (T-P) | mg-P/l | < ១ |
| ៩ | អាម៉ូញាក់ ( $NH_3$ ) | mg/l | < ៨ |

កំណត់សំគាល់

BOD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែនរលាយក្នុងទឹក ដោយពពួកមីក្រូសរីរាង្គត្រូវការខ្យល់សម្រាប់បំបែកសារធាតុសរីរាង្គ ដែលមាននៅក្នុងសំណាកនៃទឹក។

COD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែន សម្រាប់ប្រតិកម្មអុកស៊ីតកម្មបំបែកសារធាតុសរីរាង្គក្នុងទម្រង់រលាយ ឬជាគ្រាប់ ដែលមានក្នុងទឹក។

# តារាងឧបសម្ព័ន្ធទី២
## ស្តង់ដារបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប
## និងតំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
## ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬឆ្លងកាត់តាមប្រព័ន្ធលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ឯកតា | កម្រិតកំណត់ស្តង់ដា |
|---|---|---|---|
| | | | កម្រិតសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញ ចូលទៅក្នុងប្រភពទឹកសាធារណៈ |
| ១ | ប៉េហាស់(pH) | - | ៦ - ៨ |
| ២ | សារធាតុរឹងដែលអណ្តែតក្នុងទឹក(TSS) | mg/l | < ៨០ |
| ៣ | ប្រេង ឬខ្លាញ់ | mg/l | < ៥ |
| ៤ | $BOD_5$ ( 5 days at 20 $^0$C ) | mg/l | < ៣០ |
| ៥ | COD ( $Cr_2O_7^{2-}$) | mg/l | < ៥០ |
| ៦ | សាប៊ូ ( Detergents -LAS ) | mg/l | < ៧ |
| ៧ | អាស៊ូតសរុប (T-N) | mg-N/l | < ៦ |
| ៨ | ផូស្វរសរុប (T-P) | mg-P/l | < ០,៥ |
| ៩ | អាម៉ូញ៉ាក់($NH_3$) | mg/l | < ៥ |
| ១០ | កូលីហ្វម (Coliform) | MPN/100 ml | ៥០០ - ២៥០០ |

<u>កំណត់សំគាល់</u>

BOD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែនរលាយក្នុងទឹក ដោយពពួកមីក្រូសរីរាង្គត្រូវការខ្យល់សម្រាប់បំបែក សារជាតុសរីរាង្គ ដែលមាននៅក្នុងសំណាកនៃទឹក។

COD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែន សម្រាប់ប្រតិកម្មអុកស៊ីតកម្មបំបែកសារជាតុសរីរាង្គក្នុងទម្រង់រលាយ ឬជាគ្រាប់ ដែលមានក្នុងទឹក។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល
- បានឃើញអនុក្រឹត្យលេខ៩៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- គ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកចាប់ពីចំណុចបង្កើតរហូតដល់ការបោះចោលចុងក្រោយ
- ទប់ស្កាត់ការនាំចូលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដើម្បីបោះចោល
- កាត់បន្ថយការនាំចូលបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលប្រើប្រាស់រួចដែលនៅមានគុណភាពប្រើប្រាស់បាន
- ទប់ស្កាត់ការសាយភាយសារធាតុគ្រោះថ្នាក់ពីសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកចូលក្នុងបរិស្ថានទឹក ដី និងខ្យល់។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

**បរិក្ខារអគ្គិសនី** សំដៅដល់គ្រឿងប្រដាប់ប្រើប្រាស់ដែលដើរដោយចរន្តអគ្គិសនី។

**បរិក្ខារអេឡិចត្រូនិក** សំដៅដល់គ្រឿងម៉ាស៊ីនឬគ្រឿងប្រដាប់ប្រើប្រាស់ដែលដើរដោយចរន្តអគ្គិសនីបង្កើតជាចរន្តអេឡិចត្រុងនៅលើបន្ទះសៀគ្វី។

**សំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក** សំដៅដល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលលែងត្រូវការប្រើតែនៅរូបរាងទាំងមូល និងបំណែកឬកម្ទេចកម្ទីដែលសេសសល់ពីការដោះបំបែក ឬការកែច្នៃនៃបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទាំងឡាយ។

**បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលប្រើប្រាស់រួច** សំដៅដល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលធ្លាប់បានប្រើរួចហើយ ប៉ុន្តែអាចនៅប្រើបន្តទៀតបាន។

**ការកែច្នៃឡើងវិញ** សំដៅដល់ដំណើរការទាញយកធនធានពីសំណល់ ទៅបំប្លែងជាធនធានសម្រាប់ផលិតឡើងវិញ។

**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់ដំណើរការដកយក ឬកម្ទេចចោលជាតិពុល ឬក៏សារធាតុគ្រោះថ្នាក់នានាដែលមានផ្ទុកក្នុងសំណល់ ក្នុងគោលដៅសុវត្ថិភាពបរិស្ថាននៅពេលបោះបង់ចោល។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងបរិស្ថានជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

ក្រសួងបរិស្ថាន ត្រូវបែងចែកការងារគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅមន្ទីរបរិស្ថានរាជធានី ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការផ្តល់សិទ្ធិគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅមន្ទីរបរិស្ថានរាជធានី ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ក្រសួងឧស្សាហកម្មនិងសិប្បកម្មមានភារកិច្ចគ្រប់គ្រងមូលដ្ឋានផលិតកម្មនៃការកែច្នៃឡើងវិញវត្ថុធាតុដើមពីសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក បន្ទាប់ពីមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមហើយ។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកតាមការស្នើសុំរបស់ក្រសួងបរិស្ថាន។

## ជំពូកទី៣
## ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

### ផ្នែកទី១
### វិធានការគ្រប់គ្រង

**មាត្រា៧ .-**

រាល់ការបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅក្នុងប្រភពទឹក ឬទីលានចាក់សំរាម ឬក៏នៅទីសាធារណៈនានា និងការដុត ឬការវាយបំបែកសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលបង្កឱ្យគ្រោះថ្នាក់ដល់បរិស្ថានឬសុខភាពសាធារណៈ ត្រូវហាមឃាត់។

**មាត្រា៨ .-**

គោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា៩ .-**

ក្រសួងបរិស្ថានត្រូវធ្វើបញ្ជីសារពើភណ្ឌអំពីប្រភព ប្រភេទ ទីតាំង និងបរិមាណសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

**មាត្រា១០.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ការធ្វើប្រព្រឹត្តកម្ម ឬឡដុតសំណល់ និងការបង្កើតទីលានបោះចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំ និងបំពេញទម្រង់បែបបទ នៅក្រសួងបរិស្ថាន ឬនៅមន្ទីរបរិស្ថានរាជធានី ខេត្ត យោងទៅតាមកម្រិតនៃការទទួលខុសត្រូវដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ទម្រង់បែបបទនិងគំរូពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

រាល់ការប្រកបអាជីវកម្មឬវិនិយោគដូចមានចែងក្នុងវាក្យខណ្ឌទី១ខាងលើ ត្រូវតែមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថានឬមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា១១.-**

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ការធ្វើប្រព្រឹត្តកម្ម ឬឡដុតសំណល់ និងការបង្កើតទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិច-ត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា១២.-**

រាល់លិខិតអនុញ្ញាតដែលមានចែងក្នុងអនុក្រឹត្យនេះត្រូវបង់កម្រៃសេវា។ កម្រៃសេវានៃការសុំលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.-**

ក្រសួងបរិស្ថាននិងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការអប់រំនិងផ្សព្វផ្សាយអំពីផលប៉ះពាល់បណ្តាលមកពីសារធាតុគ្រោះថ្នាក់ផ្ទុកក្នុងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

## ផ្នែកទី២
## ភារកិច្ចទូទៅ

**មាត្រា១៤.-**

បុគ្គលដែលមានសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវមានភារកិច្ចដូចខាងក្រោម៖

ក- រក្សាទុកសំណល់នៅទីសុវត្ថិភាពនិងដាក់ដោយឡែកពីសំរាមលំនៅឋាន។

ខ- បញ្ជូនសំណល់ទៅទីតាំងកែច្នៃឬកន្លែងប្រមូលផ្តុំសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក តាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៥.-**

អ្នកជួសជុលបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវមានភារកិច្ចដូចខាងក្រោម៖

ក- ទុកដាក់សំណល់បំណែកឬកម្ទេចកម្ទីដែលសេសសល់ពីការជួសជុលរបស់ខ្លួនដោយអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

ខ- រៀបចំទិន្នន័យសំណល់ដែលបង្កើតពីការជួសជុលរបស់ខ្លួន។

គ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលបង្កើតពីការជួសជុលរបស់ខ្លួន ត្រូវកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៦ ._**

ម្ចាស់ទីតាំងអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ដំឡើង ឬកែច្នៃសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- អនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាននៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

ខ- រៀបចំទិន្នន័យសំណល់ដែលបង្កើតពីអាជីវកម្មរបស់ខ្លួន។

គ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលបង្កើតពីអាជីវកម្មរបស់ខ្លួនដែលកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៧ ._**

បុគ្គលដែលផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ប្រមូលនិងទុកដាក់សំណល់ចេញពីដំណើរការផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដោយអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ប្រកបដោយសុវត្ថិភាពបរិស្ថាន។

ខ- បំពាក់ឧបករណ៍ត្រួតពិនិត្យការបំពុលបរិស្ថាន។

គ- រៀបចំទិន្នន័យសំណល់ដែលបង្កើតពីផលិតកម្មរបស់ខ្លួន។

ឃ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលបង្កើតពីផលិតកម្មរបស់ខ្លួនដែលកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៨ ._**

ក្នុងករណីមានគ្រោះថ្នាក់នៅលើទីតាំងឬអំឡុងពេលដឹកជញ្ជូនសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក បុគ្គលដែលជាអ្នកទទួលខុសត្រូវ ត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុតឬស្ថាប័នជំនាញដើម្បីចាត់វិធានការលុបបំបាត់ការបំពុលបរិស្ថាននោះ។

## ជំពូកទី៤
## ការនាំចូល ការនាំចេញបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រើប្រាស់រួច

**មាត្រា១៩ ._**

បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រើប្រាស់រួចមួយចំនួន ត្រូវបានចាត់ទុកជាប្រភេទទំនិញហាមឃាត់។ ការនាំចូល ការនាំចេញនូវទំនិញប្រភេទនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន។

**មាត្រា២០.-**

បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រើប្រាស់រួចមួយចំនួនដូចមានចែងក្នុងមាត្រា១៩ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី៥
## ការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

**មាត្រា២១.-**

រដ្ឋមន្ត្រីក្រសួងបរិស្ថានមានសិទ្ធិចាត់តាំងមន្ត្រីជំនាញចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីនៃការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា២២.-**

ក្នុងពេលចុះបំពេញការងារ មន្ត្រីជំនាញនៃក្រសួងបរិស្ថានត្រូវស្នើសុំកិច្ចសហការនិងសម្របសម្រួលពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត តាមការចាំបាច់។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា២៣.-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន៖

-ការព្រមានជាលាយលក្ខណ៍អក្សរ

-ការផ្អាកលិខិតអនុញ្ញាតប្រកបអាជីវកម្មជាបណ្ដោះអាសន្ន

-ការលុបលិខិតអនុញ្ញាតប្រកបអាជីវកម្មជាស្ថាពរ។

ទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានសិទ្ធិធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធី។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ចដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ដែលបានមកពីការពិន័យចំពោះអំពើល្មើស ដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់

ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា២៤.-**

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណនៃជនល្មើស ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ចដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចរឹបអូសវត្ថុតាងនៃបទល្មើស។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹងចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទៅតុលាការរដ្ឋប្បវេណីមានសមត្ថកិច្ច។

**មាត្រា២៥.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ឬផ្អាកលិខិតអនុញ្ញាតប្រកបអាជីវកម្មជាបណ្តោះអាសន្ន ឬលុបលិខិតអនុញ្ញាតប្រកបអាជីវកម្មជាស្ថាពរ ចំពោះម្ចាស់ទីតាំងផលិតកម្ម ទីតាំងប្រមូលដឹកជញ្ជូន ទីតាំងដោះបំបែក ទីតាំងធ្វើប្រព្រឹត្តកម្ម ឬទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

ក្នុងករណីបង្កព្យសនកម្ម ម្ចាស់ទីតាំងផលិតកម្ម ទីតាំងប្រមូលដឹកជញ្ជូន ទីតាំងដោះបំបែក ទីតាំងធ្វើប្រព្រឹត្តកម្ម ឬទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតបរិស្ថាន និងសុខភាពសាធារណៈដែលខ្លួនបានបង្ក ដោយពុំទាន់គិតដល់ការសងការខូចខាតដែលកើតឡើងដល់ជនរងគ្រោះផ្សេងទៀតឡើយ។ ការវាយតម្លៃទំហំខូចខាតបរិស្ថាននិងសុខភាពសាធារណៈ ត្រូវធ្វើឡើងដោយក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា២៦.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៤០ ០០០(បួនម៉ឺន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តល្មើសដូចខាងក្រោម៖

- បញ្ចេញឬបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅក្នុងប្រភពទឹក ឬទីលានចាក់សំរាម ឬក៏នៅតាមទីសាធារណៈនានា ក្រៅពីការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច

- ដុតឬវាយបំបែកសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ដែលបង្កឱ្យគ្រោះថ្នាក់ដល់បរិស្ថាន។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា២៧.-**

នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា២៦នៃអនុក្រឹត្យនេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី១ ០០០ ០០០(មួយលាន)រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា២៨.-**

បុគ្គលដែលនាំចូលបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលប្រើប្រាស់រួច ដែលត្រូវបានចាត់ទុកជាប្រភេទទំនិញហាមឃាត់ដាច់ខាតនូវការនាំចូល ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

**មាត្រា២៩.-**

បុគ្គលដែលប្រកបអាជីវកម្មដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល និងតម្រូវឱ្យផ្អាកសកម្មភាពជាបន្ទាន់។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៣០.-**

នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា២៩នៃអនុក្រឹត្យនេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៥ ០០០ ០០០(ប្រាំលាន)រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៣១.-**

អំពើក្លែងលិខិតអនុញ្ញាត ឬឯកសារសាធារណៈផ្សេងទៀត ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

**មាត្រា៣២.-**

មន្ត្រីមានសមត្ថកិច្ច ដោយចេតនាបិទបាំងអំពើល្មើសរបស់ម្ចាស់ទីតាំងផលិតកម្ម ទីតាំងប្រមូលដឹកជញ្ជូន ទីតាំងដោះបំបែក ទីតាំងធ្វើប្រព្រឹត្តកម្ម និងទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៣៣.-**

ការវិនិយោគលើការកែច្នៃឡើងវិញគ្រឿងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ដែលបង្កើតក្នុងស្រុក ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣៤.-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន បុគ្គលដែលបាននិងកំពុងប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក សំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក មានរយៈពេល១២(ដប់ពីរ)ខែ ដើម្បីមកបំពេញទម្រង់បែបបទស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

# សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅៈ

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់កក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។
គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។
ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ដិ៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទី និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុង មាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទី សាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំង សិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាត យកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្ដឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្ដឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្ដល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្ដល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព អាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬ ការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាច មានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជី កំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើត សម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថាន សម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០-**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

១១- **ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

១២- **ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

១៣- **អាងស៊ិបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

១៤- **ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើសទៅនឹងប្បញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

១៥- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

# សេចក្តីណែនាំ

## ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំលេង

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំនត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចោញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក-"**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ-"**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចោញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ-"**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## ការគ្រប់គ្រងសំរាម

**មាត្រា ៤.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុង របស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេល

មធ្យម និងរយៈពេលវែង ។

**មាត្រា ៥.-**

ការអនុវត្តន៏ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៏វាក្យខ័ណ្ឌទី ១ នៃមាត្រា៥ នេះត្រូវអនុលោមទៅតាមគោលការណ៏ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៏ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧.-**

ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៨.-**

ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ៩.-**

ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានល្គឹកណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០.-**

ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣

## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ១១.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៏ណែនាំ លើការគ្រប់គ្រងសំណល់ ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

**មាត្រា ១២.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី ក៏រិតស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រ

កបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ១៣.-**

ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្របនឹងមានសុវត្ថិភាព ។

**មាត្រា ១៤.-**

ម្ចាស់សំណល់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

**មាត្រា ១៥.-**

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

**មាត្រា ១៦.-**

ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តនីវាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ១៧.-**

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រ សហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ១៨.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-ប្រភពដើមរបស់សំណល់

គ-ការដឹកជញ្ជូនរបស់សំណល់ និងមធ្យោបាយវេចខ្ចប់

ឃ-ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

**មាត្រា ១៩.-**

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ២០.-**

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុំតែណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

**មាត្រា ២១.-**

ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច
## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ២២.-**

ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា២៣ នេះត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២៤.-**

ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនីតិវិធី ដែលមានចែងខាងក្រោម :

- ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។
- ខ-ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។
- គ-ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។
- ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

**មាត្រា ២៦.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.~**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ២៨.~**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមសមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនោះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៩.~**

កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦
## អវសានបញ្ញត្តិ

**មាត្រា ៣០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង។ខ្លួន។

**មាត្រា ៣២.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣១

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# តារាងឧបសម្ព័ន្ធ

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១-សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ (ក្នុងករណីយកទៅដុត) ។

២-សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស ។

៣-សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាចសំណល់រាវ និងទឹកលូ ។

៤-សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម ។

៥-សំណល់ប្លាស្ទិច "ប៉ូលីវីនីក្លរួ" ។

៦-សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល ។

៧-សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៊ុយទីលីន

៨-សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩-សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០-សំណល់ដែលមានផ្ទុកជាតិបាស

១១-សំណល់លោហៈ និងសមាសធាតុរបស់វារួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្ញូម (Cd) | ដែក (Fe) | |

១២-លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣-សំណល់អំពូលអគ្គិសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១៤-សំណល់អាគុយ និងថ្មពិល

១៥-សំណល់ថ្នាំលាប និងថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦-សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧-សំណល់គ្រឿងផ្ទុះ

១៨-សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩-សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០-សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១-ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២-សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣-សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤-សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥-សំណល់ដែលជាសមាសធាតុសរីរាង្គក្លយអរីន

២៦-សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧-សំណល់ដែលជាសមាសធាតុអាសបេតូស

២៨-សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩-សំណល់ដែលជាសមាសធាតុអេទែ ($R\text{-}COO\text{-}R_1$)

៣០-សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១-សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២-សំណល់ធាតុវិទ្យុសកម្ម

៣៣-សារធាតុដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី៣២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:...៤៤៧...ប្រ.ក...ប.ស្ថ

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងសំណល់អាគុយ និងសំណល់ថ្មពិល

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៣៨៧ ប្រក.បស្ថ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យបោះបង់ចោល
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងសំណល់អាគុយ និងសំណល់ថ្មពិលប្រកបដោយសុវត្ថិភាពបរិស្ថាន។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- គ្រប់គ្រងសំណល់អាគុយ និងសំណល់ថ្មពិល ចាប់ពីចំណុចបង្កើតរហូតដល់បោះចោលចុងក្រោយ
- ទប់ស្កាត់រាល់ការសាយភាយសារធាតុគ្រោះថ្នាក់ ពីសំណល់អាគុយនិងសំណល់ថ្មពិលចូលក្នុងបរិស្ថាន
- ទប់ស្កាត់ការនាំចូលសំណល់អាគុយ និងសំណល់ថ្មពិលក្នុងគោលបំណងស្តុក ធ្វើប្រព្រឹត្តិកម្ម និងបោះបង់ចោល
- លើកកម្ពស់ការអនុវត្តអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងសំណល់អាគុយ និងសំណល់ថ្មពិល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

- **សំណល់អាគុយ** សំដៅដល់ប្រភេទអាគុយ(អាគុយស្ងួត ឬអាគុយសើម) ឬថ្មសាក( ឧបករណ៍ស្តុកថាមពល"Powerbank") ទាំងឡាយណា ដែលខូចមិនអាចប្រើប្រាស់ឡើងវិញបាន និងត្រូវបានបោះបង់ចោល។

- **សំណល់ថ្មពិល** សំដៅដល់ប្រភេទថ្មពិលគ្រប់ប្រភេទដែលខូច មិនអាចប្រើប្រាស់ឡើងវិញបាន និងត្រូវបោះបង់ចោល ។

## ជំពូកទី ២
## ការគ្រប់គ្រង និងនីតិវិធីសុំលិខិតអនុញ្ញាត

**ប្រការ៥.**

លំនៅដ្ឋានទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម និងសិប្បកម្ម មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់អាគុយនិងសំណល់ថ្មពិលដាច់ដោយឡែកពីសំណល់ផ្សេងទៀត ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត។

**ប្រការ៦.**

ការប្រមូល ការស្តុក ការដឹកជញ្ជូន ការដោះបំបែក និងការធ្វើប្រព្រឹត្តិកម្មសំណល់អាគុយ និងសំណល់ថ្មពិល ក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗទៀត និងការបោះបង់ចោលត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។

រាល់ការប្រមូល ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិលត្រូវមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ។

**ប្រការ៧.**

រាល់អាជីវកម្មសំណល់អាគុយ ដែលមានលក្ខណៈជាអាជីវកម្មគ្រួសារត្រូវសុំលិខិតអនុញ្ញាតពីមន្ទីរបរិស្ថានរាជធានី-ខេត្ត (ដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ១)។

រាល់អាជីវកម្មសំណល់អាគុយ ដែលមានលក្ខណៈជាអាជីវកម្មខ្នាតតូចនិងមធ្យម ឬអាជីវកម្មខ្នាតធំត្រូវសុំលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន (ដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ២)។

**ប្រការ៨.**

រាល់ការនាំចេញសំណល់អាគុយ និងសំណល់ថ្មពិល ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅអាចនឹងត្រូវប្រព្រឹត្តទៅបានលុះត្រាតែមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញ របស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតឱ្យនាំចូលរបស់សាមីប្រទេសជាមុនសិន (ដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ៣)។

**ប្រការ៩.**

ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់អាគុយ និងសំណល់ថ្មពិលដែលបង្កឱ្យប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។

**ប្រការ១០.**

កម្រៃសេវានៃការស្នើសុំការប្រមូល ការស្តុក ការដឹកជញ្ជូន ការដោះបំបែកសំណល់អាគុយ និងសំណល់ថ្មពិលក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗ ការធ្វើប្រព្រឹត្តិកម្ម ការបោះបង់ចោល និង

ការបង្កើតទីលានសុវត្ថិភាពត្រូវអនុវត្តតាមប្រកាសរួម ស្តីពីសេវាសាធារណៈចំពោះសំណល់គ្រោះថ្នាក់រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៣
## ភារកិច្ច និងការទទួលខុសត្រូវ

**ប្រការ១១..**

ម្ចាស់អាជីវកម្ម ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនមន្ទីរបរិស្ថាន ឬក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ពីការវិវឌ្ឍនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិល នៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ដើម្បីធានានូវសុវត្ថិភាពបរិស្ថាន និងសុខភាពសាធារណៈ។

**ប្រការ១២..**

មន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវមានកាតព្វកិច្ចតាមដាន និងរាយការណ៍ជូនក្រសួងបរិស្ថាន រៀងរាល់ ៣ខែម្តង ពីការវិវឌ្ឍនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោល សំណល់អាគុយ និងសំណល់ថ្មពិលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវដើម្បីធានានូវសុវត្ថិភាពបរិស្ថាន និងសុខភាពសាធារណៈ។

**ប្រការ១៣..**

នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន មានភារកិច្ចចុះត្រួតពិនិត្យតាមដាន ការបំពុលដោយអាជីវកម្ម សំណល់អាគុយ និងសំណល់ថ្មពិល និងធ្វើការណែនាំទៅដល់ម្ចាស់អាជីវកម្ម លើវិធានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

## ជំពូកទី ៤
## ទណ្ឌកម្ម

**ប្រការ១៤..**

ការមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាមមាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ ជំពូកទី៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ១៥..**

បន្ទាប់ពីប្រកាសនេះចូលជាធរមានចំពោះអាជីវកម្មដែលបាននិងកំពុងប្រកបអាជីវកម្មប្រមូល ស្តុក ទុកដាក់ ដឹកជញ្ជូន ដោះបំបែក ធ្វើប្រព្រឹត្តិកម្ម និងបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិល ក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗទៀត ត្រូវមកបំពេញទម្រង់បែបបទស្នើសុំលិខិតអនុញ្ញាតប្រកប

អាជីវកម្មស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះក្នុងអំឡុងពេល ១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃចេញប្រកាសនេះតទៅ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ១៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋាន រដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នាយកខុទ្ទកាល័យ និងគ្រប់អង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត
- មន្ទីរបរិស្ថានរាជធានី-ខេត្ត
- ដូចប្រការ ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ១

# សារណាកបត្រព័ត៌មាននៃការគ្រប់គ្រងសំណល់អាគុយ

១. ឈ្មោះសិប្បកម្ម៖...........................................................................................................
អាសយដ្ឋាន៖.....................................................................................................................
ផ្ទៃក្រឡា..........................................ជាកម្មសិទ្ធផ្ទាល់ខ្លួន☐ ជួលពីឯកជន☐ ឬជួលពីរដ្ឋ☐
រយៈពេលវិនិយោគ/អាជីវកម្ម៖..........................បានចាប់ផ្ដើមដំណើរការនៅឆ្នាំ៖....................។

២.ឯកសារភ្ជាប់៖

- លិខិតអនុញ្ញាតពីមន្ទីរពាណិជ្ជកម្ម ☐
- លិខិតអនុញ្ញាតពីមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ☐
- លិខិតអនុញ្ញាតពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ☐
- លិខិតអនុញ្ញាតផ្សេងៗ..................................

៣. ប្រភេទអាជីវកម្ម ឬសិប្បកម្ម៖

☐ ការប្រមូល ☐ ការស្តុកទុក
☐ ការដឹកជញ្ជូន ☐ ការដោះបំបែក
☐ ការធ្វើប្រព្រឹត្តិកម្ម ☐ ការបោះបង់ចោល
☐ ផ្សេងៗ...........................................................................................................

៤. ប្រភេទ និងបរិមាណសំណល់អាគុយ ដែលបានបង្កើតពីអាជីវកម្ម ឬសិប្បកម្ម៖

☐សំណល់រឹងគ្រោះថ្នាក់៖.......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐សំណល់រាវគ្រោះថ្នាក់៖.......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐សំណល់កក់គ្រោះថ្នាក់៖.......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐សំណល់ផេះគ្រោះថ្នាក់៖.......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐ ផ្សេងៗ...........................................................................................................

ធ្វើនៅ...................ថ្ងៃទី............ខែ............ឆ្នាំ២០......
ហត្ថលេខា និងឈ្មោះអ្នករាយការណ៍

ឧបសម្ព័ន្ធ២

# សាលាកបត្រព័ត៌មាននៃការគ្រប់គ្រងសំណល់អាគុយ

១. ឈ្មោះក្រុមហ៊ុន ឬរោងចក្រ.......................................................................................
អាសយដ្ឋាន.........................................................................................................
ផ្ទៃក្រឡា...........................................ជាកម្មសិទ្ធផ្ទាល់ខ្លួន☐ ជួលពីឯកជន☐ ឬជួលពីរដ្ឋ☐
រយៈពេលវិនិយោគ/អាជីវកម្ម:............................បានចាប់ផ្ដើមដំណើរការនៅឆ្នាំ:....................។

២.ឯកសារភ្ជាប់៖

- លិខិតអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ☐
- លិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ☐
- លិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ☐
- លិខិតអនុញ្ញាតផ្សេងៗ..................................

៣. ប្រភេទអាជីវកម្ម ឬសិប្បកម្ម៖

☐ ការប្រមូល ☐ ការស្តុកទុក
☐ ការដឹកជញ្ជូន ☐ ការដោះបំបែក
☐ ការធ្វើប្រព្រឹត្តិកម្ម ☐ ការបោះបង់ចោល
☐ ផ្សេងៗ..........................................................................................

៤. ប្រភេទ និងបរិមាណសំណល់អាគុយ ដែលបានបង្កើតពីអាជីវកម្ម ឬសិប្បកម្ម៖

☐ សំណល់រឹងគ្រោះថ្នាក់:......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐ សំណល់រាវគ្រោះថ្នាក់:......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐ សំណល់កក់គ្រោះថ្នាក់:......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐ សំណល់ផេះគ្រោះថ្នាក់:......................................បរិមាណ......................គ.ក្រ/ថ្ងៃ
☐ ផ្សេងៗ..........................................................................................

ធ្វើនៅ....................ថ្ងៃទី............ខែ............ឆ្នាំ២០......
ហត្ថលេខា និងឈ្មោះអ្នករាយការណ៍

ឧបសម្ព័ន្ធ៣

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងបរិស្ថាន**
**អគ្គនាយកដ្ឋានគាំពារបរិស្ថាន**

## ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញ
## សំណល់អាគុយ និងសំណល់ថ្មពិល

ឈ្មោះក្រុមហ៊ុនស្នើសុំ..........................................................................................................
ឈ្មោះអ្នកទំនាក់ទំនង.....................................................ភេទ.............សញ្ជាតិ.......................
មុខងារក្នុងក្រុមហ៊ុន.............................................អត្តសញ្ញាណប័ណ្ណ.......................................
អាសយដ្ឋានក្រុមហ៊ុន៖ ផ្ទះលេខ..................ផ្លូវលេខ................ក្រុមទី..................ភូមិ................
ឃុំ/សង្កាត់........................................ស្រុក/ខណ្ឌ...........................ខេត្ត/រាជធានី........................
ទូរស័ព្ទ:..........................ទូរសារ:...........................សារអេឡិចត្រូនិក:......................................
វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (អ.ត.ប) លេខ:..........................ចុះថ្ងៃទី.......ខែ.....ឆ្នាំ.......
វិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីក្នុងក្រសួងពាណិជ្ជកម្មលេខ:........................ចុះថ្ងៃទី.......ខែ.....ឆ្នាំ.......

| ល.រ | ឈ្មោះផលិតផល | គុណភាព | បរិមាណស្នើសុំ (គ្រឿង) | បន្សំសារធាតុក្នុងអាគុយ/ថ្មពិល | លេខសម្គាល់ក្នុងតារាងពន្ធគយកម្ពុជា |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |

១. ក្រុមហ៊ុនទទួលយក៖

ឈ្មោះ.........................................................................................................

អាសយដ្ឋាន...................................................................................................

ប្រទេស........................................................................................................

២. រោងចក្រផលិត៖

ឈ្មោះ.........................................................................................................

ប្រទេស........................................................................................................

៣. ទីកន្លែង ឬកំពង់ផែដែលមានបំណងនាំចេញ៖

កាលបរិច្ឆេទមកដល់.......................................................................................

គោលបំណងប្រើប្រាស់.....................................................................................

ព័ត៌មានបន្ថែម:..............................................................................................

..................................................................................................................................

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ..........

ហត្ថលេខានិងត្រា ប្រធានក្រុមហ៊ុន